ទស្សនាវដ្តី
**វិទ្យាស្ថានភាសាជាតិ**
នៃរាជបណ្ឌិត្យសភាកម្ពុជា
Journal of Institute of National
**Royal Academy of Cambodia**



**ឆ្នាំទី១៨** **លេខ១១** **ខែវិច្ឆិកា**
**ព.ស.២៥៦៨** **គ.ស.២០២៤**
Eighteenth Anniversary No.11 November,2024

**ភ្នំពេញ**
Phnom Penh

# ការវិវត្តនៃភាសាខ្មែរ

(បុរេអង្គរ អង្គរ ក្រោយអង្គរ បច្ចុប្បន្ន)

បណ្ឌិត ជួរ គារី បណ្ឌិត មាយ បូរ៉ា
និងលោក កែវ លីណែត
វិទ្យាស្ថានភាសាជាតិ

## ១- ភាសាខ្មែរ

ភាសាខ្មែរគឺជាភាសាមួយស្ថិតនៅក្នុងអម្បូរមន-ខ្មែរ ដែលជាសាខាមួយនៃអម្បូរអូស្រ្តូអាស៊ី ហើយ មានភាសាប្រហែល១២០-១៣០ភាសា តាមមតិរបស់លោក សាំ៉ឌីផ្តត ដែលជាអ្នកស្រាវជ្រាវភាសាមន-ខ្មែរ។ នៅក្នុងអម្បូរមន-ខ្មែរ មានភាសាដូចជា *ភាសាខ្មែរ, ព័រ, គ្រឹង, ទំពួន, សំរែ, ស្ទៀង, ក្នង, ព្រៅ* ជាដើម ។

មានសំណួរមួយបានចោទសួរថា តើភាសាខ្មែរមានដើមកំណើតនៅពេលណា?

បើតាមកំណាយស្ថានីយបុរេប្រវត្តិសាស្ត្រ យើងឃើញថាខ្មែរជាជនជាតិមួយដែលអរិយធម៌ខ្ពង់ខ្ពស់នៅភូមិភាគអាស៊ីអាគ្នេយ៍។ បើតាមការធ្វើកំណាយនៅស្ថានីយល្អាងស្ពានដែលមានប្រាំស្រទាប់ «ស្រទាប់ទី១មានអាយុ៦៨០០ឆ្នាំមុនគ្រិស្តសករាជ ស្ថិតនៅក្នុងសម័យHoabinhian គឺជាអរិយធម៌នៃអ្នកប្រមាញ់និងបេះផ្លែឈើ។ គេបានរកឃើញកុលាភាជន៍ជាដំបូងនៅស្រទាប់ទី២ មានអាយុ៤៣០០ឆ្នាំមុនគ្រិស្តសករាជ ដែលនេះប្រហែលជាសំណល់របស់អ្នកធ្វើស្រែចំការនៅក្នុងប្រទេសកម្ពុជា។ ស្រទាប់ទី៣ មានអាយុ២០០០ឆ្នាំមុនគ្រិស្តសករាជ និងស្រទាប់ទី៤មានអាយុ៥០០ឆ្នាំមុនគ្រិស្តសករាជ ស្ថិតនៅក្នុងសម័យកាលនៃការធ្វើដំណាំស្រូវ។ ស្រទាប់លើបង្អស់មានអាយុ៨០០ឆ្នាំនៃគ្រិស្តសករាជ មានកាលបរិច្ឆេទប្រហែលនឹងដើមសម័យអង្គរដែរ»[1]។ នៅស្ថានីយក្រែកប្រមាណ៣.០០០ឆ្នាំមុនគ្រិស្តសករាជ ស្ថានីយម្លូព្រៃប្រមាណ២០០០ឆ្នាំមុនគ្រិស្តសករាជ និងនៅស្ថានីយអង្គរបុរីប្រមាណ១៥០០-៥០០ឆ្នាំមុនគ្រិស្តសករាជ។ ហេតុដូច្នេះហើយ យើងអាចកំណត់បានថា ភាសាខ្មែរក៏មានកំណើតពីពេលនោះដែរ ពីព្រោះកាលមានសង្គមមនុស្សរស់នៅនោះ គេតែងតែប្រើភាសា ដើម្បីប្រាស្រ័យទាក់ទងគ្នា។

## ២- ដើមកំណើតអក្សរខ្មែរ

តាំងពីមុនសម័យនគរភ្នំ យើងមិនមានភស្តុតាងណាមួយដែលបញ្ជាក់ថាជនជាតិខ្មែរមានឬពុំមានអក្សរសម្រាប់ប្រើប្រាស់នោះទេតែមកដល់សម័យនគរភ្នំ(ហ្វូណន)ទើបគេបានរកឃើញសិលាចារឹកមួយផ្ទាំងសរសេរជាភាសាសំស្ក្រឹតដោយប្រើតួអក្សរព្រាហ្មីអំឡុងសតវត្សរ៍ទី២-៣នៃគ.ស.ក្នុងរាជ្យរបស់ព្រះបាទស្រីមារៈ(តាមឯកសារចិនហៅថា ព្រះបាទហ្វាន់ចេម៉ាន់)ដែលហៅថា **សិលាចារឹកវ៉ូកាញ់**ស្ថិត ក្នុងខេត្តញ៉ាត្រាង(វៀតណាមខាងត្បូង)។ សិលាចារឹកនេះ គេចាត់ទុកថាជាសិលាចារឹកខ្មែរមុនដំបូងគេបង្អស់។ ក៏ប៉ុន្តែអ្នកស្រាវជ្រាវមួយចំនួនដូចជាលោក **អេជែន អៃម៉ូនីញេ**(Etienne Aymonier), លោក **លូីហ្វីណូ**(Louis Finot) លោក **អូហ្គូស្ត៍ បាថ៌**(Auguste BARTH) លោក **អាបែល ប៊ែរហ្គែង**(Abel BERGAIG NE)បានចាត់ទុកថា សិលាចារឹកវ៉ូកាញ់

[1] ធុយ ចាន់ធួន : ស្ថានីយបន្ទាយគូនៃអរិយធម៌មេមត់, សារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់, រាជបណ្ឌិតសភាកម្ពុជា, ឆ្នាំសិក្សា ២០០០-២០០២, ទំព័ ១៤-១៥។

ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ : ឆ្នាំទី១៨ លេខ១១ ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
Journal of Institute of National Language: Vol.18 No.11 November 2024

ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិគឺជាផ្នែកមួយនៃការផ្សព្វផ្សាយរបស់វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជាក្នុងការលើកកម្ពស់ការសិក្សាស្រាវជ្រាវភាសានិងអក្សរសាស្ត្រខ្មែរឱ្យមានលក្ខណៈស្តង់ដានិងឈានទៅរកការរីកចម្រើនដូចអរិយភាសាក្នុងលោក។

**និពន្ធនាយក**
បណ្ឌិត **មាឃ បូរ៉ា**

**និពន្ធនាយករង**
បណ្ឌិត **ខាត់ មេង**

**ក្រុមការងារ**
មន្ត្រីវិទ្យាស្ថានភាសាជាតិ

**រចនានិងរៀបចំទំព័រ**
បណ្ឌិត **ជុំ ស៊ុនណាង**
លោក **កែវ លីណែត**
លោកស្រី **អ៊ឹង ម៉ាល័យ**

**ទីប្រឹក្សាបច្ចេកទេស**
បណ្ឌិតសភាចារ្យ **ព្រុំ ម៉ល់**
បណ្ឌិតសភាចារ្យ **ខ្លូត ធីតា**
បណ្ឌិតសភាចារ្យ **ច័ន្ទ សំណព្វ**
បណ្ឌិតសភាចារ្យ **ស៊ុំ ឈុំប៊ុន**
បណ្ឌិតសភាចារ្យ **សោម សុមុនី**
បណ្ឌិត **ជួរ គារី**

**ទីប្រឹក្សារដ្ឋបាល**
ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច**
ឯកឧត្តមបណ្ឌិត **យង់ ពៅ**

ព័ត៌មានទស្សនាវដ្ដី
វិទ្យាស្ថានភាសាជាតិ, ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ ឆ្នាំទី១៨ លេខ១១, ខែកត្តិក គ.ស.២០២៤, ភ្នំពេញ : រាជបណ្ឌិត្យសភាកម្ពុជា។

ចេញផ្សាយដោយ : វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា
អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
: ប្រអប់សំបុត្រលេខ៥៣១ ភ្នំពេញ 12406
អ៊ីមែល : inlrac.languages@gmail.com
ទូរសព្ទ : ០១១ ៧១៧ ០១១

ឧបត្ថម្ភការបោះពុម្ពដោយ
បោះពុម្ពដោយ

ភាតិកា
ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ : ឆ្នាំទី១៨ លេខ១១ ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
Journal of Institute of National Language: Vol.18 No.11 November 2024

ទំព័រ

**អារម្ភកថា** ............ ខ

**ការវិវត្តនៃភាសាខ្មែរ (បុរេអង្គរ អង្គរ ក្រោយអង្គរ បច្ចុប្បន្ន)**

បណ្ឌិត មាឃ បូរ៉ា, បណ្ឌិត ជួរ គារី, លោក កែវ លីណែត ............ 1

**ទំនៀមពីបុរាណតាមរយៈសិលាចារឹក**

បណ្ឌិត មាឃ បូរ៉ា ............ 33

**សិលាចារឹកវត្តព្រះពុទ្ធឃោចារ្យ (វត្តចិនដំដែកខាងត្បូង) K. 1213**
**និង ព្រឹត្តិការណ៍មួយចំនួននៅប្រទេសកម្ពុជានាដើមសតវត្សរ៍ទី១៩**

បណ្ឌិត ជុំ ស៊ុនណាង, លោក កែវ លីណែត, លោក វ៉ាន់ ម៉ូន, លោកស្រី អ៊ឹង ម៉ាល័យ ............ 52

**ការបង្កើតកម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេស**

បណ្ឌិត ជុំ ស៊ុនណាង, បណ្ឌិត ណុន សុខា ............ 59

**អក្សរសិល្ប៍ប្រជាប្រិយជនជាតិព័រ**

នាយកដ្ឋានអក្សរសាស្ត្រនិងអក្សរសិល្ប៍ ............ 77

**សាស្ត្រា គោបុត្រ**

បណ្ឌិត ប៊ី សុខគង់, លោក កែវ លីណែត, លោកស្រី អ៊ឹង ម៉ាល័យ ............ 81

# អារម្ភកថា

គំនិតទស្សនៈរបស់អ្នកសិក្សាស្រាវជ្រាវដែលទើបរកឃើញថ្មីគឺសុទ្ធតែមានសារៈសំខាន់នៅក្នុងការរួមចំណែកអភិវឌ្ឍសង្គមជាតិផ្នែកបញ្ញាញាណ។ ថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានភាសាជាតិ(វ.ភ.ជ.) នៃរាជបណ្ឌិត្យសភាកម្ពុជាក៏បានខិតខំសិក្សាស្រាវជ្រាវ វិភាគ ប្រមូលចងក្រងជាឯកសារមួយចំនួនដែលចុះផ្សាយតាមរយៈទស្សនាវដ្ដីរបស់ខ្លួនចំនួន១០លេខនិងលេខពិសេសចំនួន០១លេខរួចមកហើយ។

ទស្សនាវដ្ដីចុះផ្សាយលេខ១១ ឆ្នាំ២០២៤នេះ មានអត្ថបទចម្រុះទាក់ទងភាសា, សិលាចារឹក និង អក្សរសិល្ប៍។ ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិឆ្នាំទី១ លេខ១ ឆ្នាំ២០០០ បានចាប់កំណើតជាដំបូងឡើង ដើម្បីផ្សព្វផ្សាយអត្ថបទទាំងឡាយទាក់ទងជាពិសេស ភាសា សិលាចារឹក អក្សរសិល្ប៍ និងវប្បធម៌។ ជាបន្តបន្ទាប់ គណៈកម្មការទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិនឹងបន្តចុះផ្សាយនូវរាល់អត្ថបទរបស់អ្នកស្រាវជ្រាវទាំងឡាយដែលមានគោលបំណងអភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរនិងផ្ដល់បញ្ញាញាណចូលរួមចំណែកធ្វើឱ្យភាសាខ្មែររីកចម្រើនរឹងមាំលើមូលដ្ឋានវិទ្យាសាស្ត្រ។

យើងខ្ញុំទាំងអស់គ្នាដែលជា ថ្នាក់ដឹកនាំ សហសេវិក និង មន្ត្រី វ.ភ.ជ. សូមរំឭកនឹកគុណឧទ្ទិសទស្សនាវដ្ដី លេខ១១នេះ ជូនចំពោះវិញ្ញាណក្ខន្ធឯកឧត្ដមបណ្ឌិតសភាចារ្យ **ឡុង សៀម**, ឯកឧត្ដមបណ្ឌិតសភាចារ្យ **អ៊ុំ ច័ន** ឯកឧត្ដមបណ្ឌិត **នៅ ស៊ុន** ជាពិសេស និង វរជនអក្សរសាស្ត្រជាតិដទៃទៀត ដែលមានគុណបំណាច់ក្នុងការលើកស្ទួយភាសានិងវប្បធម៌ជាតិខ្មែររៀងមក។

សូមឱ្យព្រះវិញ្ញាណក្ខន្ធ ព្រះមហាវីរក្សត្រ សម្ដេចព្រះសង្ឃរាជ ព្រះសង្ឃគ្រប់ព្រះអង្គ និងវិញ្ញាណក្ខន្ធ កវីនិពន្ធខ្មែរគ្រប់ជំនាន់និងសម័យកាលទាំងអស់ ឆ្ពោះទៅសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

**និពន្ធនាយក**
បណ្ឌិត **មាឃ បូរ៉ា**

នេះជារបស់ចាម។ រីឯលោក **ហ្សក សឺដេស**(Georges Coedès) វិរិយបណ្ឌិតោភិក្ខុ **ប៉ាង ខាត់** បានចាត់ទុកសិលាចារឹកនេះថាជារបស់ខ្មែរ និងជាពិសេស តាមរយៈសៀវភៅ«មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ»របស់បណ្ឌិត **មីសែល ត្រាណេ** បានស្រង់សម្ដីរបស់លោក **ហ្វីលីយ៉ូហ្សា**(Filliozat)បានសិក្សាឡើងវិញនៅឆ្នាំ១៩៦៨ អំពីខ្លឹមសារអត្ថបទសិលាចារឹកវ៉ូកាញ់នេះថា «ពីមុនមានអ្នកស្រាវជ្រាវមួយចំនួននិយាយថាសិលាចារឹកនេះជាកម្មសិទ្ធិរបស់ប្រជាជនចាម តែក្រោយពីការស្រាវជ្រាវដ៏ល្អិតល្អន់ដោយលោក **ហ្វីលីយ៉ូហ្សា**(Filliozat)ទើបយើងដឹងថាជារបស់ខ្មែរ»[2]។

ចំពោះទស្សនៈផ្ទាល់វិញ យើងឯកភាពទៅលើមតិដែលបានអះអាងថា សិលាចារឹកវ៉ូកាញ់នេះជារបស់ខ្មែរ ដូចអ្នកស្រាវជ្រាវមុនៗដែរ ដោយស្នេរឈរលើកត្តាបួន គឺ

- កត្តាភូមិសាស្ត្រ យើងឃើញថា ដែនដីខេត្តញ៉ាត្រាង (វៀតណាមខាងត្បូងសព្វថ្ងៃ) ជាដែនដីអតីតអាណាចក្រភ្នំ,
- ព្រះនាមរបស់ព្រះមហាក្សត្រខ្មែរដែលមានឈ្មោះថា ព្រះបាទ ស្រីមារៈ,
- ខ្មែរទទួលឥទ្ធិពលឥណ្ឌាតាមរយៈសាសនា ទោះបីព្រហ្មញ្ញសាសនា ឬ ពុទ្ធសាសនាក៏ដោយ ក៏សាសនានេះនាំមកទាំងភាសានិងអក្សរ ចូលមកក្នុងអាណាចក្រភ្នំ (ហ្វូណន),
- សិលាចារឹកនេះ ផ្ដល់ជាគំរូតួអក្សរមកសម័យក្រោយៗទៀត។

ទោះបីសិលាចារឹកនេះ សរសេរជាភាសាសំស្ក្រឹតក៏ដោយ ក៏ជាមោទនភាពមួយដែរ ដែលខ្មែរយើងមានតួអក្សរសម្រាប់ប្រើប្រាស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះ សូម្បីតែជនជាតិពុំមានរដ្ឋផងនោះ។

ក្រៅពីសិលាចារឹកវ៉ូកាញ់ បើពិនិត្យទៅលើការចុះបញ្ជីសិលាចារឹករបស់លោក ហ្សក សឺដេស ដែលបានបោះពុម្ពផ្សាយនៅឆ្នាំ១៩៦៦ មានសិលាចារឹកដទៃទៀតដូចជា សិលាចារឹកតាព្រហ្ម(ទន្លេបាទី) K.៤០ ខេត្តតាកែវរបស់ព្រះបាទរុទ្រវរ្ម័ន សរសេរជាភាសាសំស្ក្រឹត, សិលាចារឹកប្រាសាទប្រាំល្វែងK.៥ ខេត្តផ្សារដែក(កម្ពុជាក្រោម)របស់ព្រះបាទគុណវរ្ម័នសរសេរជាភាសាសំស្ក្រឹត, សិលាចារឹកវត្តហ្លួងកៅK.៣៦៥ ខេត្តបាសាក់(Basak) ប្រទេសឡាវសរសេរជាភាសាសំស្ក្រឹត, សិលាចារឹកអ្នកតាដំបងដែកK.៨៧៥ ខេត្តតាកែវ សរសេរជាភាសាសំស្ក្រឹត, សិលាចារឹកវត្តចេតិយ K.៩២៤ ខេត្តឡុងសៀង ប្រទេសវៀតណាម សរសេរជាភាសាសំស្ក្រឹត, សិលាចារឹកស៊ីទេព K.៩៧៥ ខេត្តពិស្ណុលោក ប្រទេសថៃ សរសេរជាភាសាសំស្ក្រឹត ជាដើម។

តាមការការចង្អុលបង្ហាញសិលាចារឹកខាងលើនេះ យើងឃើញថា សិលាចារឹកទាំងនេះ សុទ្ធតែសរសេរជាភាសាសំស្ក្រឹត តែទោះបីសរសេរជាភាសាសំស្ក្រឹតក៏ដោយ ក៏ខ្មែរយើងមានមោទនភាពមួយ ដែលខ្មែរមានតួអក្សរសម្រាប់កត់ត្រាភាសា។

លុះមកដល់ឆ្នាំ៥៣៣នៃមហាសករាជ ត្រូវនឹងថ្ងៃ១៣កើត ខែមាឃ-បុស្ស ឆ្នាំ៦១១នៃគ្រិស្តសករាជ ទើបគេប្រទះឃើញសិលាចារឹកសរសេរជាភាសាខ្មែរដែលប្រើតួអក្សរព្រាហ្មីមុនដំបូងគេនៅវត្តទួលគំនូរក្នុងស្រុកអង្គបុរីខេត្តតាកែវ ដែលបានចុះបញ្ជីសារពើភណ្ឌសិលាចារឹកអង្គបុរីK.៦០០ ហើយដែលចារឡើងក្នុងរាជរបស់ព្រះមហាក្សត្រព្រះបាទមហេន្ទ្រវរ្ម័នទី១។ អត្ថបទសិលាចារឹកនេះ បានរៀបរាប់អំពីបញ្ជីខ្ញុំបម្រើ, ដីធ្លី, គោ, ក្របី

[2]- មីសែល ត្រាណេ : មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ, ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ពខ្មែរ, ឆ្នាំ២០១៣, ទំព័រ១៦៨។

ជាដើម ដែលមន្ត្រីថ្វាយដល់អាទិទេពកម្រតាងអញ មហាគណបតិ (គណេស),ថ្វាយដល់ព្រះវិហារ តំក្រោម (ព្រះវិហារដើមក្រោម ) និង ថ្វាយដល់អាទិទេពមណីស្វរៈ ។

ក៏ប៉ុន្តែ បើយើងសង្កេតទៅលើសិលាចារឹកដែលសរសេរជាភាសាខ្មែរ ដោយប្រើតួអក្សរព្រាហ្មីនេះ ដែលគេបានរកឃើញមានដូចជា សិលាចារឹកវត្តថ្លែងK.១, សិលាចារឹកវត្តពោធិវង្សលើK.១១, សិលាចារឹកអង្គបុរីK.២៥ (តាកែវ), សិលាចារឹកព្រះវិហារធំ(កំពង់ចាម)K.៥២០, សិលាចារឹកទួលវត្តគំនូរ(តាកែវ)K.៥៥៧, សិលាចារឹកទួលអង្គ(តាកែវ)K.៥៥៩ ជាដើម ឃើញថាអក្ខរក្រមមានវ័យចំណាស់ជាងសិលាចារឹកK.៦០០ទៅទៀត គ្រាន់តែសិលាចារឹកទាំងនេះគ្មានចុះកាលបរិច្ឆេទតែប៉ុណ្ណោះ។

ដោយឈរលើមូលដ្ឋាននេះ  គេអាចសន្និដ្ឋានបានថាសិលាចារឹកសរសេរជាភាសាខ្មែរដោយប្រើតួអក្សរព្រាហ្មី អាចចាប់បដិសន្ធិឡើងក្នុងអំឡុងសតវត្សរ៍ទី៥-៦មកម្ល៉េះ។

## ៣- ការវិវត្តនៃភាសាខ្មែរ

ភាសាក៏ជាធាតុមួយនៃវប្បធម៌ អរិយធម៌ដែរ តែងតែមានការប្រែប្រួល រីកចម្រើនឬអន់ថយ និង ស្លាប់ទៅវិញស្របទៅតាមការរស់នៅរបស់សង្គមមនុស្សនិងតាមជាតិសាសន៍នីមួយៗ។

តាមការសិក្សាស្រាវជ្រាវ យើងឃើញថា ភាសាខ្មែរមានការវិវត្តបីដំណាក់កាលធំៗ គឺភាសាខ្មែរ សម័យបុរាណ ភាសាខ្មែរសម័យកណ្តាល និង ភាសាខ្មែរសម័យបច្ចុប្បន្ន។

## ៤- ភាសាខ្មែរសម័យបុរាណ

ភាសាខ្មែរសម័យបុរាណ  គឺគិតចាប់តាំងពីសម័យដែលមានមនុស្សខ្មែររស់នៅតាំងពីដំបូងឡើយរហូតដល់សតវត្សរ៍ទី១៥។ សម័យកាលនេះ គេអាចចែកជាបីដំណាក់កាល គឺ

ក. ភាសាខ្មែរសម័យបុរេប្រវត្តិ ហូតដល់សតវត្សរ៍ទី១

ខ. ភាសាខ្មែរបុរាណសម័យមុនអង្គរ (សតវត្សរ៍ទី១ ដល់ សតវត្សរ៍ទី៨)

គ. ភាសាខ្មែរបុរាណសម័យអង្គរ (សតវត្សរ៍ទី៩ ដល់ សតវត្សរ៍ទី១៥)

## ៥- តារាងអក្សរខ្មែរតាមសម័យកាល

គំរូតារាងសញ្ញាព្យញ្ជនៈនិងស្រៈ សម័យមុនអង្គរ អង្គរ ក្រោយអង្គរ ដូចខាងក្រោម៖

### ៥.១- តារាងព្យញ្ជនៈសម័យមុនអង្គរ[3]

| **ព្យញ្ជនៈខ្មែរ ទំនើប** | Transliteration | **សតវត្សរ៍ទី ៦** |
|---|---|---|
| | | |
| ក្ក | ka |  |
| ខ្ខ | kha |  |
| គ្គ | ga |  |
| ឃ្ឃ | gha |  |

[3]- តារាងព្យញ្ជនៈនេះ គូរដោយ លោក ឡុង សុវណ្ណា និស្សិតសាកលវិទ្យាល័យខេមរៈ ជំនាន់ទី៨ ជាមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា។

| | | |
|---|---|---|
| ង្ង | ṅa |  |
| ច្ច | ca |  |
| ឆ្ឆ | cha | |
| ជ្ជ | ja |  |
| ឈ្ឈ | jha |  |
| ញ្ញ | ña |  |
| ដ្ដ | ṭa |  |
| ឋ្ឋ | ṭha | |
| ឌ្ឌ | ḍa | |
| ឍ្ឍ | dha | |
| ណ្ណ | ṇa |  |
| ត្ត | ṭa |  |
| ថ្ថ | ṭha | |
| ទ្ទ | da |  |
| ធ្ធ | dha |  |
| ន្ន | na |  |
| ប្ប | pa |  |
| ផ្ផ | pha |  |
| ព្ព | ba |  |
| ភ្ភ | bha |  |
| ម្ម | ma |  |
| យ្យ | ya |  |
| រ្រ | ra |  |
| ល្ល | la |  |
| វ្វ | va |  |

| | | |
|---|---|---|
| ស្ស | sa |  |
| ឝ្ឝ | Ça |  |
| ឞ្ឞ | ṣa |  |
| ហ្ហ | ha |  |

### ៥.២- ព្យញ្ជនៈសម័យមុនអង្គរ

| ព្យញ្ជនៈខ្មែរ ទំនើប | Transliteration | សតវត្សទី ៧ |
|---|---|---|
| ក្ក | ka |  |
| ខ្ខ | kha |  |
| គ្គ | ga |  |
| ឃ្ឃ | gha |  |
| ង្ង | ṅa |  |
| ច្ច | ca |  |
| ឆ្ឆ | cha |  |
| ជ្ជ | ja |  |
| ឈ្ឈ | jha |  |
| ញ្ញ | ña |  |
| ដ្ដ | ṭa |  |
| ឋ្ឋ | ṭha |  |
| ឌ្ឌ | ḍa | |
| ឍ្ឍ | dha | |
| ណ្ណ | ṇa |  |

| | | |
|---|---|---|
| ដ្ដ | ṭa |  |
| ឋ្ឋ | ṭha |  |
| ទ្ទ | da |  |
| ធ្ធ | dha |  |
| ន្ន | na |  |
| ប្ប | pa |  |
| ផ្ផ | pha |  |
| ព្ព | ba |  |
| ភ្ភ | bha |  |
| ម្ម | ma |  |
| យ្យ | ya |  |
| រ្រ | ra |  |
| ល្ល | la |  |
| វ្វ | va |  |
| ស្ស | sa |  |
| ឝ្ឝ | Ça |  |
| ឞ្ឞ | ṣa |  |
| ហ្ហ | ha |  |

### ៥.៣- ព្យញ្ជនៈសម័យមុនអង្គរ

| ព្យញ្ជនៈខ្មែរ ទំនើប | Transliteration | សតវត្សរ៍ទី ៨ |
|---|---|---|
| ក្ក | ka |  |
| ខ្ខ | kha |  |
| គ្គ | ga |  |
| ឃ្ឃ | gha |  |
| ង្ង | ṅa |  |
| ច្ច | ca |  |
| ឆ្ឆ | cha |  |
| ជ្ជ | ja |  |
| ឈ្ឈ | jha |  |
| ញ្ញ | ña |  |
| ដ្ដ | ṭa |  |
| ឋ្ឋ | ṭha |  |
| ឌ្ឌ | ḍa | |
| ឍ្ឍ | dha | |
| ណ្ណ | ṇa |  |
| ត្ត | ṭa |  |
| ថ្ថ | ṭha |  |
| ទ្ទ | da |  |

| | | |
|---|---|---|
| ធ្ធ | dha |  |
| ន្ន | na |  |
| ប្ប | pa |  |
| ផ្ផ | pha |  |
| ព្ព | ba |  |
| ភ្ភ | bha |  |
| ម្ម | ma |  |
| យ្យ | ya |  |
| រ្រ | ra |  |
| ល្ល | la |  |
| វ្វ | va |  |
| ស្ស | sa |  |
| ឝ្ឝ | Ça |  |
| ឞ្ឞ | ṣa |  |
| ហ្ហ | ha |  |

## ៥.៤- សញ្ញាស្រៈនិស្ស័យសម័យមុនអង្គរ

| សញ្ញាស្រៈទំនើប | Transliteration | សតវត្សរ៍ទី ៦ |
|---|---|---|
| ា (អា) | ā |  |
| ិ (អិ) | i |  |
| ី (អី) | ī |  |

| | | |
|---|---|---|
| ◌ុ (អុ) | u |  |
| ◌ូ (អូ) | ū |  |
| េ◌ (អេ) | e |  |
| ែ◌ (អែ) | ai |  |
| ោ◌ (អោ) | o |  |
| ៅ◌ (អៅ) | au |  |
| ◌ុំ (អុំ) | oṃ |  |
| ◌ំ (អំ) | aṃ |  |
| ◌ាំ (អាំ) | āṃ |  |
| ◌ះ (អះ) | aḥ |  |
| ◌ុះ (អុះ) | uḥ |  |
| េ◌ះ(អេះ) | eḥ | |
| ោ◌ះ(អោះ) | oḥ |  |

### ៥.៥- សញ្ញាស្រៈសម័យមុនអង្គរ

| សញ្ញាស្រៈ ទំនើប | Transliteration | សតវត្សរ៍ទី៧ |
|---|---|---|
| ◌ា (អា) | ā |  |
| ◌ិ (អិ) | i |  |
| ◌ី (អី) | ī |  |
| ◌ុ (អុ) | u |  |

| | | |
|---|---|---|
| ◌ូ (អូ) | ū |  |
| ◌េ (អេ) | e |  |
| ◌ៃ (អៃ) | ai |  |
| ◌ោ (អោ) | o |  |
| ◌ៅ (អៅ) | au |  |
| ◌ុំ (អុំ) | oṃ |  |
| ◌ំ (អំ) | aṃ |  |
| ◌ាំ (អាំ) | āṃ | |
| ◌ះ (អះ) | aḥ |  |
| ◌ុះ (អុះ) | uḥ |  |
| ◌េះ (អេះ) | eḥ |  |
| ◌ោះ (អោះ) | oḥ |  |

## ៥.៦- សញ្ញាស្រៈសម័យមុនអង្គរ

| សញ្ញាស្រៈទំនើប | Transliteration | សតវត្សរ៍ទី៨ |
|---|---|---|
| ◌ា (អា) | ā |  |
| ◌ិ (អិ) | i |  |
| ◌ី (អី) | ī |  |
| ◌ុ (អុ) | u |  |

| | | |
|---|---|---|
| ◌ូ (អូ) | ū |  |
| េ◌ (អេ) | e |  |
| ែ◌ (អែ) | ai |  |
| េ◌ា (អោ) | o |  |
| េ◌ៅ (អៅ) | au |  |
| ◌ុ◌ំ (អុំ) | oṃ |  |
| ◌ំ (អំ) | aṃ |  |
| ◌ា◌ំ (អាំ) | āṃ | |
| ◌ះ (អះ) | aḥ |  |
| ◌ុ◌ះ (អុះ) | uḥ |  |
| េ◌◌ះ(អេះ) | eḥ |  |
| េ◌ា◌ះ(អោះ) | oḥ |  |

## ៥.៧- តារាងស្រៈនិស្ស័យសម័យអង្គរ[4]




[4] តារាងស្រៈនិស្ស័យនេះផ្ដល់ដោយលោកសាស្ត្រាចារ្យ យាង វីរបុត្រ។

## ៥.៨- តារាងស្រៈពេញតួសម័យអង្គរ[5]




## ៥.៩- អក្ខរក្រមសម័យអង្គរ[6]




---

[5] តារាងស្រៈពេញតួនេះផ្តល់ដោយលោកសាស្ត្រាចារ្យ យ៉ាង វីរបុត្រ ។

[6]- តារាងព្យញ្ជនៈនេះផ្តល់ដោយលោកសាស្ត្រាចារ្យ យ៉ាង វីរបុត្រ ។

ត ta
ថ tha
ទ da
ធ dha
ន na
ប pa
ផ pha
ព ba
ភ bha
ម ma
យ ya
រ ra
ល la
វ va
ឝ śa
ឞ ṣa
ស sa



## ៥.១០- ការវិវត្តអក្ខរាវិរុទ្ធមួយចំនួនតាំងពីសម័យ មុនអង្គរ អង្គរ បច្ចុប្បន្ន

| ល.រ. | អក្ខរាវិរុទ្ធសម័យបច្ចុប្បន្ន | អក្ខរាវិរុទ្ធសម័យអង្គរ | អក្ខរាវិរុទ្ធសម័យមុនអង្គរ |
|---|---|---|---|
| ១ | គោ | ត្មុរ៑ | ត្មុរ៑/ថ្មុរ៑ |
| ២ | អ្នកស្រែ | អ្នក៑ស្រេ | អ្នក៑ស្រេ |
| ៣ | អ្នករបាំ | ម៌ាំ/របាំ | រមំ/របំ |
| ៤ | ពិណ | វីណ | វិណ/វីណ |
| ៥ | ភ្នំ | វ្នំ | វ្នំ |
| ៦ | ត្រពាំង | ត្រវាង៑ | ត្រវង៑/ត្រវាង៑ |
| ៧ | ភ្នែក | វ្នេក៑ | វ្នេក៑ |
| ៨ | ប្រមុះ | ចុង៑មុហ៑ | មុហ៑( មុះ )/ចុង៑មុស៑( ចុង មុះ ) |
| ៩ | ដៃ | តៃ | តៃ |
| ១០ | ជើង | ជេង៑ | ជេង៑ |
| ១១ | ឆ្នាំ | ឆ្នាំ | ច្នំ/ច្នាំ/ឆ្នាំ |
| ១២ | សុវណ្ណ | សុវណ៌្ណ | សុវណ៌្ណ/សុវន្ន៌ |
| ១៣ | ស្រុកក្រៅ | ស្រុក៑ក្រៅ | ស្រុក៑ក្រៅ |
| ១៤ | ស្រែក្រោម | ស្រេក្រាំ | ស្រេក្រាំ |
| ១៥ | ស្រែប្រាំង | ស្រេប្រង៑ | ស្រេប្រង៑ ង |
| ១៦ | ស្លា | ស្លា | ស្លា |
| ១៧ | ដើម | តើំ/តេម៑ | តើំ/តេម៑ |
| ១៨ | ទិញ | ទុញ៑ | ទុញ៑ |
| ១៩ | ចម្រៀង | ចម្រេង៑/ចំរេង៑ | ចម្រេង៑/ចំរេង៑ |
| ២០ | បង្រៀន | បយ៌្យាន៑ | បយ៌្យាន៑ |
| ២១ | ច្បារ | ច្បរ៑/ត្បល៑/ថ្បល៑ | ច្បរ៑/ត្បល៑/ថ្បល៑ |
| ២២ | និព្វាន | និវ៌្វាន/និវ៌្វាណ | និវ៌្វាន/និវ៌្វាណ |
| ២៣ | ក្រមួន | កល្មន៑ | កល្មន៑ |
| ២៤ | | | |
| ២៥ | | | |

គួរកត់សម្គាល់ថា តួព្យញ្ជនៈប្រកបនៅសម័យមុនអង្គរឬសម័យអង្គរ លោកមានប្រើ*វិរាម* (៎) ពីលើ ដើម្បីសម្គាល់ក្នុងការមិនបញ្ចេញសូរអាននូវព្យញ្ជនៈប្រកបចុងព្យាង្គ ខុសពីពាក្យដែលជាភាសាសំស្ក្រឹតឬបាលីដែលមានបញ្ចេញសូរអានលើតួកព្យញ្ជនៈប្រកបចុងព្យាង្គ។

តើយើងអាចយល់បានទេថា *វិរាម* នេះអាចវិវត្តមកជាសញ្ញា*បន្តក់* ឬ*ទណ្ឌឃាត* ដែលសព្វថ្ងៃនេះ យើងប្រើក្នុងបរិបទផ្សេងពីវិរាមសម័យដើម។ សញ្ញាបន្តក់ «់» គឺគេប្រើសម្រាប់កាត់សូរវែងមកសូរខ្លី ដើម្បីសម្គាល់ន័យរបស់ពាក្យនីមួយ ដូចជា ចាន≠ចាន់ មាន≠មាន់ ទាន≠ទាន់ ...ជាដើម។ រីឯ ទណ្ឌឃាត ប្រើសម្រាប់សម្លាប់សូរព្យញ្ជនៈចុងព្យាង្គដែលជាពាក្យក្លាយពីភាសាសំស្ក្រឹតឬបាលីចោលតែម្តង ដូចជា៖

| ពាក្យបាលី | ពាក្យសំស្ក្រឹត | ពាក្យខ្មែរ |
|---|---|---|
| បយោជន | ប្រយោជន | ប្រយោជន៍ |
| អវិរោធន | អវិរោធន | អវិរោធន៍ |
| | ប្រ+ឝាសន | ប្រសាសន៍ |
| អាទិ | អាទិ | អាទិឬអាទិ៍(អា-ទិឬអាត) |
| អចិន្តេយ្យ | អចិន្ត្យ/អចិន្តនីយ | អចិន្ត្រៃយ៍ |
| ...... | ....... | ....... |

ជាដើម។

## ៦- ភាសាខ្មែរសម័យកណ្តាល

ភាសាខ្មែរសម័យកណ្តាលចាប់ពីសតវត្សរ៍ទី១៦ ដល់សតវត្សរ៍ទី១៩។ នៅក្នុងសម័យកាលនេះ ភាសាខ្មែរមានភាពស្មុគស្មាញនិងជួបនូវវិបត្តិជាច្រើន ដោយសារសង្គ្រាមឈ្លានពានពីសំណាក់បរទេស និងសង្គ្រាមក្នុងស្រុកធ្វើឱ្យភាសានិងអក្សរមានការធ្លាក់ដុនដាបយ៉ាងខ្លាំង ការរៀនសូត្រខ្វះឯកភាពគ្នា។ បានសេចក្តីថា ការសិក្សារៀនសូត្រនៅវត្តអារាម និងតំបន់រៀងៗខ្លួន ជាពិសេសនៅក្នុងការចារឬសរសេរ សត្រាមានការសរសេរខុសៗគ្នា។ រហូតមកដល់សម័យបារាំង ភាសាខ្មែរក៏ត្រូវបានធ្លាក់កិត្យានុភាពរបស់ខ្លួនមួយកម្រិតទៀត ហើយបារាំងបង្ខំឱ្យរៀនភាសារបស់គេជាយាន។ ទោះបីយ៉ាងណាក៏ដោយភាសាខ្មែរ អក្សរខ្មែរមិនបានបាត់បង់នូវកិត្យានុភាពឡើយ គឺ បានរក្សាឱ្យនៅគង់វង្ស ដោយការខិតខំប្រឹងប្រែងពីសំណាក់ព្រះសង្ឃនៅតាមវត្តអារាមនានា។

## ៧- ភាសាខ្មែរបច្ចុប្បន្ន

ភាសាខ្មែរបច្ចុប្បន្ននេះអាចចាប់គិតពីចុងសតវត្សរ៍ទី១៩ រហូតមកដល់បច្ចុប្បន្ននេះ ។

### ៧.១-ស្ថានភាពទូទៅនៃភាសាខ្មែរនៅសតវត្សរ៍ទី២០

មានការប្រែប្រួលធំពីរផ្នែកការអប់រំនៅប្រទេសកម្ពុជាទាំងផ្នែកពុទ្ធចក្រនិងអាណាចក្រ។ សាលាបង្រៀនភាសាបាឡីត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩០៤ នៅខេត្តសៀមរាបនិងក្នុងឆ្នាំ១៩១៤ (ឯកសារខ្លះថានៅឆ្នាំ១៩១១) នៅក្រុងភ្នំពេញ។ តាំងពីបុរាណកាលមក ការអប់រំនៅក្នុងសង្គមខ្មែរប្រព្រឹត្តទៅតាមវត្តអារាម។ ទោះរហូតមកដល់សម័យបារាំងចូលមកក៏ការអប់រំបែបនេះនៅតែបន្ត ដែលនៅពេលនោះ គេហៅថា «សាលាវត្ត» សម្រាប់សម្គាល់ការអប់រំដោយព្រះសង្ឃឬអ្នកចេះដឹងខ្មែរនៅតាមវត្តអារាម និង «សាលាកូនកាត់» ឬ «សាលា

បារាំង» គឺជាសាលាបារាំង-ខ្មែរ សម្រាប់សម្គាល់ការអប់រំដោយគ្រប់គ្រងដោយរដ្ឋបាលបារាំង( ជាការអប់រំតាមផ្លូវការរដ្ឋ )។ «សាលាកូនកាត់» ឬ «សាលាបារាំង» បង្កើតឡើងក្នុងឆ្នាំ១៩០៣។

អាណាព្យាបាលបារាំងនៅប្រទេសកម្ពុជាបាននាំយកម៉ាស៊ីនបោះពុម្ពចូលមកប្រទេសកម្ពុជានៅរវាងឆ្នាំ ១៩០៧។ ជនជាតិខ្មែរមួយចំនួនដែលមានទម្លាប់នឹងការអានសាស្ត្រាមានគំនិតបដិសេធចំណេះដឹងដែលបោះពុម្ពលើក្រដាស។ ទោះយ៉ាងណាក្តី យើងក៏សង្កេតឃើញមនុស្សខ្មែរមួយចំនួនមានគំនិតជឿនលឿនមានគំនិតវិទ្យាសាស្ត្រដូចសម័យបច្ចុប្បន្នដែរដូចជា សម្តេចព្រះសង្ឃរាជជួនណាត, សម្តេច ហួត តាត, លោកភិរម្យង៉ុយ ជាដើម។

នាពេលនោះ ស្នាដៃអក្សរសាស្ត្រធំដែលសម្រេចនាពេលនោះគឺ វចនានុក្រមខ្មែរដែលបោះពុម្ពផ្សាយលើកទីមួយឆ្នាំ១៩៣៨។ ប៉ុន្តែ មុននឹងការកកើតជាវចនានុក្រមនេះ គេសង្កេតឃើញមានការតស៊ូព្យាយាមដ៏ខ្លាំងក្លាផ្នែកកម្លាំងប្រាជ្ញាស្មារតីរបស់អ្នកប្រាជ្ញរាជបណ្ឌិតសម័យនោះ។

វចនានុក្រមខ្មែរដំបូងជាស្នាដៃដែលកើតឡើងតាមរយៈគណៈកម្មការតាក់តែងវចនានុក្រមខ្មែរ (គណៈកម្មការនេះកាលនោះ គេហៅថា «ក្រុមជំនុំ»)។ វចនានុក្រមនេះកើតចេញពីអ្នកចេះដឹងខ្មែរដែលចង់ឃើញប្រទេសខ្មែរមានឯកភាពផ្នែកអក្ខរាវិរុទ្ធនិងមានទម្រង់ដូចវចនានុក្រមបណ្ឌិត្យសភាបារាំង។

គណៈកម្មការតាក់តែងវចនានុក្រមខ្មែររបស់រាជការមួយត្រូវបានប្រកាសបង្កើតឡើងតាមព្រះរាជក្រឹត្យថ្ងៃទី៤ខែកញ្ញាឆ្នាំ១៩១៥ក្នុងរាជ្យព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ។ គណៈកម្មការតែងវចនានុក្រមខាងលើមាន ១១រូប( ផ្នែកខាងដើមនៅទំព័រអក្សរ ត នៃវចនានុក្រមខ្មែរដែលបោះពុម្ពគ្រាទី៥ត្រង់ អធិបតីក្រុម ជំនុំ សមាជិកក្រុមជំនុំមាន១៨រូប ដែលលោកបានប្រាប់ថា *តាំងដោយព្រះរាជប្រកាសលេខ៦៧ចុះ ខែសេបតមប្រ៏*( កញ្ញា ) *ឆ្នាំ ១៩១៥និងព្រះរាជប្រកាសតាមលំដាប់មុនក្រោយឱ្យបង្កើតវចនានុក្រមខ្មែរ*) ដែលមានលោក ហ្ស៊ែក សេដែសកាលនៅជាចាងហ្វាសាលាបារាំងចុងបូព៌ាជាអ្នកផ្តួចផ្តើមឱ្យកើតការនេះឡើងនិងព្រមទាំងឆ្លៀតជួយអស់លោកក្នុងក្រុមជំនុំនេះផងដែរ។ ការងារតែងវចនានុក្រមប្រព្រឹត្តទៅនៅព្រះវិហារព្រះកែវមរកត។

ក្រុមជំនុំធ្វើ «វចនានុក្រមខ្មែររបស់រាជការ»នេះ កើតឡើងតាមព្រះរាជប្រកាសលេខ៧៣ ចុះថ្ងៃទី១០ខែសេបតមប្រ៏ ឆ្នាំ១៩២៩ ព្រមទាំងការចាត់ចែងបោះពុម្ពរបស់ព្រះរាជបណ្ណាល័យកម្ពុជា។ ពេលរៀបចំបោះពុម្ពលើកទី១ ត្រូវបានអស់លោកកុង្សីយ៍សនាបតីសម័យនោះ សុំឱ្យដាក់ឈ្មោះថា «វចនានុក្រម ខ្មែរ» ដោយរំលែកជាភាគទី១ភាគទី២វិញ មិនដាក់ថា «វចនានុក្រមខ្មែររបស់រាជការ»ទេ ពីព្រោះវាហាក់ដូចជាបង្ខំគេឱ្យប្រើ។

គួរបញ្ជាក់ថា សុត្តន្តប្រីជា*អ៊ិន* ដែលនៅក្នុងគណៈកម្មការតែងវចនានុក្រម ក្រៅពីជាកវីល្បីឈ្មោះ លោកជាអ្នកបាឡីមួយរូប។ លោកទទួលបន្ទុកស្រាវជ្រាវរកពាក្យណាមាន «រ» ខាងចុង។ ព្រះសីលសំវរ *ហាក់* ធ្វើជាលេខាគណៈកម្មការ។ លោកយកបញ្ជីពាក្យបណ្តោះអាសន្នពីលោក *ស៊ីដែស* មកកត់ត្រាលើក្តារខៀន។ បញ្ជីពាក្យនេះផ្អែកលើវចនានុក្រមរបស់លោក *អៃម៉ូនីយេរ*( E. Aymonier ) និងព្រះសង្ឃគ្រិស្តសាសនាព្រះនាម *ហ្គេដុង* ( Guesdon )។ មេពាក្យត្រូវបានបន្ថែមដោយគណៈកម្មការ ជាពិសេសដោយសុត្តន្តប្រីជា*អ៊ិន* ។

ក្រោយមក មានបញ្ហាមួយចំនួនបានកើតឡើង។ បញ្ហាខ្វែងគំនិតគ្នានេះកើតឡើងពី :

១- ការបង្កើតសញ្ញា «សង្កត់» ឬ «ក្បៀស»

២- ការបង្កើត «សំយោគសញ្ញា»

៣- ការបង្កើតសញ្ញា «អឌ្ឍចន្ទ»។

ដំណើរការបោះពុម្ពវចនានុក្រមត្រូវផ្អាកក្នុងឆ្នាំ១៩២៦ជាមួយនឹងព្រះរាជប្រកាស១៩កក្កដា១៩២៦ បង្កើតគណៈកម្មការមួយថ្មី។ គណៈកម្មការថ្មីនេះមាន១១រូប។ ជាចុងក្រោយឆ្លងកាត់ការព្យាយាម បញ្ហាបច្ចេកទេសនិងភាពខ្វែងគំនិតខ្លះ វចនានុក្រមខ្មែរដំបូងបានលេចជារូបរាងក្នុង ព.ស.២៤៨១ ត្រូវនឹងឆ្នាំ១៩៣៨។

ការបោះពុម្ពវចនានុក្រមខ្មែរលើកទី៤(១៩៦២)មានការកែប្រែអក្ខរាវិរុទ្ធមួយចំនួន(ក្នុងទំព័រញ)ដូចជា៖

កែះ *កិ.* កែជា កេះ, គួរ *ន.* (ស្រូវ) ជា កួរ (កួរស្រូវ), ចង្កើះ កែជា ចង្កឹះ, ឆ្កឹះឬឆ្កើះលុប ឆ្កើះ ទុក ឆ្កឹះ, ញាតស្បាត កែជា ញៀតស្បាត, ដំនៀល កែជា ដំណៀល, ....។

ការបោះពុម្ពវចនានុក្រមខ្មែរទាំងពីរភាគលើកនេះ(គ្រាទី៥) មានការកែប្រែច្រើនតាមសម័យកាល។ ក្រៅពីប្រាប់លក្ខណៈរបស់មេពាក្យ ប្រភពពាក្យ សូរអាន ក្រុមជុំនុំក៏បានលុបអក្សរសំស្រ្កឹតមួយចំនួន ដែលដោយជំនួសដោយអក្សរ ស វិញ។ អក្សរសំស្រ្កឹតទាំងនោះមាន« ឞ ឝ »ក្រៅពីនោះ លោកបាន រៀបចំតួអក្សរពីក ដល់ឡ និងជា៣៣តួ ជាមួយនឹងតួ អ និង ស្រៈនិស្ស័យ២១តួ។

ស្នាដៃអក្សរសាស្ត្រលេចធ្លោមួយទៀតនៃសតវត្សរ៍ទី២០គឺការងារប្រែគម្ពីរព្រះត្រៃបិដកពីភាសាបាលីមកជាភាសាខ្មែរដែលជាលទ្ធផលនៃការងារមួយក្នុងរយៈពេល៤០ឆ្នាំ(១៩២៩-១៩៦៨)។ គម្ពីរនេះមានចំនួន ១១០ភាគ។ គ្រប់ភាគនីមួយៗមាន២ផ្នែកគឺ ផ្នែកខាងឆ្វេងជាភាសាបាលីផ្នែកខាងស្តាំជាសេចក្តីប្រែសម្រាយជាភាសាខ្មែរ។

**អំពីការកែប្រែអក្ខរាវិរុទ្ធ**

បន្ទាប់ពីទទួលការតែងតាំងជាគណៈកម្មការឆ្នាំ១៩១៥ មានការកែប្រែអក្ខរាវិរុទ្ធមួយចំនួន ដែលពីមុនមកសរសេរមិនទាន់រៀបរយល្អ ដូចជា៖

«ឱ» ប្រកបថា «ឧក» បើសរសេរ «ឱញ៉ា, ឯឱ» តែគណៈកម្មការបានប្តូរសរសេរជា «ឧកញ៉ា, ឯកឧក» ដូចអក្ខរាវិរុទ្ធសព្វថ្ងៃនេះ។ ពាក្យ «ឪ» ដែលយកអក្សរ វ ដាក់ពីលើ ឧ ជាតួប្រកបឱ្យមានសំឡេង ជា /ឧវ/ ឬ /អុវឬអូវ/ ត្រូវរក្សាទុកដដែល តែសម្រាប់ប្រើ ក្នុងពាក្យ « ឪ, ឪពុក, ឪទិន, ឪម៉ាល់,...», ឱ

សូមបញ្ជាក់ថា តាំងពីមានព្រះរាជប្រកាសតែងតាំងគណៈកម្មការតែងវចនានុក្រមលើកដំបូង នាឆ្នាំ ១៩១៥ មកដល់ឆ្នាំ១៩៦៨ វចនានុក្រមខ្មែរបានបោះពុម្ពចំនួន៥លើក៖

លើកទីមួយ នៅឆ្នាំ១៩៣៨ - ១៩៤៣(ព.ស.២៤៨១- )មានមេពាក្យ ៩ ៦៤១ ពាក្យ

លើកទីពីរ នៅឆ្នាំ១៩៥១

លើកទីបី នៅឆ្នាំ...........?

លើកទី៤ នៅឆ្នាំ១៩៦២

លើកទីប្រាំ នៅឆ្នាំ១៩៦៧ - ១៩៦៨(ព.ស.២៥១១-១២) មានមេពាក្យជាង១ ៨០០ពាក្យ។

### ៧.២- គណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្មសិក្សា[7]

គណៈកម្មាធិជាតិអចិន្ត្រៃយ៍នៃខេមរយានកម្មសិក្សាបង្កើតឡើងតាមរយៈសមាជជាតិលើកទី២៣ នាថ្ងៃទី១០ដល់ថ្ងៃទី១៣ខែកក្កដាឆ្នាំ១៩៦៧ដែលសម្រេចឱ្យប្រើភាសាខ្មែរជាទូទៅក្នុងកិច្ចការរដ្ឋបាលនិងការសិក្សា។ ក្នុងសម័យប្រជុំថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧ អ្នកទទួលខុសត្រូវខាងអប់រំនៃក្រសួងអប់រំជាតិ បានសម្រេចឱ្យអនុវត្តខេមរយានកម្មគ្រប់មុខវិជ្ជានៅមធ្យមសិក្សានៅថ្នាក់ទី៦ ចាប់ពីឆ្នាំ១៩៦៧-៦៨តទៅ។ មកដល់ថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៦៧ ក្រសួងអប់រំជាតិបានចេញលិខិតបង្គាប់ការលេខ៥០៦កន. បង្កើតគណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្មសិក្សា[8]។ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៦៧ ក្រសួងអប់រំជាតិបានចេញប្រកាសលេខ២២៩៤ បញ្ជាឱ្យអនុវត្តខេមរយានកម្មក្នុងមធ្យមសិក្សាដោយចាប់ផ្តើមពីថ្នាក់ទី៦ ចាប់ពីបវេសនកាលសិក្សាឆ្នាំ១៩៦៧-៦៨ តទៅ។

- **ដំណាក់កាលទី១ ចាប់ពីឆ្នាំ១៩៦៧ ដល់មុនឆ្នាំ១៩៧០** (អ្នកខ្លះថារហូតដល់ឆ្នាំ១៩៧២)

នៅក្នុងអារម្ភកថាសទ្ទានុក្រមខេមរយានកម្ម បារាំង-ខ្មែរដែលបោះពុម្ពលើកទីមួយ ..ដោយសារផលនៃឯករាជ្យជាតិ ភាសាខ្មែរយើងទើបបានស្គាល់សន្ទុះថ្មីមួយ។ ដោយសារព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះប្រមុខរដ្ឋ សមាជជាតិលើកទី២៣ បានសម្រេចឱ្យប្រើភាសាខ្មែរជាផ្លូវការក្នុងកិច្ចការរាជការនិងក្នុងសាលារៀន។ ....

ដើម្បីបង្កើតពាក្យឬប្រែពាក្យខ្មែរ អង្គការខេមរយានកម្មបានប្រកាន់ខ្ជាប់នូវគោលការណ៍ធំៗបី៖

ទី១- យើងប្រែឬបង្កើតពាក្យតាមមូលដ្ឋានខ្មែរសុទ្ធសាធ

ទី២- កាលបើយើងរកពាក្យក្នុងប្រភពទីមួយនេះពុំបាន យើងត្រូវងាកទៅរកពាក្យបាលីសំស្ក្រឹតងាយៗខ្លះមកបង្គ្រប់។

ទី៣- ពាក្យបច្ចេកទេសអន្តរជាតិយើងទុកដដែល។[9]

ធ្វើបែបនេះ ទើបភាសាខ្មែរវិវត្តទៅដោយពុំឃ្លាតចាកពីគន្លងជាតិខ្លាំងផង ហើយមានលក្ខណៈវិទ្យាសាស្ត្រគ្រប់គ្រាន់ទាន់សម័យផង។

លោក ហង្ស ធន់ហាក់ ប្រធានគណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្មសិក្សា

ដោយក្រសួងអប់រំជាតិបានសម្រេចទុកសម្តេចព្រះសង្ឃរាជ ជួន ណាតនិងព្រះពោធិវង្សជាកំពូល

---

[7]ឈ្មោះនេះយោងតាមអារម្ភកថាសទ្ទានុក្រមបារាំងខ្មែរ ការផ្សាយចេញពីគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ ឆ្នាំ១៩៦៩។ ឯកសារមួយចំនួនយើងទទួលបានពីឯកឧត្តម សូ មុយឃៀង : ២៥ សីហា ២០០០។

[8]ស្ថានភាពខេមរយានកម្ម នៅមធ្យមសិក្សា ឆ្នាំ១៩៧២។

[9]អារម្ភកថាសទ្ទានុក្រមបារាំងខ្មែរ ការផ្សាយចេញពីគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ ឆ្នាំ១៩៦៩។

ក្នុងការអារកាត់រឿងសព្វសារពើដែលទាក់ទងនឹងខេមរយានកម្ម[10]។

ដំណាក់កាលទី១នេះ គណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្មសិក្សាបានបោះពុម្ពសទ្ទានុក្រម បារាំង-ខ្មែរ ដោយប្រមូលពាក្យបច្ចេកទេសបានចំនួន ៦ ០៣៦ពាក្យ។ សមិទ្ធផលឆ្នាំទីមួយនេះកើតឡើងដោយសារព្រះរាជូបត្ថម្ភដ៏ថ្លៃថ្លា នៃសម្តេចព្រះសង្ឃរាជគណៈមហានិកាយនិងសម្តេចព្រះពោធិវង្ស ជាសក្ខីភាពនៃសេចក្តីប្រឹងប្រែងរបស់គណៈកម្មការបច្ចេកទេសនានាក្នុងអង្គការខេមរយានកម្ម...[11]។ យើងសង្កេតឃើញថាការបោះពុម្ពសទ្ទានុក្រមរបស់គណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្មសិក្សា លើកទីមួយនេះ អក្ខរាវិរុទ្ធពុំបានធ្វើអ្វីឱ្យប្លែកពីវចនានុក្រមខ្មែរប៉ុន្មានឡើយ។

- **ដំណាក់កាលទី២ ចាប់ពីឆ្នាំ១៩៧០ ដល់ ១៩៧៥**

ដោយសារសង្គ្រាម(រដ្ឋប្រហារឆ្នាំ១៩៧០) និង ការសោយទិវង្គតរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ក្នុងឆ្នាំ១៩៦៩ លោក ឡុច ផ្លែង ប្រធានគណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្ម គ្មានវត្តមានសម្តេចព្រះសង្ឃរាជ ជួន ណាត ទៀតទេ តែមានវត្តមានសម្តេចព្រះសង្ឃរាជ ហួត តាត ជាប្រធានគណៈកម្មការវប្បធម៌។ ក្នុងដំណាក់កាលទីពីរនេះ គណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្មបាន កែសម្រួលពាក្យច្រើន ដែលគណៈកម្មការអនុម័តពាក្យមាននាទីប្រែនិងអនុម័តពាក្យតាមសេចក្តីពន្យល់ និងតាមសំណើរបស់តំណាងគណៈកម្មការបច្ចេកទេសនីមួយៗ។ ជំនាន់នោះ គណៈកម្មការបច្ចេកទេស ប្រែពាក្យបរទេសចេញជាន័យសេចក្តីខ្មែរត្រង់ៗ តាមមុខវិជ្ជានីមួយៗឬក៏រក្សាទុកសូរបរទេសដដែលគ្រាន់តែសម្រួលសំណេរតាមបែបខ្មែរ។ ក្នុងករណីនេះ គណៈកម្មការអនុម័តពាក្យបានបង្កើតគោលប្រែពាក្យជាច្រើន ដើម្បីរកឯកភាពខាងន័យនិងខាងសំណេរ។ ជាទូទៅគេច្រើនប្រើ *វិធីធ្នូល* ចំពោះពាក្យប្រែចេញ តាមន័យ ដើម្បីចៀសវាងពាក្យឃ្លា(ពាក្យដែលមានលក្ខណៈដូចជាឃ្លាមួយ) ដូចជាពាក្យដែលមានដាក់ «ការ សេចក្តី អ្នក ប្រដាប់»នៅពីមុខជាដើម លើកលែងតែពាក្យដែលធ្នូលទៅមិនកើតនោះចេញ។

ឧទាហរណ៍៖

Classement ប្រែថា *ចំណាត់ថ្នាក់* មិនប្រែថា *ការចាត់ថ្នាក់* ទេ

Besion ប្រែថា *តំរូវការ* មិនប្រែថា *សេចក្តីត្រូវការ* ទេ

Mort-né ប្រែថា *ខ្ទើតស្លាប់* មិនប្រែថា *អ្នកកើតស្លាប់* ទេ

Reptile ប្រែថា *លូន* មិនប្រែថា *សត្វលូន* ទេ

..........

ចំពោះពាក្យខ្លះដែលមិនប្រែគណៈកម្មការនេះគ្រាន់តែសម្រួលសូរនិងសំណេរខ្លះតាមលក្ខណៈខ្មែរ ដោយបង្កើតគោលទុកជាមូលដ្ឋានខ្លះ ដោយសម្រួលមិនទុកដូចជាសូរ ហ្គ ហ្វ ហ្ស ដើម្បីសម្គាល់សំឡេង gue fe phe je che នោះទេ តែគណៈកម្មាធិការខេមរយានកម្មទីពីរនេះប្រើអក្សរ ក គ ផ ភ ស ស៊ ច ជ ជំនួសវិញ។ ធ្វើយ៉ាងនេះដើម្បីចៀសវាងការបង្កើតសញ្ញាថ្មីបន្ថែមលើតារាងព្យញ្ជនៈខ្មែរដែលមានច្រើនលើសលប់ណាស់ទៅហើយ។

---

[10]ទស្សនាវដ្តីខេមរយានកម្មក្នុងការសិក្សាឆ្នាំទី១ លេខ៦ ឆ្នាំ១៩៦៧ ទំព័រ៤។

[11]អារម្ភកថាសទ្ទានុក្រមបារាំងខ្មែរ ការផ្សាយចេញពីគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ ឆ្នាំ១៩៦៩។

ឧទាហរណ៍៖

| | | | | |
|---|---|---|---|---|
| Chicago | សរសេរ | ស៊ីកាកូ | មិនសរសេរ | ស៊ីកាហ្គោឬស៊ីកាគោ ទេ |
| De Gaulle | សរសេរ | ដឺកូល | មិនសរសេរ | ដឺហ្គោលឬដឺគោល ទេ |
| Asie | សរសេរ | អាស៊ី | មិនសរសេរ | អាហ្ស៊ី ទេ |
| Oxygène | សរសេរ | អុកស៊ីសែន | មិនសរសេរ | អុកស៊ីហ្សែន ទេ |
| Rèflexe | សរសេរ | រេផ្លិច | មិនសរសេរ | រេហ្វ្លិច ទេ |

ពាក្យអនុម័តរួចត្រូវបានបញ្ជូនទៅសុំសេចក្ដីយល់ព្រមពីសម្ដេចព្រះសង្ឃរាជ ហួត តាត ដើម្បីផ្សាយនិងឱ្យប្រើជាផ្លូវការ។ ស្របនឹងសហប្រតិបត្តិការយ៉ាងសកម្មពីសម្ដេចព្រះសង្ឃរាជនេះ ព្រះកិត្តិវិរិយ បណ្ឌិតោ ប៉ាង ខាត់ ដែលជាប្រធានចម្រុះខាងភាសាខ្មែរ ក៏បានចំណាយពេលជួយតម្រែតម្រង់គោល ប្រែពាក្យនៅជំនាន់នោះយ៉ាងច្រើនសន្ធឹកដែរ។

តាមកំណត់ហេតុចម្រុះខាងភាសាខ្មែរដែលមានសមាជិកមកពីវិទ្យាស្ថានជាតិខេមរយានកម្ម វិទ្យាស្ថានខ្មែរ-មន និងមកពីគណៈកម្មការវប្បធម៌(សម្ដេចព្រះសង្ឃរាជ ហួត តាត ជាប្រធានគណៈ កម្មការវប្បធម៌) កាលពីពេលប្រជុំថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៧២ បានកត់ត្រាត្រង់«បញ្ហារាយព្យាង្គ»ទុក មកថា *«អង្គប្រជុំសម្រេចឱ្យសរសេរជាព្យាង្គរាយ តាមធម្មតាតទៅទៀត ដូចជា សំណង់ តំលៃ កំសាន្ត លំអ បំពេញ បំព្រាង បំភ្លេច បំផ្លាញ តំរួត តំរង់ ទំលាប់ ...»* ។ សៀវភៅខេមរយាកម្មបារាំង-ខ្មែរ បោះពុម្ព ផ្សាយកាលឆ្នាំ១៩៧៣ បានអនុវត្តយ៉ាងខ្ជាប់ខ្ជួន តាមសេចក្ដីសម្រេចនេះ[12]។

### ៧.៣-ភាសាខ្មែរក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩

បញ្ញវន្តជាតិតាមជំនាញវិជ្ជាជីវៈ នៅរស់សល់ពីការកាប់សម្លាប់តិចតួចបំផុត ជាពិសេស បញ្ញវន្តជាតិខាងវិស័យអក្សរសាស្ត្រខ្មែរ អស់លោកដែលនៅរស់រានមានជីវិត លោកខិតខំបំពេញភារកិច្ចដ៏ធំធេងនេះ ដើម្បីកូនខ្មែរបានសិក្សារៀនសូត្របន្ត។

*«ក្រោយថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ការសិក្សាអប់រំបានរស់ឡើងវិញ ក្រសួងអប់រំបានបន្តស្នាដៃ ខេមរយានកម្មតមកទៀត ពីបឋមសិក្សាដល់ឧត្ដមសិក្សា ដោយយកសៀវភៅសិក្សាគ្រប់មុខវិជ្ជារបស់ខេមរយានកម្មមកប្រើជាគោលយកពាក្យខេមរយានកម្មមកប្រើជាគន្លឹះ យកលទ្ធផលស្រាវជ្រាវខ្លះៗមកអនុវត្ត ដើម្បីនិរន្តរភាពនៃការសិក្សាអប់រំនិរន្តរភាពនៃភាសាជាតិពីសម័យខេមរយានកម្មមក។ តែ"ប្រាជ្ញាញាណ" របស់ខេមរយានកម្មខ្លះនៅលើក្រដាសនៅឡើយទេ»*[13]។

ក្នុងកាលៈទេសៈដ៏លំបាកនោះ ពួកអស់លោកបានបន្តវេនពីខេមរយានកម្ម ដោយយកក្បួនខ្នាតពីអង្គការជាតិមួយនេះមកអនុវត្តបន្តរហូតមកដល់ពេលមួយ(១៩៩៦-២០១០?)ដែលវិទ្យាស្ថាភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជាធ្វើសន្និសីទជាតិចំនួនបីដងដើម្បីបង្កើតឡើងនូវគណៈកម្មាធិការជាតិភាសាខ្មែរនិងប្រែក្លាយមកជាក្រុមប្រឹក្សាជាតិភាសាខ្មែរ។

[12]អត្ថបទ សាស្ត្រាចារ្យ សូ មុយឃៀង ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៥។
[13]អត្ថបទ សាស្ត្រាចារ្យ សូ មុយឃៀង ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៥។

## ៧.៤- វិទ្យាស្ថានភាសាជាតិ

ក្រោយពេលប្រទេសជាតិមានឯកភាព បង្រួបបង្រួមជាតិ ទទួលបានសុខសន្តិភាពពេញលេញ បញ្ញវន្តខ្មែរដែលរស់នៅក្រៅស្រុកជាយូរមកហើយនោះ ក៏បានចូលមករួមចំណែកកសាងជាតិឡើងវិញជាមួយរាជរដ្ឋាភិបាលតាមឯកទេសរបស់ខ្លួនរៀងៗខ្លួន ក្នុងចំណោមនោះលោក ឡុង សៀម ដែលជាបណ្ឌិតភាសាវិទ្យាបានអញ្ជើញមកពីប្រទេសរុស្ស៊ី រួមនឹងបញ្ញវន្តនិងឥស្សរជនជាន់ខ្ពស់នានានៅក្នុងប្រទេសដែលស្នេហាអក្សរសាស្ត្រខ្មែរបានរួបរួមគ្នាបង្កើតឱ្យមានវិទ្យាស្ថានភាសាជាតិនេះឡើង។

វិទ្យាស្ថានភាសាជាតិ ជាគ្រឹះស្ថានសាធារណរដ្ឋបាល បង្កើតឡើតតាមរយៈអនុក្រឹត្យលេខ៤៥ អនក្រ.បក.ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៩៨។ វិទ្យាស្ថាននេះមានអាណាព្យាបាលបច្ចេកទេសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកផ្នែកសកម្មភាពនៃវិទ្យាស្ថាននិងអាណាព្យាបាលហិរញ្ញវត្ថុរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លោកបណ្ឌិតសភាចារ្យ ឡុង សៀម ជាប្រធានវិទ្យាស្ថាន។ តាមមាត្រាបីនៃការបង្កើតវិទ្យាស្ថាននេះមានបេសកកម្មសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយនិងអភិវឌ្ឍភាសាខ្មែរ (មានភារកិច្ច៨ចំណុច)។

ចាប់ពីថ្ងៃទី៧ដល់ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០០ វិទ្យាស្ថានភាសាជាតិបានចាប់ផ្ដើមធ្វើសន្និសីទជាតិ លើកដំបូង ស្ដីពី«ការស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាខ្មែរ» ដែលមានវាគ្មិនជាតិនិងអន្តរជាតិចូលរួមចំនួន២៦រូប ក្នុងនោះវាគ្មិនអន្តរជាតិចំនួន៤រូប មានអ្នកចូលរួមចំនួនជាង៦០០នាក់ និង ទទួលបានអនុសាសន៍ចំនួន២២ ក្នុងនោះមានសំណូមពរឱ្យរាជរដ្ឋាភិបាលបង្កើតគណៈកម្មការភាសាជាតិមួយដែលមានអនុគណៈកម្មការផ្សេងៗឱ្យចូលរួមគ្រប់និន្នាការ។

សន្និសីទជាតិលើកទី២ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៥ វិទ្យាស្ថានភាសាជាតិបានធ្វើសន្និសីទជាតិស្ដីពី«ការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ» មានវាគ្មិនចំនួន១៨រូប មានអ្នកចូលប្រមាណ ២០០នាក់និងទទួលបានអនុសាសន៍ចំនួន២២ដែរ ក្នុងនោះក៏មានសំណើឱ្យរាជរដ្ឋាភិបាលបង្កើតគណៈកម្មការភាសាជាតិមួយដើម្បីស្វែងរកឯកភាពខាងភាសាជាតិ ឆ្លើយតបទៅនឹងអនុសាសន៍នោះ ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី សុខ អាន លោកបានសន្យាថានឹងជួយជំរុញឱ្យមានគណៈកម្មាធិការជាតិមួយខាងភាសា។

សន្និសីទជាតិលើកទី៣ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៦ វិទ្យាស្ថានភាសាជាតិបានធ្វើសន្និសីទជាតិស្ដីពី «ការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ភាសាខ្មែរ» មានវាគ្មិនចំនួន១១រូប ស្រង់អនុសាសន៍បានចំនួន៧ក្នុងនោះក៏មានសំណើឱ្យរាជរដ្ឋាភិបាលបង្កើតគណៈកម្មការភាសាជាតិមួយដើម្បីស្វែងរកឯកភាពខាងភាសាជាតិ។

## ៧.៥- ក្រុមប្រឹក្សាជាតិភាសាខ្មែរ(អតីតគណៈកម្មាធិការជាតិភាសាខ្មែរ)

មកដល់ថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ១៨ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ ដែលមានសមាជិកជាឥស្សរជនអញ្ជើញមកពីគ្រប់ក្រសួង និងតំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សមាគមអ្នកនិពន្ធខ្មែរ។ល។ ចំនួន៣៦រូប ដែលមានឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រីជាប្រធាន, ឯកឧត្ដមសាស្ត្រាចារ្យ បណ្ឌិត **ឡុង សៀម** អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជានិងជាប្រធានវិទ្យាស្ថានភាសាជាតិ (១៩៩៦-២០០៧)ជាអនុប្រធានអចិន្ត្រៃយ៍, ឯកឧត្ដមសាស្ត្រាចារ្យបណ្ឌិត **ថ្មុំ ម៉ល់** ទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកផ្នែកភាសាវិទ្យា អនុ-

ប្រធាន, អគ្គលេខាធិការ១រូប អគ្គលេខាធិការរង១រូប, ទីប្រឹក្សា៤រូប, សមាជិក សមាជិកា២៥រូប និងលេខាធិការ ៣រូប។

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ គណៈកម្មាធិការជាតិភាសាខ្មែរបានបើកសម័យប្រជុំពេញអង្គរបស់ខ្លួននៅបន្ទប់លេខ១៥បេជាន់ទីមួយនៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលជាប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ។

មកដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៧៩២ អនក្រ.តត ស្តីពីការកែសម្រួលសមាសភាពនៃគណៈកម្មាធិការជាតិភាសាខ្មែរដែលមាត្រា១ ចំណុចមួយ ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ភ្នំ ម៉ល់** ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកភាសាវិទ្យានៅរាជបណ្ឌិត្យសភាកម្ពុជានិងអនុប្រធាននៃគណៈកម្មាធិការជាតិភាសាខ្មែរ ជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិភាសាខ្មែរ ជំនួសឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឡុង សៀម** ដែលបានទទួលមរណភាព។ ចំណុច២ ឯកឧត្តម **ឈន អឿម** សមាជិកគណៈកម្មាធិការជាតិភាសាខ្មែរ ជាអនុប្រធាននៃគណៈកម្មាធិការជាតិភាសាខ្មែរ ជំនួសឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត **ភ្នំ ម៉ល់** ដែលត្រូវទទួលភារកិច្ចថ្មី។

នៅក្នុងអារម្ភកថានៃព្រឹត្តិបត្រគណៈកម្មាធិការជាតិភាសាខ្មែរលេខ២ ឆ្នាំ២០០៩ បណ្ឌិត **ភ្នំ ម៉ល់** បានសរសេរគោលមាគ៌ារបស់គណៈកម្មាធិការជាតិភាសាខ្មែរ(គ.ជ.ភ.ខ.) ដូចខាងក្រោមនេះ៖

*«ដូចវិស័យឯទៀតៗដែរ អក្សរសាស្ត្រខ្មែរ ជាពិសេសភាសាខ្មែរ បានទទួលផលប៉ះពាល់ខ្លាំងពីសង្គ្រាមស៊ីវិលដែលប្រទេសកម្ពុជាបានឆ្លងកាត់អស់ជាច្រើនទសវត្សរ៍។ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ តាមអនុក្រឹត្យលេខ១៨អនក្រ.បក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ ឱ្យរកឯកភាពជូនភាសាយើងវិញ។*

*កង្វះឯកភាពមាន៖*

- *កង្វះឯកភាពក្នុងការសរសេរពាក្យ;*
- *កង្វះឯកភាពក្នុងការអានពាក្យ;*
- *កង្វះឯកភាពក្នុងការបង្កើត/ការប្រើពាក្យ;*
- *កង្វះឯកភាពក្នុងកម្ចីពាក្យពីក្រៅ។*

*ដើម្បីរកឯកភាពក្នុងការសរសេរពាក្យនិងក្នុងការអានពាក្យ គ.ជ.ភ.ខ.បានអនុម័តយកវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ គ្រាទី៥ជាគោល។ ដោយសារការស្រុះស្រួលមូលមតិគ្នាយកវចនានុក្រមនេះជាគោល ការសរសេរពាក្យនិងការអានពាក្យ ត្រូវបានដោះស្រាយស្រេចបាច់នៅថ្នាក់លើ ប៉ុន្តែ គ.ជ.ភ.ខ.ត្រូវរៃយ៉ាងណាឱ្យការអនុវត្តធ្លាក់ដល់ថ្នាក់មូលដ្ឋាន : នេះជាភារកិច្ចដែលគ.ជ.ភ.ខ. ត្រូវធ្វើតរៀងទៅ រហូតដល់មានការអនុវត្តទូទាំងប្រទេស។*

*នៅពេលដែលសម្តេចព្រះសង្ឃរាជកំណត់អក្ខរាវិរុទ្ធ ព្រះអង្គបានជួបនឹងការសរសេរពាក្យប្លែកៗគ្នា ទាក់ទងនឹងពាក្យជាច្រើន ដូច្នេះ ព្រះអង្គបានបង្ហំព្រះទ័យធ្វើសម្បទានមួយចំនួន ទុកឱ្យគេសរសេរពាក្យខ្លះបានពីរ/បីបែប គ្រាន់តែបង្ហាញឱ្យដឹងថា ការសរសេរបែបណាជាការសមស្រប ហើយបានបញ្ជាក់ថា « ត្រូវទុកឱកាសឱ្យគេទៅសិនចុះ(...)យូរៗទៅគង់តែនឹងប្រើតាមទាំងអស់គ្នាឯងៗទៅទេ(និទាន,”ថ្ងៃទី១០ ធ្នូ ១៩៦៧ (ព.ស.*

*២៥១១)", ទំព័រយ)។ ក្នុងសម្រង់ពាក្យក្លាយសរសេរជាព្យាង្គតម្រួត ដែលយើងចុះផ្សាយក្នុងព្រឹត្តិបត្រលេខ២ នេះ មានពាក្យមួយចំនួនត្រូវបានសម្ដេចព្រះសង្ឃរាជ អនុញ្ញាតឱ្យសរសេរជាព្យាង្គរាយផងដែរ។ ក្រៅពីនេះ ពាក្យមួយចំនួនទៀតក៏បានទទួលការសរសេរជាពីរបែបដែរ ដូច : ស្រឡាប/ស្រលាប, ស្រឡះ/ស្រលះ, បាឡី/បាលី, ចៀស/ជៀស....។ កាលគាត់នៅរស់នៅឡើយ លោកសាស្ត្រាចារ្យបណ្ឌិត ឡុង សៀម តែងមានប្រសាសន៍ថាភាសាខ្មែរគួរឈានទៅរកដំណាក់កាលដែលពាក្យនីមួយៗសរសេរបានតែមួយបែប ដូចអរិយភាសាក្នុងលោកដែរ។ ជាងសែសិបឆ្នាំក្រោយពីសម្ដេចព្រះសង្ឃរាជ "ទុកឱកាសឱ្យគេទៅសិនចុះ" គ.ជ.ភ.ខ. គួរធ្វើឱ្យបានសម្រេចនូវគោលបំណងនេះ (ដែលជាគោលបំណងរបស់ព្រះអង្គផង និង គោលបំណងរបស់ភាសាវិទូធំម្នាក់ដែលស្រឡាញ់ភាសាខ្មែរផង) នៅពេលអនាគតដ៏បង្គួរមួយ ដោយបន្តកិច្ចការរបស់ព្រះអង្គ និង ដោយផ្អែកលើបញ្ញាញាណនិងលើសុភនិច្ឆ័យ។*

*ការអនុម័តយកវចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជជាមូលដ្ឋាន អាចឱ្យយើងសរសេរពាក្យនិងអានពាក្យត្រូវគ្នាស្ទើរតែទាំងអស់*[14]*(លើកលែងតែករណីបន្ទាប់បន្សំមួយចំនួន)។ គ.ជ.ភ.ខ.ចង់ឱ្យអ្នកស្រឡាញ់ភាសាជាតិទិញវចនានុក្រមនេះដាក់ផ្ទះរបស់ខ្លួនឱ្យបានគ្រប់គ្នា ហើយឱ្យឧស្សាហ៍បើកមើលឱ្យបានញឹកញាប់ ទាំងអក្ខរាវិរុទ្ធ ទាំងការបង្ហាញអំពីការអាន(បើគេធ្វើដូចនេះ គេនឹងឃើញថា ការអានពាក្យប្រពៃណី ថាប្រពៃនៃ] ជាការមិនសមស្របទេ*[15]*)។*

*ក្រៅពីអក្ខរាវិរុទ្ធ អាទិភាពទី២បន្ទាន់ គឺការប្រើពាក្យឱ្យបានដូចគ្នា ជាពិសេស ពាក្យសម្គាល់ ប្រទេសនិងរាជធានី/រដ្ឋធានី ដែលប្រជាជនខ្មែរកំពុងប្រើប្លែកៗគ្នា ខ្លះខ្ចីពីភាសាបារាំង ខ្លះខ្ចីពីភាសាអង់គ្លេស : គ.ជ.ភ.ខ. ត្រូវទប់ស្កាត់ឱ្យទាន់ពេល កុំចាំឱ្យបែកជាពីរក្រុមសឹមបង្ខំឱ្យយកពាក្យណាចោលពាក្យណា ដើម្បីឱ្យមានឯកភាពជាក្រោយនោះឡើយ។*

*ការអនុម័តពាក្យតាមជំនាញ ការចៀសវាងការប្រើប្រាស់ពាក្យជាច្រើនសម្រាប់សម្គាល់បញ្ញត្តិតែមួយ (លើកលែងតែករណីពិសេសខ្លះៗ)នឹងនាំឆ្ពោះទៅរកការបង្កើតសទ្ទានុក្រមជំនាញផ្សេងៗ ដែលជាការកិច្ចរយៈពេលយូររបស់គ.ជ.ភ.ខ.: គ.ជ.ភ.ខ.មិនត្រូវដណ្ដើមយកវចនានុក្រមនៃភាសាខ្មែរទូទៅពីពុទ្ធសាសនបណ្ឌិត្យ ឬពីវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា ឬ ពីក្រុមឯកជនណាមួយមកធ្វើនោះឡើយ*[16]*។*

*ជ. គណៈកម្មាធិការជាតិភាសាខ្មែរ*

*អនុប្រធានអចិន្ត្រៃយ៍*

[14]គ.ជ.ភ.ខ.មានភារកិច្ចរកឯកភាពជូនភាសា និង រំលីង "ថ្នល់លំដែលចាក់រាយក្រួសបាយក្រៀមស្ដើងៗ" ពីព្រោះ នេះជាភាពបន្ទាន់ គ.ជ.ភ.ខ. មិនបិទសិទ្ធិរបស់ភាសាវិទូដែល ចង់ស្រាវជ្រាវ ចង់ស្វែងយល់ឱ្យកាន់តែច្បាស់អំពីភាសាខ្មែរ ដើម្បីការរីកចម្រើននោះទេ(ប៉ុន្តែគប្បីភាសាវិទូទាំងឡាយចៀសការអនុវត្តទៅលើដោយអត្តនោម័ត ដោយឥតមានការអនុម័តទទួលយកពីតំណាងប្រជាជាតិខ្មែរ គឺ ពីស្ថាប័នជាតិដូច គ.ជ.ភ.ខ.ដែលមានសព្វថ្ងៃនេះឬពីស្ថាប័នណាមួយទៀតបែបដូចគ្នានេះ នៅពេលអនាគត។

[15]នេះគ្រាន់តែជាឧទាហរណ៍មួយប៉ុណ្ណោះ : អ្នកស្រឡាញ់ភាសាជាតិអាចពឹងផ្អែកលើវចនានុក្រមខ្មែរ ដើម្បីអានពាក្យជាច្រើន ទៀតឱ្យបានសមស្រប។

[16]នៅប្រទេសខាងលិច គេទុកសេរីភាពឱ្យក្រុមបុគ្គលឬបុគ្គលធ្វើវចនានុក្រម ឱ្យតែក្រុមបុគ្គលឬបុគ្គលទាំងនោះគោរពអក្ខរាវិរុទ្ធរបស់ជាតិនិងពាក្យសមស្របរបស់ភាសា : ក្រុមបុគ្គលណាឬបុគ្គលណា ដែលធ្វើបានល្អជាងគេ ក្រុមបុគ្គលឬបុគ្គលនោះមាន អតិថិជនច្រើនជាងគេ។ ចំពោះសទ្ទានុក្រមវិញ ក៏ដូចគ្នានេះដែរ : ប៉ុន្តែ ក្នុងករណីសទ្ទានុក្រមនេះឯង នៅប្រទេសកម្ពុជាយើង យើងនៅមានបញ្ហាប្រើពាក្យមិនត្រូវគ្នាក្នុងជំនាញនីមួយៗ ដូច្នេះក្នុងដំណាក់កាលដំបូង ការត្រួតពិនិត្យពីសំណាក់ គ.ជ.ភ.ខ. ជាការចាំបាច់។

*បណ្ឌិត ព្រុំ ម៉ល់»*

តាំងពីឆ្នាំ២០០៧ មកដល់ឆ្នាំ២០១០ ក្រៅពីអនុម័តពាក្យតាមគណៈកម្មការបច្ចេកសព្ទនីមួយៗ គណៈកម្មាធិការជាតិភាសាខ្មែរបានអនុម័ត គោលការណ៍ធំៗមួយចំនួន ដូចខាងក្រោមៈ

១- ថ្ងៃពុធ ទី២០ ២ ២០០៨ គ.ជ.ភ.ខ.បានអនុម័តជាឯកច្ឆន្ទ ដោយមានសម្បទានពីសមាជិកមួយចំនួន យកអក្ខរាវិរុទ្ធជាផ្លូវការតាមវចនានុក្រមសម្តេច ជួន ណាត បោះពុម្ពឆ្នាំ១៩៦៧ (ភាគទី១)និង ១៩៦៨ (ភាគទី២)។

២- នៅថ្ងៃពុធ ទី៥ ៣ ២០០៨ គ.ជ.ភ.ខ.បានអនុម័តយល់ព្រមបង្កើតឱ្យមានអង់តែនមួយសម្រាប់ឱ្យមហាជនដែលគ្មានវចនានុក្រម សួរអំពីអក្ខរាវិរុទ្ធដែលគេមិនចេះសរសេរ។ លោក ជួរ គារី លេខាធិការនៃ គ.ជ.ភ.ខ.ត្រូវបានចាត់ឱ្យទទួលខុសត្រូវ ឆ្លើយឆ្លងជាមួយអ្នកសួរ...។

៣- នៅថ្ងៃពុធ ទី២១ ៥ ២០០៨ បានពិគ្រោះពិភាក្សាលើធាតុ /-កម្ម/ លើបណ្តុំធាតុ

/-ឧបនីយកម្ម/ និង /-នីយកម្ម/ ដែលគេប្រើនៅចុងពាក្យ ដូចក្នុង *ផលិតកម្ម, ជាតូបនីយកម្ម, សុខដុមនីយកម្ម*...។ ដោយផ្អែកលើគណៈកម្មការវប្បធម៌(គណៈកម្មការនៃការបង្កើតពាក្យ) សម័យសម្តេចព្រះសង្ឃរាជ ជួន ណាតផង និង លើមតិនៃសមាជិកខ្លួនខ្លះផងគ.ជ.ភ.ខ. សម្រេចថាៈ

៣.១- ធាតុ /-កម្ម/អាចប្រើដូចបច្ឆិមបទ សម្រាប់បង្កើតនាមសព្ទសម្គាល់អំពើ/សកម្មភាព/ការ ដូចក្នុង កសិកម្ម (សកម្មភាពនៃការដាំដុះ/នៃការភ្ជួររាស់), ផលិតកម្ម (ការផលិត)....

៣.២- ឱ្យអាទិភាពតាមមតិភាគច្រើនទៅបណ្តុំធាតុ /-នីយកម្ម/ ដែលមិនវែងពេកប្រៀបនឹង /-ឧបនីយកម្ម/ក្នុងការប្រើប្រាស់សម្រាប់បង្កើតនាមសព្ទ ដូច *ខ្មែរនីយកម្ម* ជាដើម ដែលមានន័យថា "ធ្វើឱ្យមានលក្ខណៈជាខ្មែរ" ទោះបីបណ្តុំធាតុទាំងពីរនេះត្រូវគេប្រើជំនួសគ្នាបានដូច ក្នុងខ្មែរនីយកម្ម ឬ ខ្មែរូបនីយកម្ម ក៏ដោយ;

៣.៣- "*ភាវូបនីយកម្ម*" មិនមែនជាបណ្តុំធាតុមួយដុលដែលមាននៅសម័យសម្តេចព្រះសង្ឃរាជ ជួន ណាត ទេ ពីព្រោះ "ភាវូប" ជាលទ្ធផលនៃការតភ្ជាប់រវាងព្យាង្គ "ភាព" ខាងចុង នៃពាក្យដើមខ្លះ ដូចពាក្យ *ឯកភាព, សេរីភាព,...*ទៅនឹងព្យាង្គខាងដើមនៃបណ្តុំធាតុ

/-ឧបនីយកម្ម/ : ក្រោយពីមានការបូកបញ្ចូល*ឯកភាព* ជាមួយ /-ឧបនីយកម្ម/ គេបាន "*ឯកភាវូបនីយកម្ម*" ហើយព្យាង្គ "*ភាព*" ក៏ក្លាយទៅជា "*ភាវ*" រីឯស្រៈ"ុ" ក៏ត្រូវសម្រួលទៅជា ស្រៈ "ូ" វិញ ដូចក្នុង*ឯកភាវូបនីយកម្ម* (ក៏ដូចជាក្នុង*សេរីភាវូបនីយកម្ម, សន្តិភាវូបនីយកម្ម*,...ផងដែរ)។

៤- ថ្ងៃពុធ ទី២៨ ខែឧសភា ឆ្នាំ២០០៨ គ.ជ.ភ.ខ.បានដោះស្រាយបញ្ហាទាក់ទងនឹងការសរសេរជាអក្សរខ្មែរនូវសូរបរទេសមួយចំនួន ដែលយើងតែងតែប្រទះតាមរយៈពាក្យកម្ចី ដោយអនុម័តយកសំណើរបស់ឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ ដែលបានធ្វើការស្រាវជ្រាវ ដោយផ្អែកលើវចនានុក្រមសម្តេច ជួន ណាត និងលើឯកសារផ្សេងៗទៀត។ សូរទាំងនោះ មានៈ

[g] ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ហ្គ"

[f] ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ហ្វ"

[ʒ] ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ហ្ស"

[ɟ] ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ "ស្ជ"

[ s]/[z] ដែលយើងត្រូវប្រើព្យញ្ជនៈ "ស"

ក្រៅពីអនុម័តយកការសរសេរ ការអានខាងលើ គ.ជ.ភ.ខ. បានអនុម័តគោលការណ៍បង្កើតពាក្យ ដែលស្នើដោយគណៈកម្មការបង្កើតពាក្យនិងកម្ចីពាក្យ។

## គោលការណ៍បង្កើតពាក្យ

ដើម្បីបង្កើតពាក្យ គេត្រូវស្គាល់កត្តាបីធំៗគឺ លក្ខខណ្ឌនៃការបង្កើតពាក្យ វិធីនៃការបង្កើតពាក្យ និងធាតុដែលត្រូវយកមកប្រើសម្រាប់បង្កើតពាក្យ។

### **១- លក្ខខណ្ឌនៃការបង្កើតពាក្យ**

លក្ខខណ្ឌនេះជាដែនកំណត់ឱ្យមានភាពរលូននៅក្នុងការបង្កើតពាក្យនិងក្នុងការប្រើប្រាស់ពាក្យ ហើយក៏អាចរក្សាបាននូវឯកភាពក្នុងភាសាខ្មែរ។

១.១- លក្ខខណ្ឌទីមួយ

ត្រូវបង្កើតពាក្យថ្មី ដើម្បីសម្គាល់តែបញ្ញត្តិថ្មី។ បញ្ញត្តិថ្មីជាបញ្ញត្តិដែលគេមិនធ្លាប់ស្គាល់ឬមិនទាន់មានពាក្យដើម្បីសម្គាល់វា។ ក្នុងក្របខណ្ឌនេះ យើងមិនត្រូវបង្កើតពាក្យថ្មីដើម្បីសម្គាល់បញ្ញត្តិដែលមានពាក្យសម្រាប់ហៅរួចមកហើយនោះឡើយ បើពុំនោះសោតទេ វានឹងបង្កឱ្យមានការខ្វះឯកភាពនៅក្នុងភាសាខ្មែរ។ ពាក្យថ្មីៗដូចជាពាក្យ វាទករ (énonciateur ) វាទកាល (temps de l'énonciation) កើតឡើងក្នុងឆ្នាំ១៩៩៣ .....។

១.២- លក្ខខណ្ឌទីពីរ

យើងអាចបង្កើតពាក្យថ្មី ដើម្បីសម្គាល់បញ្ញត្តិចាស់ តែក្នុងករណីដែលបច្ចេកសព្ទចាស់មានបញ្ហា។ ឧទាហរណ៍ គេអាចបង្កើតពាក្យ *ផ្លាក់* ដើម្បីជំនួសពាក្យ *អាយតនិបាត* ព្រោះ *អាយតនិបាត* ជាពាក្យបាលី ដែលមានលក្ខណៈវែងនិងពិបាកយល់។ល។ ហើយពាក្យថ្មីមានសុក្រឹតភាពជាង។ ម្យ៉ាងទៀតនៅក្នុងស្នាដៃស្ដីពីវេយ្យាករណ៍អន្តរកម្មនិយម គេបានបង្កើតបច្ចេកសព្ទ *ឯកតភាព* ដើម្បីជំនួសបច្ចេកសព្ទ *ឯកវចនៈ* មិនសម្គាល់បញ្ញត្តិដែលមាននៅក្នុងការសិក្សាពីនាមសព្ទខ្មែរនោះទេ។ ដោយហេតុនេះហើយ បានជានៅក្នុងភាសាខ្មែរ យើងគ្មានឈ្នាក់វេយ្យាករណ៍ដើម្បីបញ្ជាក់ពីវចនៈរបស់នាមនោះទេ។

ប្រការនេះបណ្ដាលមកពីខ្មែរយើងគ្មានវចនៈ ហើយ អ្វីដែលគេយល់ច្រឡំថាជាឯកវចនៈនោះ តាមពិតទៅ វាគ្រាន់តែជាបញ្ញត្តិមួយទាក់ទងទៅនឹងចំនួនដែលបញ្ជាក់ពីភាពមានមួយឯកតា ហើយដែលគេហៅថា *ឯកតភាព* ។

១.៣- លក្ខខណ្ឌទីបី

ការបង្កើតពាក្យត្រូវធ្វើឡើងតាមវិធីណាមួយក្នុងចំណោមវិធីទាំងអស់របស់ខ្មែរ ដែលមានភាពសមស្របជាងគេបំផុតទៅនឹងតម្រូវការជាក់ស្ដែង។ យើងត្រូវខិតខំជ្រើសរើសយកវិធីណាមួយដែលមានសុក្រឹតភាពជាង

និងអាចផ្តល់ជាពាក្យដែលមានភាពងាយស្រួលក្នុងការប្រើប្រាស់។ ម្យ៉ាងទៀត បើសម្រេចជ្រើសរើសយកវិធីណាមួយដែលមានកល្ខណៈសមស្របជាងបំផុតមកប្រើដើម្បីបង្កតពាក្យសម្រាប់សម្គាល់បញ្ញត្តិមួយហើយមិនគួរគប្បីប្រើវិធីផ្សេងទៀតដើម្បីបង្កើតពាក្យសម្រាប់ហៅបញ្ញត្តិដដែលនោះទៀតទេ ព្រោះវាអាចនាំឱ្យមានបញ្ហានៅក្នុងអក្សរសាស្ត្រជាតិ។

១.៤- លក្ខខណ្ឌទីបួន

ការបង្កើតពាក្យត្រូវឈរលើមូលដ្ឋាននៃវេយ្យាករណ៍ណាមួយច្បាស់លាស់ ដោយអនុលោមទៅតាមគោលការណ៍ន័យនិយម មានន័យថា ពាក្យដែលបង្កើតមកត្រូវមានន័យច្បាស់លាស់ឬត្រូវសម្គាល់បញ្ញត្តិណាមួយដែលខ្មែរយើងបានជួបប្រទះ។

**២- វិធីនៃការបង្កើតពាក្យ**

វិធីបង្កើតពាក្យគឺជាក្បួនដែលបានប្រើរួចមកហើយ ហើយអាចប្រើបន្តទៅទៀតបាន ដោយអនុលោមទៅតាមភាពសមស្របនៃតម្រូវការចំពោះមុខ។

២.១- វិធីផ្សេងៗ មាន៖

២.១.១- វិធីបន្សំ មានទម្រង់៖

- ទម្រង់ស្នូល-បន្សំ ដូចជា **ស្បែក**គោ **ស្ករ**ត្នោត **កង់**ឡាន **ផ្ទះ**ថ្ម **ដំឡូង**ឈាមមាន់ **កាហ្វេ**ខ្មៅ ...។
- ទម្រង់បន្សំ-ស្នូល ដូចជា កូន**សោ** មេ**សោ** ចុង**ផ្លូវ** ដើម**ផ្លូវ** លោក**គ្រូ** អ្នក**គ្រូ** ...។
- ទម្រង់សមាស ដូចជា កងទ័ពព្រៃម៉ៅនិយម លទ្ធិពុទ្ធសាសនា មនុស្សអាត្មានិយម...។

គឺ *កងទ័ពព្រៃដែលចូលចិត្តម៉ៅ លទ្ធិនៃពុទ្ធសាសនា*...។

- ទម្រង់បង្គុំ ដូចជា ឪពុកម្តាយ បងប្អូន កូនចៅ ។ល។
- ទម្រង់បន្ថែម មានបន្ថែមដើមនិងបន្ថែមចុង

បន្ថែមដើម ដូចជា **ការ**រៀនសូត្រ **ភាព**អង់អាច **សុ**ច្ឆន្ទៈ **អ**គតិ ។ល។

បន្ថែមចុង ដូចជា កុមា**រា** កុមា**រី** នាយ**ក** នាយិ**កា** ឧក្រិដ្ឋ**កម្ម** សកល**ភាព** សុក្រឹត**ភាព**

២.១.២- វិធីសមាស ជាវិធីដែលកើតឡើងដោយការប្រើវិធីពីរឬច្រើនបញ្ចូលគ្នានៅក្នុងការបង្កើតពាក្យមួយដែលយើងអាចហៅបានថា ជាពាក្យបន្សំសមាស ដូចជា សកលភាវូបនីយកម្ម (< សកល+ភាព>សកលភាព, ឧប+នីយ+កម្ម>ឧបនីយកម្ម, រួចគេសំយោគលទ្ធផលនៃពាក្យសមាសទាំងពីរ>សកលភាព+ឧបនីយកម្ម «ដោយប្តូរ ព ជា វ និង ឧ ជា ូ » > សកលភាវូបនីយកម្ម )។

២.១.៣- វិធីកម្លាយ ជាវិធីបង្កើតពាក្យដោយប្រើផ្នត់មកកម្លាយពាក្យឫសដើម្បីបង្កើតពាក្យថ្មី។ ឧទាហរណ៍ គេប្រើផ្នត់ដែក[-ម-]ដើម្បីកម្លាយឫស *ចាំ* ឱ្យកើតទៅជា *ឆ្មាំ* ដែលមានន័យថា *អ្នកចាំ*រីឯ ផ្នត់ដែក[-ន-] ប្រើកម្លាយឫស*ជាន់* ឱ្យកើតទៅជាពាក្យ*ឈ្នាន់* ដែលមានន័យថា *ឧបករណ៍សម្រាប់ជាន់*។ ដូចគ្នា គេអាចបង្កើតពាក្យ *ខ្នាន់ ថ្នើរ ធ្នុក ខ្នើយ ខ្និប ឃ្នាស់* ...។

២.១.៤- វិធីតម្រាប់សូរ ជាវិធីបង្កើតពាក្យដោយត្រាប់តាមសូរដែលបានឮ។ ឧទាហរណ៍ *តុកកែ តក់ៗ គ្រឹមៗ តាវ៉ៅ កុកកែកឹត កាក់គីងកាងកឹត ផាំង* ...។ល។

២.១.៥- វិធីសន្មត ជាវិធីមួយនៃការបង្កើតពាក្យដែលគេប្រើនៅពេលដែលគេគ្មានលទ្ធភាពបង្ហាញពីហេតុផល។ ឧទាហរណ៍ *ទៅ លេង ស លឿង ចង់ ដាវ* ។ល។

២.១.៦- វិធីរូប-សទ្ទតា ជាលទ្ធផលនៃការបកប្រែស្ទើរតែចំៗពីបច្ចេកសព្ទបារាំងថា procédés morpho-phonologiquesគឺ ពាក្យមួយសងពាក្យមួយ : procédés = វិធី, morpho(< morphologie)=រូប/រូបតា, phonologiques(< phonologie)= សទ្ទតា(វិទ្យា)។ ទាំងក្នុងភាសាបារាំង ទាំងក្នុងភាសាខ្មែរ បច្ចេកសព្ទនេះឥតមានន័យឱ្យគេចាប់បាន ដូចជា វិធីកម្លាយឬសមាស ជាដើមនោះ ឡើយ។ បច្ចេកសព្ទនេះមានអរូបីយកម្មខ្ពស់ទៅលើន័យ បានសេចក្ដីថា ន័យរបស់បច្ចេកសព្ទត្រូវបាន គេសន្មត ឡើងប្រហាក់ប្រហែលនឹងន័យរបស់ពាក្យ atome នៅពេលដំបូងនៅពេលគេដាក់ឱ្យប្រើនោះដែរ។ នៅក្នុងវិធីនេះមាន ការកាត់ពាក្យ(ពាក្យក្រៅ/ក្នុងកន្សោម)ដោយបែបផ្សេងៗ ហើយ គេសម្រួល រូបសាស្ត្រ ឬ ទុកដដែល តាមការចាំបាច់...។

- ពាក្យអក្សរកាត់បានមកពីការទុកអក្សរទីមួយខាងដើម នៃពាក្យនីមួយក្នុងកន្សោមពាក្យ ឧទាហរណ៍ គ.ជ.ភ.ខ. , គ.ជ.ប., ...។

- ពាក្យកន្សោមកាត់ ការកាត់ប៉ះភាគ/ពាក្យខាងដើមនៃកន្សោម ឧទាហរណ៍ សមត្ថកិច្ច < អាជ្ញាធរ មានសមត្ថកិច្ច ....។ល។

- ពាក្យកាត់ ពាក្យកាត់ខាងចុង និង ពាក្យកាត់ខាងដើម

ពាក្យកាត់ខាងចុង ឧទាហរណ៍ ឯកឧត្តមឧប < ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ....។

ពាក្យកាត់ខាងដើម ឧទាហរណ៍ ក្នុងភាសាបារាំង ដូចជា Bus < autobus ...។

- ពាក្យកាត់ត , ....

**៣- ធាតុសម្រាប់បង្កើតពាក្យ**

**៣.១-** ធាតុជាឯកតាភាសា(សទ្ទតា[17] រូបតា[18] ពាក្យ)។ល។ ដែលប្រើសម្រាប់បង្កើតពាក្យ។ ឧទាហរណ៍៖

- *បង* និង *ប្អូន* ជាធាតុដែលប្រើបង្កើតពាក្យ *បងប្អូន* ។

- ផ្នត់ដើម [ក-] និងពាក្យឫស *បាំង* ជាធាតុដែលប្រើសម្រាប់បង្កើតពាក្យ *ក្បាំង* ។

**៣.២-** លក្ខខណ្ឌនៃការជ្រើសរើសធាតុក្នុងការបង្កើតពាក្យ

ដើម្បីអភិរក្សភាសាខ្មែរនិងអត្តសញ្ញាណជាតិ យើងត្រូវគោរពលក្ខខណ្ឌដូចតទៅ៖

[17]សទ្ទតាជាឯកតាអប្បរមាគ្មានន័យរបស់ភាសា (ចំពោះភាសាដែលចាត់ទុកសទ្ទតា ជាឯកតាតូចបំផុតរបស់ភាសានោះ) ហើយ មានមុខងារញែក/មុខងារបំប្លែកនៅក្នុងរូបតានិងវចនតា។

[18]រូបតា(morphème)ជាមូលតាមួយបែបដែលឥតមានអត្ថិភាពជាពាក្យឯករាជ្យក្នុងភាសា ហើយដែលក្នុងភាសាខ្មែរគេប្រើសម្រាប់ភ្ជាប់ជាមួយពាក្យឫសដើម្បីបង្កើតពាក្យកម្លាយ ដូចជា [-ម-] (រូបតា) + ជួញ (ពាក្យឫស/វចនតា)>ឈ្មួញ...។

៣.២.១- លក្ខខណ្ឌទីមួយ

ត្រូវប្រើប្រាស់ជាចម្បងនិងឱ្យអស់ពីលទ្ធភាពនូវធាតុដែលមានក្នុងភាសាខ្មែរ-មន។

៣.២.២- លក្ខខណ្ឌទីពីរ

ប្រើប្រាស់ធាតុបាលីសំស្ក្រឹតបែបខ្មែរក្នុងករណីចាំបាច់ឬក្នុងករណីដែលធាតុខ្មែរ-មនមិនអាចយកមកប្រើបាន។

៣.២.៣- លក្ខខណ្ឌទីបី

រក្សាទម្លាប់ល្អដែលមានកន្លងមកដោយបន្តមិនប្រើប្រាស់ធាតុដែលមានក្នុងភាសាដទៃទៀតក្រៅពីភាសាខ្មែរ-មន និង បាលីសំស្ក្រឹត លើកលែងតែក្នុងករណីខានមិនបាន ដូចមានក្នុងឧទាហរណ៍ខាងក្រោម។

ឧទាហរណ៍ ទូកម៉ាស៊ីន ទឹកតែ មីឆា ស៊ុបគោ រ៉ឺម៉កម៉ូតូ មីក្រូសេដ្ឋកិច្ច ម៉ាក្រូសេដ្ឋកិច្ច។ល។

## គោលការណ៍កម្ចីពាក្យ

### ១- និយមន័យ

#### ១.១-និយមន័យនៃគោលការណ៍កម្ចីពាក្យ

គោលការណ៍កម្ចីពាក្យជាក្បួនទូទៅមួយដែលជួយដល់អ្នកបច្ចេកទេសឱ្យបានដឹងពីព្រំដែននៃកម្ចីពាក្យ។ គោលការណ៍នេះនឹងផ្តល់នូវលទ្ធភាពក្នុងការខ្ចីពាក្យពីបរទេសមកប្រើប្រាស់ផង និង ផ្តល់នូវលក្ខខណ្ឌដើម្បីរក្សាឱ្យបាននូវអត្តសញ្ញាណភាសាខ្មែរផង។

#### ១.២-និយមន័យនៃពាក្យកម្ចី

ពាក្យកម្ចីគឺជាពាក្យដែលខ្មែរខ្ចីពីភាសាបរទេស ដោយនាំយកមកជាមួយទាំងដុលឬដោយអន្លើនូវបញ្ញត្តិដែលពាក្យបរទេសនោះសម្គាល់ ហើយ ដែលខ្មែរមិនទាន់មានពាក្យឬមិនអាចបង្កើតពាក្យមក សម្គាល់បញ្ញត្តិនោះបាន។ ឧទាហរណ៍ *សាមញ្ញ វិជ្ជា ស៊ីម៉ងត៍ ម៉ូតូ ម៉ូទ័រ កុំព្យូទ័រ* ។ល។

### ២- លក្ខខណ្ឌនៃកម្ចីពាក្យ

ដើម្បីបន្តអភិរក្សភាសាខ្មែរនិងរក្សាឱ្យបាននូវចីរភាពនៃគំនិតច្នៃប្រឌិតរបស់បុព្វបុរសខ្មែរ ការខ្ចីពាក្យពីភាសាបរទេសមកប្រើក្នុងភាសាខ្មែរទំនើប ត្រូវគោរពតាមគោលការណ៍ដូចតទៅនេះ៖

#### ២.១-លក្ខខណ្ឌទីមួយ

អាចខ្ចីពាក្យពីបរទេសមកប្រើតែក្នុងករណីដែលមិនអាចបង្កើតពាក្យក្នុងភាសាខ្មែរដើម្បីសម្គាល់បញ្ញត្តិដែលមាននៅក្នុងភាសាបរទេសនោះបាន។ ឧទាហរណ៍ *ស៊ីម៉ងត៍ អេតចាយ កាហ្វេ តែ* ។ល។

#### ២.២-លក្ខខណ្ឌទីពីរ

អាចខ្ចីពាក្យពីបរទេសមកប្រើតែក្នុងករណីដែលការបង្កើតពាក្យក្នុងភាសាខ្មែរអាចធ្វើទៅបានដែរ តែវា

ចោទជាបញ្ហាដូចជាវែងពេក ពិបាកអាន ពិបាកយល់ន័យ មិនចំន័យ ឬ មានន័យខុសពីពាក្យដើម ។ល។

**២.៣-លក្ខខណ្ឌទីបី**

ហាមមិនឱ្យខ្ចីពាក្យពីបរទេសមកប្រើជំនួសពាក្យដែលមានក្នុងភាសាខ្មែររួចហើយ។ ឧទាហរណ៍ មិនត្រូវខ្ចីពាក្យ *ស៊ីញ៉េ កុងត្រា លីង សៀវែយ៉ង់ កុងត្រូល័រ* ។ល។ មកប្រើជំនួសពាក្យ (ចុះ) *ហត្ថលេខា កិច្ចសន្យា ខ្សែ អនុរក្ស អប្បមាទ* ។ល។ ដែលខ្មែរបានប្រើរួចហើយនោះទេ ទោះបីជាពាក្យនេះជាពាក្យកម្ចី ពីភាសាបរទេសដែរក៏ដោយចុះ។

**២.៤-លក្ខខណ្ឌទីបួន**

ត្រូវព្យាយាមខ្ចីពាក្យពីភាសានៃប្រទេសដែលស្ថិតនៅឆ្ងាយពីប្រទេសខ្មែរ ហើយដែលគ្មានចេតនាសាបព្រោះឥទ្ធិពលមកលើភាសាវប្បធម៌ និង អត្តសញ្ញាណកម្មខ្មែរ ទោះក្នុងកាលៈទេសៈណាក៏ដោយ។

**២.៥-លក្ខខណ្ឌទីប្រាំ**

ខ្ចីពាក្យត្រូវឈរលើមូលដ្ឋានសម្របសម្រួលផ្នែកសំណេរនិងសំណូរដែលមានលក្ខណៈជាឡាតាំងបែបខ្មែរ ទោះបីជា ពាក្យទាំងនោះមានប្រភព(យោងលើលក្ខខណ្ឌទីបួនផង)មកពីភាសាណាក៏ដោយ។

## ជម្រើសរវាងការបង្កើតពាក្យនិងកម្ចីពាក្យ

នៅពេលជួបប្រទះនឹងបញ្ញត្តិថ្មី តាមរយៈការស្រាវជ្រាវនិងការបកប្រែ គួរមានទម្លាប់រិះរកបង្កើត ពាក្យឱ្យអស់លទ្ធភាពសិន មុននឹងខ្ចីពាក្យពីភាសាបរទេស។ ក្នុងស្មារតីនេះ យើងត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនដែលមានចែងបន្ទាប់ពីនិយមន័យខាងក្រោមនេះ។

**១- និយមន័យ**

ជម្រើសពុំមែនជាទ្វេបថដែលមានន័យថាយកគោលការណ៍ណាមួយក៏បាននោះទេ តែវាប្រើក្នុងន័យតម្រូវឱ្យជ្រើសរើសយកគោលការណ៍ណាមួយក្នុងចំណោមការបង្កើតពាក្យនិងកម្ចីពាក្យដែលសម ស្របទៅនឹងភាពចាំបាច់បំផុត។

**២- លក្ខខណ្ឌ**

ជាចំណងមួយដែលមិនអនុញ្ញាតឱ្យប្រើគោលការណ៍បង្កើតពាក្យឬគោលការណ៍កម្ចីពាក្យតាមតែចិត្តចង់បាននោះទេ។

**២.១- លក្ខខណ្ឌទីមួយ**

ផ្តល់អាទិភាពទៅលើការបង្កើតពាក្យជាជាងកម្ចីពាក្យមកប្រើភ្លាមៗ។ លក្ខខណ្ឌនេះមានបំណងអភិរក្សភាសាខ្មែរនិងទប់ស្កាត់ឥទ្ធិពលពីភាសាដទៃ។

**២.២- លក្ខខណ្ឌទីពីរ**

អាចអនុវត្តគោលការណ៍កម្ចីពាក្យបានតែក្នុងករណីដែលការបង្កើតពាក្យមិនអាចធ្វើទៅបាន។

**២.៣- លក្ខខណ្ឌទីបី**

អាចអនុញ្ញាតឱ្យខ្ចីពាក្យមកប្រើភ្លាមៗ តែក្នុងករណីចាំបាច់ជាបន្ទាន់ដែលការបង្កើតពាក្យដើម្បីយកមក

បកប្រែពាក្យបរទេសមិនអាចធ្វើទាន់តាមតម្រូវការ។ ប៉ុន្តែ មិនត្រូវបញ្ចូលពាក្យទាំងនោះទៅក្នុងវចនានុក្រមភ្លាមៗទេ ដោយទុកប្រើជាបណ្តោះ អាសន្នសិន ហើយត្រូវខំបង្កើតពាក្យក្នុងគ្រាបន្ទាប់ដ៏ខ្លីដើម្បីបកប្រែពាក្យនោះជាភាសាជាតិវិញ។

**២.៤- លក្ខខណ្ឌទីបួន**

ផ្តល់អាទិភាពទៅឱ្យការអនុវត្តគោលការណ៍កម្ចីពាក្យតែនៅក្នុងវិស័យវិទ្យាសាស្ត្រពិត ហើយខំចៀសវាងកម្ចីពាក្យក្នុងវិស័យភាសាវិទ្យា អក្សរសាស្ត្រ អក្សរសិល្ប៍ វប្បធម៌ ដើម្បីថែរក្សានិងអភិរក្ស អត្តសញ្ញាណជាតិខ្មែរ។

**២.៥- លក្ខខណ្ឌទីប្រាំ**

មិនត្រូវបង្កើតពាក្យថ្មីមកជំនួសពាក្យកម្ចីដែលមានប្រើយូរមកហើយនោះទេ។ ឧទាហរណ៍ មិនត្រូវខិតខំបង្កើតពាក្យថ្មី ដើម្បីជំនួសពាក្យថ្មីដើម្បីជំនួសពាក្យ *គោ* ដែលខ្មែរខ្ចីពីបាលីសំស្រ្កឹតយូរមកហើយនោះឡើយ ហើយ ក៏មិនត្រូវស្វែងរកបង្កើតពាក្យថ្មីមកជំនួសពាក្យ ស៊ីម៉ងត៍ ដែលខ្មែរខ្ចីពីបារាំងយូរមក ហើយនោះដែរ។

**២.៦- លក្ខខណ្ឌទីប្រាំមួយ**

ជម្រើសរវាងការបង្កើតពាក្យនិងកម្ចីពាក្យត្រូវអនុវត្តចំពោះករណីដែលត្រូវសម្គាល់បញ្ញត្តិថ្មីតែប៉ុណ្ណោះ។ បើយើងជ្រើសយកការបង្កើតពាក្យមកអនុវត្តហើយ ហាមខ្ចីពាក្យបរទេសមកប្រើដើម្បីសម្គាល់បញ្ញត្តិដដែលនោះទៀត។ ផ្ទុយទៅវិញ បើខ្ចីពាក្យពីភាសាបរទេសមកប្រើជាអចិន្ត្រៃយ៍ហើយ ហាមមិនឱ្យបង្កើតពាក្យមកជំនួសពាក្យកម្ចីនោះឡើយ។

## គន្ថនិទ្ទេស

### ១- ជាភាសាខ្មែរ


- ពុទ្ធសាសនបណ្ឌិត្យ: វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨។
- ព្រឹត្តិបត្រ គ.ជ.ភ.ខ. លេខពិសេស លេខ១ លេខ២ លេខ៣។
- មីសែល ត្រាណេ : មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ, ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ពខ្មែរ, ឆ្នាំ២០១៣។
- សទ្ទានុក្រមខេមរយានកម្ម ឆ្នាំ១៩៦៩
- សទ្ទានុក្រមខេមរយានកម្ម ឆ្នាំ១៩៧៣
- ឡុង សៀម : វាក្យស័ព្ទសំស្ក្រឹតដំបូងក្នុងភាសាខ្មែរបុរាណ និងស្ថាននាម មានប្រភពចេញពីសំស្ក្រឹត ... នៅក្នុង ៖ ទស្សនាវដ្ដីកម្ពុជសុរិយា, លេខ១ ឆ្នាំទី៥០ ឆ្នាំ១៩៩៦។
- ឡុង សៀម : ស្ថាននាមវិទ្យាខ្មែរ ភ្នំពេញ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៩៧។
- ឡុង សៀម : បញ្ញាវចនស័ព្ទវិទ្យា ភ្នំពេញ ផ្សាយដោយអ្នកនិពន្ធ ឆ្នាំ១៩៩៩។
- ឡុង សៀម : វចនានុក្រមខ្មែរបុរាណ (តាមរយៈសិលាចារឹកបុរេអង្គរ សតវត្សរ៍ទី៦-៨) រោងពុម្ពភ្នំពេញ ឆ្នាំ២០០០ ។

- ឡុង សៀម : " អំពីកិត្យានុភាព និងការអភិវឌ្ឍន៍ភាសាខ្មែរ( ជាពិសេសតាមឯកសារភាសា មន-ខ្មែរ និងសិលាចារឹកកម្ពុជា )"នៅក្នុង ៖ ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា លេខ០២ មិថុនា ២០០១ ។
- អៀវ កើស: ភាសាខ្មែរ , បណ្ណាគារមិត្ត សេរី , ភ្នំពេញ , ឆ្នាំ១៩៦៧ ។

**២- ស្នាដៃជាភាសាបរទេស**

- Coedès.G, ***Inscriptions du Cambodge,*** Hanoi, BEFEO,VolumeI, 1937.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeII, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeIII, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeIV, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeV, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeVI, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeVII, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeVIII, 1942.
- Jenner Philip N, ***A chrestomathy of Pre-Angorian Khmer I, Dated Inscriptions from the seventh and Eighth Cenyuries( A.D.611-781),*** University of Hawaii, White Lotus, 1980.
- Jenner Philip N, ***A chrestomathy of Pre-Angorian Khmer II, Lexicon of the Dated Inscriptions,***University of Hawaii, Publication by Author, 1981.
- Jenner Philip N, ***A chrestomathy of Pre-Angorian Khmer III, Undated Inscriptions fram the Sixth to the Eighth Century,*** University of Hawaii, Publication by Author,1988.
- Jenner Philip N, ***A chrestomathy of Pre-Angorian Khmer IV, Lexicon of the Undated Inscriptions,*** University of Hawaii, Publicaion by Author, 1982 .
- Pou Saveros, **Dictionaire Vieux Khmer- Français-Anglais an Old Khmer-French Dictionary**, Paris, Cedoreck, 1992.

# ទំនៀមពីបុរាណតាមរយៈសិលាចារឹក

បណ្ឌិត មាឃ បូរ៉ា
ប្រធានវិទ្យាស្ថានភាសាជាតិ

**សិលាចារឹក** មកពីពាក្យ **សិលា** មានន័យថ្ម ផ្សំជាមួយនឹងពាក្យ **ចារឹក** ដែលមានន័យថា ចារ សរសេរ កត់ត្រាជាដើម។ ដូច្នេះសិលាចារឹកមានន័យថា អក្សរដែលបានចារនៅលើផ្ទាំងថ្ម។ ដូច្នេះបានសេចក្ដីថា សិលាចារឹក គឺជាអត្ថបទអក្សរសាស្ត្រ អក្សរសិល្ប៍ ប្រវត្តិសាស្ត្រ ដែលត្រូវបានគេសរសេរ កត់ត្រា ទុកនៅលើគោលសីមា លើជញ្ជាំងប្រាសាទ លើសសរស្ដម្ភ លើមេទ្វារ មេបង្អួច ឆ្លាក់នៅលើឧបករណ៍ប្រើប្រាស់ផ្សេងៗ ជាដើម។

សិលាចារឹកសរសេរជាភាសាខ្មែរដែលមានចុះកាលបរិច្ឆេទឆ្នាំ៥៣៣ម.ស.ត្រូវនឹងឆ្នាំ៦១១គ.ស. គឺសិលាចារឹកអង្គរបុរីK.៦០០មានចំណាស់ជាងគេ។ ប៉ុន្តែ បើយើងសង្កេតទៅលើទម្រង់អក្សរនៃសិលាចារឹកមួយចំនួនដែលគេបានរកឃើញក្រៅអំពីសិលាចារឹកនេះ ដូចសិលាចារឹកវត្តថ្លែងK.១, សិលាចារឹកវត្តពោធិវង្សលើK.១១, សិលាចារឹកអង្គរបុរីK.២៥(តាកែវ), សិលាចារឹកព្រះវិហារធំ(កំពង់ចាម)K.៥២០, សិលាចារឹកទួលអង្គ(តាកែវ) K.៥៥៩ ជាដើម យើងឃើញថា មានវ័យចំណាស់ជាងសិលាចារឹកK.៦០០ទៅទៀត គ្រាន់តែសិលាចារឹកទាំងនេះគ្មានចុះកាលបរិច្ឆេទតែប៉ុណ្ណោះ។ ដោយឈរលើមូលដ្ឋាននេះ គេអាចសន្និដ្ឋានបានថា សិលាចារឹកសរសេរជាភាសាខ្មែរយើងអាចចាប់បដិសន្ធិឡើងក្នុងអំឡុងសតវត្សរ៍ទី៥-៦មកម្លេះ។

រាល់អត្ថបទនៃសិលាចារឹកទាំងអស់ លោកចារឡើងឧទ្ទិសថ្វាយដល់អាទិទេពក្នុងលទ្ធិព្រហ្មញ្ញសាសនា ពុទ្ធសាសនាមហាយាន ឬជាអត្ថបទរដ្ឋការ ជាអត្ថបទរៀបរាប់អំពីបញ្ជីឈ្មោះ នរនាម ស្ថាននាម កត់ត្រាព្រឹត្តិ-ការណ៍ រឿងរ៉ាវ សកម្មភាពនានា ដែលមានលក្ខណៈជាប្រវត្តិ ដែលបានកើតឡើងនៅក្នុងសម័យកាលរបស់ខ្លួនឱ្យកូនចៅជំនាន់ក្រោយបានដឹងបានយល់អំពីកិច្ចការដែលខ្លួនបានធ្វើកន្លងមក និង ចង់ឱ្យអ្នកជំនាន់ក្រោយបន្តស្នាដៃរបស់ខ្លួនទៀត ដើម្បីស្វែងយល់អំពីប្រវត្តិសាស្ត្រ ពង្សាវតារ រឿងរ៉ាវ ហេតុការណ៍របស់ បុព្វបុរស និង ជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងឱ្យឃើញពីអរិយធម៌ សាសនានៅក្នុងប្រទេសរាប់ពាន់ឆ្នាំមកហើយ និងជាឯកសារពិតប្រាកដ មិនអាចក្លែងបន្លំបានឡើយ។ មិនតែប៉ុណ្ណោះ សិលាចារឹកមិនត្រឹមតែជាឯកសារបុរាណ ដែលសិក្សាអំពីអក្សរនិងភាសាប៉ុណ្ណោះទេ វាបានផ្ដល់ផលប្រយោជន៍ដល់មុខវិជ្ជាដទៃទៀត ដូចជាផ្នែកបុរាណវត្ថុវិទ្យា ប្រវត្តិសាស្ត្រ សាសនា សិល្បៈ វប្បធម៌ ជាដើម។

ការសិក្សាស្រាវជ្រាវនានា ទោះបីទាក់ទងជាមួយនឹងជំនាញអ្វីឬប្រធានបទអ្វីក៏ដោយ តែងតែផ្ដល់ផលប្រយោជន៍ តាមមុខជំនាញទាំងនោះ។ តាមការសិក្សាស្រាវជ្រាវ យើងសង្កេតឃើញថា អត្ថបទសិលាចារឹកបានចង្អុលបង្ហាញ ពីគោរមងារសម្គាល់អាទិទេព ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី មន្ត្រីថ្នាក់ខ្ពស់ មន្ត្រីតាមវិស័យនានា រហូតអ្នក បម្រើប្រុសស្រី ស្ថាបត្យកម្មសំណង់ប្រាសាទ ព្រះវិហារ នគរ បុរី ភូមិភាគ ខេត្ត ស្រុក ភូមិឋាន ដីស្រែ ចម្ការ ច្បារ ដំណាំ ការរៀបចំដែនដីថ្មី ការជីកបារាយណ៍ ការជីកស្រះត្រពាំង ការលើកទំនប់ ការជីកប្រឡាយ សកម្មភាព ខាងសាសនា ខាងសង្គមកិច្ច។ល។ ពីសំណាក់ព្រះមហាក្សត្រ ព្រាហ្មណាចារ្យ ព្រះសង្ឃ គ្រប់ជាន់ថ្នាក់ ពួកអភិជន មន្ត្រីគ្រប់ជាន់ថ្នាក់នៅតាមខេត្ត ស្រុក ជាដើម ដើម្បីអភិវឌ្ឍមហានគរឱ្យល្បីល្បាញនៅក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោក។

នៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងផ្តោតលើសិលាចារឹកសម័យមុនអង្គរនិងសម័យអង្គរតែប៉ុណ្ណោះ ហើយក្នុងការសិក្សានេះ យើងចែកជាបីចំណុច ដូចមានជាបន្តបន្ទាប់៖

## ១- ស្ថាននាមសម្គាល់ដែនដីរដ្ឋបាលសម័យមុនអង្គរនិងសម័យអង្គរ

### ១.១- នគរ

នៅសម័យមុនអង្គរ យើងមិនទាន់ឃើញសំណេរពាក្យ **នគរ** ដែលមានន័យថា រាជធានី ទីក្រុងនៅឡើយទេ។ លុះមកដល់សម័យអង្គរ ទើបយើងឃើញមានការប្រើពាក្យ **នគរ** ដោយភ្ជាប់ជាមួយនឹងពាក្យ **នគរ** នេះ មាន : **នគរស្រីយសោធរបវ៌ត** nagara çrī yaçodharaparvvata នៅក្នុងសិលាចារឹក K.444,៩៧៤នៃគ.ស. បន្ទាត់ទី១០, **នគរស្រីឥន្ទ្របុរ** nagara çrī indrapura សិលាចារឹកប្រាសាទបេងK.989B,១០០៨នៃគ.ស. បន្ទាត់ទី៨, **នគរស្រីមាហេន្ទ្របវ៌ត** nagara çrī māhendra parvvata សិលាចារឹកស្តុកកក់ធំK.235C,១០៥២នៃ គ.ស.បន្ទាត់ទី៥៦ និង **នគរអភិវាទននិត្យ** nagara abhivādananitya សិលាចារឹកស្តុកកក់ធំK.235D,១០៥២នៃ គ.ស.បន្ទាត់ទី៧០។

### ១.២-ប្រមាន/ប្រមាណ pramān pramāṇ

តាមរយៈសិលាចារឹកសម័យមុនអង្គរនិងសម័យអង្គរ វាក្យសព្ទ"ប្រមាន/ប្រមាណ pramān pramāṇ" បានត្រូវប្រើទាំងសម័យមុនអង្គរ ទាំងសម័យអង្គរ ដើម្បីកំណត់ឈ្មោះនៃការបែងចែកទឹកដីធំៗឬមួយភូមិភាគនៃកម្ពុជទេសក្នុងដឹកនាំគ្រប់គ្រងប្រទេស។ បើតាមរយៈសិលាចារឹក គេប្រើវាក្យសព្ទ ប្រមាន/ប្រមាណ pramān pramāṇ នេះ ដែលមានដូចជាប្រមានិជេង៑តរាញ pramān jeṅ tarāñ K.878, ៨៩៦នៃគ.ស.បន្ទាត់ទី១២; K.183, ៩២៨នៃ គ.ស.បន្ទាត់ទី២៥, ប្រមានជេង៑វ្នំ pramān jeṅ vnaṃ K.713, ៨៩៣នៃគ.ស.បន្ទាត់ទី២២/ K.878, ៨៩៨នៃគ.ស.បន្ទាត់ទី៥/K.380E,១០៣៨នៃគ.ស.បន្ទាត់ទី២២, ប្រមានិអាយ៑ជ្រៃនណ pramān āy jrainaṇ K.393N, ១០៥៥នៃគ.ស.បន្ទាត់ទី១១, ប្រមានិថាស៑*pramāna* thās K.669D,៩៧២នៃគ.ស.បន្ទាត់ទី៣៩, ប្រមានបូវ៌ pramāna pūrvva K.235D,១០៥២នៃគ.ស. បន្ទាត់ទី៩៨, ប្រមានិបូវ៌ទិគ pramān pūrvvadiça K.668, ៩៧២នៃគ.ស.បន្ទាត់ទី៥, ប្រមានិប្រគាន្តគ្រាម pramān praçānta grāma K.187S,៩៣២នៃគ.ស. បន្ទាត់ទី១, ប្រមានិភីមបុរ pramān bhīmapura K.270N,៩២១នៃគ.ស.បន្ទាត់ទី១៤/K.206,១០៤២នៃគ.ស. បន្ទាត់ទី២០, ប្រមានិមល្យង pramān malyaṅ K.713, ៨៩៣នៃគ.ស.បន្ទាត់ទី១៨/ប្រមានិមល្យាង៑*pramān* malyāṅ K.693,១០០៣នៃគ.ស.បន្ទាត់ទី២៦, ប្រមានិ ល្វោ pramān lvo K.292,១០១១នៃគ.ស.បន្ទាត់ទី១៦, ប្រមានល្ទៅ pramāna ldau K.569,១៣០៦នៃគ.ស.បន្ទាត់ទី៣, ប្រមានិវ្រៃវេក្ក pramān vraivekk K.107,សតវត្សរ៍ទី៧បន្ទាត់ទី២, ប្រមានិវ្យេក៑ pramān vyek K.165,៩៥៧នៃគ.ស.បន្ទាត់ទី១៦, ប្រមានិគត គ្រាម pramān çatagrāma K.989,១០០៨នៃគ.ស.បន្ទាត់ទី៨, ប្រមានិសន្ទុក៑ pramān sanduk K.956,សតវត្សរ៍ទី១០បន្ទាត់ទី៤៧, ប្រមានិគំម្ភុបុរ *pramān* çaṃmbhupura K.125,១០០១នៃគ.ស.បន្ទាត់ទី១៩, ប្រមានស្រី ឥន្ទ្របុរ pramāna çrī indrapura K.105,៩៨៧នៃគ.ស. បន្ទាត់ទី៤, ប្រមានិស្រេឞ្ឋបុរ pramān çreṣṭhapura K.944, ១០០៣នៃគ.ស.បន្ទាត់ទី១២, ប្រមានិអ្មោឃបុរ pramān ᵃmoghapura K.211,១០៣៧នៃគ.ស. បន្ទាត់ទី៣/

K.235D,១០៥២នៃគ.ស.បន្ទាត់ទី១៨, ប្រមានិ ឧគ្របុរ pramān ugrapura K.183,៩២៨នៃគ.ស.បន្ទាត់ទី១១។

តាមរយៈស្ថាននាមដែលប្រើពាក្យសព្ទ **ប្រមានិ/ប្រមាណ** សម្គាល់ដែនដីរដ្ឋបាលនេះ យើងសង្កេតឃើញមានប្រើជាភាសាខ្មែរផងនិងកម្ចីពីភាសាសំស្ក្រឹតផង។

**១.៣-វិស័យ**

ពាក្យសំស្ក្រឹតមានន័យថា តំបន់ ខេត្ត។ ពាក្យ "វិសយ" នេះ សម្រាប់សម្គាល់នូវដែនដីរាជការមួយៗ នៅក្នុងសម័យមុនអង្គរនិងសម័យអង្គរ។ តាមរយៈសិលាចារឹកនានា ពាក្យ "វិសយ" សម្គាល់នូវទីរួមខេត្ត ដែលមានស្ថាប័នរាជការខាងគ្រហស្ថនិងខាងសាសនា ដែលមានដូចជា វិษយកន្ទារ *viṣaya* kandvār K.158D, ១០០៣ នៃគ.ស.បន្ទាត់ទី៦, វិษយករោំviṣaya karoṃ K.235D,១០៥២នៃគ.ស.បន្ទាត់ទី៩៨, ខ្លោញ វិษយខ្ទក viṣaya khdak K.235D,១០៥២នៃគ.ស.បន្ទាត់ទី៨៦-៨៧/ K.524,១១១៧នៃគ.ស. បន្ទាត់ទី៦, វិษយ ជេង៑តរាញ viṣaya jeṅ tarāñ K.466,១០១៥នៃគ.ស.បន្ទាត់ទី៥, វិษយជេង៑វ្នំ viṣaya jeṅ vnaṃ K.235D,១០៥២នៃគ.ស.បន្ទាត់ទី៣, វិษយធាន្យបុរ viṣaya dhānyapura K.966,១១៦៧នៃគ.ស. បន្ទាត់ទី៥, វិษយធម្មបុរ viṣaya dharmmapura K.697B,សតវត្សរ៍ទី១០ បន្ទាត់ទី៨-៩, វិษយនីលកន្ត viṣaya nīlakantha K.380E, ១០៣៨ នៃគ.ស.បន្ទាត់ទី១៥, វិษយបូវ៌្វទិគ viṣaya pūrvva diça K.235D,១០៥២នៃគ.ស.បន្ទាត់ទី២៥, វិษយភីមបុរ viṣaya bhīmapura K.938A,សតវត្សរ៍ទី១១បន្ទាត់ទី១៦, viṣaya maṅgala [pura] K.229, សតវត្សរ៍ទី១១បន្ទាត់ទី៣, វិษយមល្យង៑ viṣaya malyaṅ K.200A,១១៨៥នៃគ.ស.បន្ទាត់ ទី៣, វិษយវិក្រាន្ត viṣaya vikrānta K.830,១១០៦នៃគ.ស.បន្ទាត់ទី៩, វិษយវិជបុរ viṣaya vijapura K.229, សតវត្សរ៍ទី១១ បន្ទាត់ទី៧, វិษយ វិជយបូរ viṣaya vijayapūra K.1074/K.1090,សតវត្សរ៍ទី១១បន្ទាត់ទី១០-១១, វិษយវ្នំកន្សិង៑ *viṣaya* vnaṃ kaṅsin K.105,៩៨៧នៃគ.ស.បន្ទាត់ទី២២-២៣, វិษយវ្យាធបុរ viṣaya vyādha pura K.211,១០៣៧នៃគ.ស. បន្ទាត់ទី១, វិษយគ្រេស្ឋបុរ viṣaya çreṣṭhapura K.143A, សតវត្សរ៍ទី១១ បន្ទាត់ទី១៦-១៧, វិษយសង្ខហ៑ viṣaya saṅkhah K.215,៩៤៩នៃគ.ស.បន្ទាត់ទី១៨, វិษយសន្ទុក viṣaya sanduk K.150, សតវត្សរ៍ទី១០-១១ បន្ទាត់ទី៨, វិษយសេនគិរិ viṣaya senagiri K.549,សតវត្សរ៍ទី១៣ បន្ទាត់ទី២១, វិษយអមោឃបុរ viṣaya amoghapura K.221S,១០១១នៃគ.ស.បន្ទាត់ទី២ ជាដើម។ តាមរយៈស្ថាននាមដែលប្រើពាក្យសព្ទ **វិសយ/វិษយ** នេះ សម្គាល់ដែនដីរដ្ឋបាលនេះ យើងសង្កេតឃើញមានប្រើជាភាសាខ្មែរផងនិងកម្ចីពីភាសាសំស្ក្រឹតផង។

**១.៤-ស្រុក**

ជាទីកន្លែង ស្រុក ភូមិដ្ឋាន សម្រាប់ប្រជាជនរស់នៅ តាមរយៈសិលាចារឹកសម័យមុនអង្គរ គេអាចនិយាយបានថាពាក្យសព្ទនេះជាពាក្យដ៏ចំណាស់មួយដែរក្នុងចំណោមពាក្យចំណាស់ដទៃទៀត នៅក្នុងពាក្យដែលសម្គាល់ស្ថាននាមវិទ្យាទាំងឡាយ។

ស្ថាននាមដែលពាក្យ "ស្រុក" មានដូចជា ស្រុកក្រោង៑ mratāñ khloñ çrī vira vijaya sruk kroṅ chlaṅ gaāṅ drakas K.292,១០១១នៃគ.ស.បន្ទាត់ទី២១, ស្រុក ក្រៅក្រាយ៑ sruk krauv krāy K.292,១០១១នៃគ.ស. បន្ទាត់ទី៣៤, ស្រុកខ្មៅ K.383,១១១២នៃគ.ស.បន្ទាត់ទី៧, ស្រុកខ្ទុល៑ sruk khtul K.292,១០១១នៃគ.ស.បន្ទាត់ទី៣១, ស្រុកខ្យល៑[វក៑] sruk khyal [vak] K.393N, ១០៥៥នៃគ.ស.បន្ទាត់ទី១១, ស្រុកខ្យាត sruk khyāta K.292, ១០១១ នៃគ.ស.បន្ទាត់ទី៣៣, [ស្រុ]កខ្លោញ៑តុំ [sru]k khloṅ tuṃ K.467,១០១១នៃគ.ស.បន្ទាត់ទី២៤, ស្រុកខ្សរ៑ sruk

khvyav K.397,១១១២នៃគ.ស.បន្ទាត់ទី៤, ស្រុកិគង្គា sruk gaṅgā K.467,១០១១នៃគ.ស.បន្ទាត់ទី២២, ស្រុកិគណទារ៉ត្ត sruk gaṇa dār tṛ K.774,៩៨៩ នៃគ.ស.បន្ទាត់ទី៦, ស្រុកិគទុលិ sruk gadul K.476,១០១១នៃគ.ស. បន្ទាត់ទី១៣, ស្រុកិគធិរ sruk gadhira K.292, ១០១១នៃគ.ស.បន្ទាត់ទី២៦, ស្រុកិគម្រ្យាង៑ sruk gamryāṅ K.257N, ៩៩៤នៃគ.ស.បន្ទាត់ទី៤,៧, ស្រុកិ គយ្យ៉ាកិ sruk garyyāk K.229, សតវត្សរ៍ទី១១បន្ទាត់ទី១, ស្រុកិ គល្គុលិ sruk galgul K.292,១០១១នៃគ.ស.បន្ទាត់ទី១២, ស្រុកិគោត្រសេន sruk gotrasena K.256,៩៨៤នៃគ.ស.បន្ទាត់ទី១៩, ស្រុកិគ្នង៑ sruk gnaṅ K.235D, ១០៥២នៃគ.ស.បន្ទាត់ទី១១៤, ស្រុកិតជ្មះគ្នង៑ច្រនាញ៑វោ sruk ta jmaḥ gnaṅ cranāñ vo K.235D,១០៥២ នៃគ.ស.បន្ទាត់ទី១០៦, ខ្លោញកន្តាលិស្រុកិគ្នាក្វន៑ khloñ kantāl sruk gnā kvan K.248,សតវត្សរ៍ទី១១បន្ទាត់ទី១៤-១៥, ស្រុកិគ្នាង៑កន្ទិន៑ sruk gaāṅ kandin K.476,១០១១នៃគ.ស.បន្ទាត់ទី១៩, ស្រុកិគ្នាង៑មរាកិ sruk gaāṅ marāk K.292,១០១១នៃគ.ស.បន្ទាត់ទី៤៣, កំស្តេង៑គ្នាង៑រុង៑ ស្រុកិគ្នាង៑រុង៑ kaṃsteṅ gaāṅ ruṅ sruk gaāṅ ruṅ K.206,១០៤២នៃគ.ស.បន្ទាត់ទី៣១, ស្រុកិគ្នាង៑លំបោះ sruk gaāṅ lampoḥ K.292,១០១១នៃគ.ស. បន្ទាត់ទី២១, ស្រុកិចង្ចិង៑ sruk caṅciṅ K.183,៩២៨នៃគ.ស.បន្ទាត់ទី១០, ស្រុកិ ចតុកណ្ណ៌ sruk catukarṇṇa K.185, សតវត្សរ៍ទី១០បន្ទាត់ទី១៤, ស្រុកិចទោង៑ sruk cadoṅ K.221N,១០១១នៃ គ.ស.បន្ទាត់ទី២, ស្រុកិចន៑ sruk can K.580,សតវត្សរ៍ទី១០បន្ទាត់ទី២២, ស្រុកិចន្ទោង៑ sruk candoṅ K.337, ៨៩៣នៃគ.ស.បន្ទាត់ទី៤, ស្រុកិចន្ហ្វរជ្រៅកន្តាលិ sruk canhvar jrau kantāl K.476,សតវត្សរ៍ទី១២បន្ទាត់ទី២៥, ស្រុកិចន្ហ្វរជ្រៅ ករោំ sruk canhvar jrau karoṃ K.476,សតវត្សរ៍ទី១២បន្ទាត់ទី២៦, ស្រុកិចរង៑ sruk caraṅ K.194, ១១១៩នៃគ.ស.បន្ទាត់ទី៦, ស្រុកិចវលគ្រាម sruk cavalagrāma K.476,១០១១នៃគ.ស.បន្ទាត់ទី២៩, ស្រុកិ ចារ៑សោ sruk cār so K.292E,១០១១នៃគ.ស. បន្ទាត់ទី២០, ស្រុកិចាសិ sruk cās Ka.18A,១០១៤នៃគ.ស.បន្ទាត់ទី៤, ស្រុកិចិត្រលិង sruk citraliṅ K.253, ៩២២ នៃគ.ស.បន្ទាត់ទី១, ស្រុកិចុង៑ឆោកិ sruk cuṅ chok K.476, ១០១០នៃគ.ស.បន្ទាត់ទី២៧, ស្រុកិចុង៑ឆ្ទិង៑ sruk cuṅ chdiṅ K.754,១៣០៨នៃគ.ស.បន្ទាត់ទី៤, ស្រុកិចុង៑វិសិ sruk cuṅ vis K.238A, ៩៤៩នៃគ.ស.បន្ទាត់ទី៣, ស្រុកិចុម្មោង៑លេវ្នំ sruk currmmoṅ le vnaṃ K.292E,១០១១នៃគ.ស.បន្ទាត់ទី២៧, ស្រុកិចេកតេំសំម្រោង៑sruk cek teṃ saṃmroṅ K.292E,១០១១នៃគ.ស.បន្ទាត់ទី៤០, ស្រុកិ ចំកា sruk caṃkā K.262N,៩៨២នៃគ.ស.បន្ទាត់ទី១៥, ស្រុកិចំកាបុរុឞ sruk caṃkā puruṣa K.183,៩២៨នៃគ.ស.បន្ទាត់ទី៧, ស្រុកិ ចំកាស្ទាង៑ sruk caṃkā sdāṅ K.292, ១០១១នៃគ.ស.បន្ទាត់ទី២២, ស្រុកិចំនតកន្តាលិ sruk caṃnat kantāl K.292E,១០១១នៃគ.ស.បន្ទាត់ទី៣៨, ស្រុកិចំនតត្រកាលិ sruk caṃnat trakāl K.292E, ១០១១នៃគ.ស.បន្ទាត់ទី៣៨, ស្រុកិចំនតធលា sruk caṃnat dhalā K.292,១០១១នៃគ.ស.បន្ទាត់ទី៣៤, ស្រុកិ ចំពោកិ sruk campok K.344,៩៨៥នៃគ.ស.បន្ទាត់ទី១៩, ស្រុកិច្រលះ sruk cralaḥ K.183,៩២៨នៃគ.ស.បន្ទាត់ទី១, ស្រុកិ ច្រលុះ sruk craluḥ K.1051,៩១៥នៃគ.ស. បន្ទាត់ទី១១, ស្រុកិច្ឫសិគ្នាង៑គ្រៅលេវ្នំលោ sruk cṛs gaāṅ grau le vnaṃ lo K.292N,១០១១នៃគ.ស.បន្ទាត់ទី១៤, ស្រុកិច្វរមោ K.235D, ១០៥២នៃគ.ស.បន្ទាត់ទី១០៥, ស្រុកិច្វរ៑ឥតិ sruk cvar it K.467,១០១១នៃគ.ស.បន្ទាត់ទី១៩, ស្រុកិច្អាលិត្ឫ sruk c-āl tṛ K.292,១០១១នៃ គ.ស.បន្ទាត់ទី៣៤, ស្រុកិឆោកិកណ្ឌាំ sruk chok kaṇdā [ṃ] K.188,៩២៩នៃគ.ស.បន្ទាត់ទី៥, ស្រុកិឆោកិវកុល sruk chok vakula K.397,១១១២នៃគ.ស.បន្ទាត់ទី១, ស្រុកិឆោកិត្របេកិ sruk chok trapek K.165N,៩៥៧នៃ គ.ស.បន្ទាត់ទី៩, ស្រុកិឆោកិទង៑ទ្រង៑ sruk chok daṅdraṅ K.476,សតវត្សរ៍ទី១២បន្ទាត់ទី១៦, ស្រុកិឆោកិវល្វលិ sruk chok valval K.697B,សតវត្សរ៍ទី១០បន្ទាត់ទី២, ស្រុកិឆោកិវេង៑ sruk chok veṅ K.720, ១០០៦នៃគ.ស. បន្ទាត់ទី១៧, ស្រុកិ ឆ្ទិង៑គ្រគ្យរ៑ sruk chdiṅ gragyar K.292, ១០១១នៃគ.ស.បន្ទាត់ទី៥៨, ស្រុកិ

ឆ្ទិងស្តោក sruk chdiṅ stok K.31,១០១៩នៃគ.ស.បន្ទាត់ទី៤, ស្រុកឆ្ទ្យារ sruk chdyār K.467,១០១១នៃគ.ស.បន្ទាត់ទី២២, ស្រុកជតាក sruk jatāk K.292,១០១១នៃគ.ស.បន្ទាត់ទី២៤, ស្រុកជតាលិង្គ sruk jatāliṅga K.100, សតវត្សរ៍ទី១០បន្ទាត់ទី១, ស្រុក ជយក្សេត្រ sruk jayakṣetra K.832, សតវត្សរ៍ទី១០បន្ទាត់ទី១, ស្រុកជយគ្រាម sruk jayagrāma K.313a,៨៧៩ នៃគ.ស.បន្ទាត់ទី២, ស្រុកជរោយចារ sruk jaroy cār K.218,សតវត្សរ៍ទី១១បន្ទាត់ទី៩, ស្រុកជជោរ sruk jarjor K.175N,សតវត្សរ៍ទី១០បន្ទាត់ទី៩, ខ្ញាសិស្រុក ជៃមាល gnaṅ khvos sruk jaimāla K.292, ១០១១នៃគ.ស.បន្ទាត់ ទី២៦, ស្រុកជេង៍គ្នង៍ sruk jeṅ gnaṅ K.183, ៩២៨នៃគ.ស.បន្ទាត់ទី៦, ស្រុកជេង៍ធលា ចំអ្យាត sruk jeṅ dhalā caṃayāt K.292,១០១១នៃគ.ស.បន្ទាត់ទី៣១, ស្រុកជំន្យកតិ sruk jaṃnyak ti K.292E, ១០១១នៃគ.ស.បន្ទាត់ទី៣០, ស្រុកជំរៅភិមបុរ sruk jaṃrau bhimapura K.183,៩២៨នៃគ.ស.បន្ទាត់ទី១៣-១៤, ស្រុកជ្រៃគយ្យាក sruk jrai garyyāk K.221,១០១១នៃគ.ស.បន្ទាត់ទី៥, ស្រុកឈេរឡោំ sruk jhe rloṃ K.235D,១០៥២នៃគ.ស.បន្ទាត់ទី១១២, ស្រុកតង្កាល៑ sruk taṅkāl K.194,១១១៩ នៃគ.ស.បន្ទាត់ទី៤៣, ស្រុកតន្លោះ sruk tanloḥ K.292E, ១០១១នៃគ.ស.បន្ទាត់ទី៣៨, ស្រុកតបោវន sruk tapovana K.809,៨៧៨-៨៨៨នៃគ.ស.បន្ទាត់ទី២៤, ស្រុក តរញ៉កន្ទិន sruk tarañ kandin K.1036A, សតវត្សរ៍ ទី១២បន្ទាត់ទី២៧, ស្រុក តេំតន្នោត sruk teṃ tannot K.257, ៩៩៤នៃគ.ស.បន្ទាត់ទី២៣, ស្រុកតេំថ្ញាន sruk teṃ thṅān K.292, ១០១១នៃគ.ស.បន្ទាត់ទី១៩, ស្រុកតំទោង៑ sruk taṃdoṅ K.183,៩២៨នៃគ.ស.បន្ទាត់ទី២៤, ស្រុកតេំវល្វល៑ sruk teṃ valvval K.206,១០៤២នៃគ.ស. បន្ទាត់ទី៤, ស្រុកតេំស្វាយសំសាំ sruk teṃ svāy saṃsāṃ K.467, ១០១១នៃគ.ស.បន្ទាត់ទី២៩, ស្រុកតេំស្វី sruk teṃ svī K.152,សតវត្សរ៍ទី១០-១១បន្ទាត់ទី៥, ស្រុកតោហ៑ តាហ៑ sruk toh tāh K.183, ៩២៨នៃគ.ស.បន្ទាត់ទី១, ស្រុកតំបោល៑ sruk taṃpol K.262S,៩៨២នៃគ.ស.បន្ទាត់ទី១២, [ស្រុ]កតំល្វាន [sru]k taṃlvān K.292,១០១១ នៃគ.ស.បន្ទាត់ទី២៤, ស្រុកតំវ្វង៑ sruk taṃvvaṅ K.215, ៩៩៩នៃគ.ស.បន្ទាត់ទី១៧, ស្រុកត្រលៅ sruk tralau K.105,៩៨៧នៃគ.ស.បន្ទាត់ទី១១, ស្រុកត្រវាង៑កំទ្វាត sruk travāṅ kaṃdvāt K.843A, ១០២៥នៃគ.ស.បន្ទាត់ទី១១, ស្រុកត្រវាង៑ក្រូច sruk travāṅ krvac K.852, ១១០៧នៃគ.ស.បន្ទាត់ទី៨, ស្រុកត្រវាង៑ក្រូស៑ sruk travāṅ krvas K.292,១០១១នៃគ.ស.បន្ទាត់ទី១៣, ស្រុក ត្រវាង៑កំទ្វាត sruk travāṅ kaṃdvāt K.843A, ១០២៥នៃគ.ស. បន្ទាត់ទី១១, ស្រុកត្រវាង៑ខ្លុង៑ sruk travāṅ khluṅ K.467,១០១១នៃគ.ស.បន្ទាត់ទី១៣, ស្រុកត្រវាង៑គុរុ sruk travāṅ guru K.598 B,១០០៦នៃគ.ស.បន្ទាត់ទី២៥, ស្រុកត្រវាង៑ជ្វិក sruk travāṅ jvik K.32,១១១៦ នៃគ.ស.បន្ទាត់ទី១៩, ស្រុកត្រវាង៑ទ្យំ sruk travāṅ dyaṃ K.292, ១០១១នៃគ.ស.បន្ទាត់ទី២៩, ស្រុកត្រវាង៑វោ sruk travāṅ vo K.393N,១០៥៥នៃគ.ស.បន្ទាត់ទី8, ស្រុកត្រវាង៑ សង្កោ sruk travāṅ saṅko K.205,១០៣៦នៃគ.ស.បន្ទាត់ទី១៦, ស្រុកត្រាច Ka.18,១០១៤នៃគ.ស.បន្ទាត់ទី២៨, ស្រុកត្រី sruk trī K.476,សតវត្សរ៍ទី១២បន្ទាត់ទី១៧, ស្រុក ត្រាំទាហ sruk trāṃ dāha K.476, សតវត្សរ៍ទី១២ បន្ទាត់ទី២០, ស្រុកត្វង៑ជេង៑ sruk tvaṅ jeṅ K.383, ១១២១នៃ គ.ស.បន្ទាត់ទី៧, ស្រុកត្វងម្វាយតេំ sruk tvaṅ mvāy teṃ K.235D, ១០៥២នៃគ.ស.បន្ទាត់ទី១១២, ស្រុកថ្កល៑ sruk thkval K.207,១០៤២នៃគ.ស.បន្ទាត់ទី១៧, ស្រុកថ្កល៑ធំ sruk thkval dhaṃ K.105,៩២១នៃគ.ស.បន្ទាត់ទី៦, ស្រុកថ្កាល៑ជោង៑ sruk thkvāl joṅ K.425,៩៦៨ នៃគ.ស.បន្ទាត់ទី១៥-១៦, ស្រុកថ្នល៑ sruk thnal K.105, ៩៨៧នៃគ.ស.បន្ទាត់ទី១២, ស្រុកថ្នល៑ភ្វាស៑ sruk thnval bhvās K.231,៩១០នៃគ.ស.បន្ទាត់ទី៣២, ស្រុកថ្ប្ល៑ ក្រសាង៑ sruk thpal krasāṅ K.292 E,១០១១នៃ គ.ស.បន្ទាត់ទី៤៨, ស្រុកថ្ប្ល៑ចារsruk thpal cār K.829,សតវត្សរ៍ទី១១បន្ទាត់ទី៨, ស្រុកថ្ប្ល៑ជ្មស៑ sruk thpal jmas K.476, ១០១១នៃគ.ស.បន្ទាត់ទី១០, ស្រុកថ្ប្ល៑តង្កោ sruk

thpal taṅko K.292,១០១១នៃគ.ស.បន្ទាត់ទី១៤, ស្រុកថ្បល់ វិនៅវ៍ sruk thpal vinauv K.292,១០១១នៃគ.ស. បន្ទាត់ទី៤៩, ស្រុកថ្បល់សំពោង K.292N, ១០១១នៃគ.ស.បន្ទាត់ទី១៣, ស្រុកថ្បល់ស្វាះ sruk thpal svāḥ K.467, ១០១១នៃគ.ស.បន្ទាត់ទី២៦, ស្រុក ថ្បល់អំវិល sruk thpal aṃvil K.292,១០១១នៃគ.ស.បន្ទាត់ទី៣២, ស្រុកថ្បាល់ sruk thpāl K.467,១០១១នៃ គ.ស.បន្ទាត់ទី១៥, ស្រុកថ្បង sruk thpvaṅ K.183,៩២៨នៃគ.ស.បន្ទាត់ទី?, ស្រុកថ្មី sruk thmi K.843A,១០២៥ នៃគ.ស.បន្ទាត់ទី២៨, ស្រុកថ្មោបាយ sruk thmo pāy K.175N,សតវត្សរ៍ទី១០ បន្ទាត់ទី២-៣, ស្រុកថ្មោយោល sruk thmo yol K.183, ៩២៨នៃគ.ស.បន្ទាត់ទី១,៣, ស្រុកថ្មោវ្វក sruk thmo vvak K.292,១០១១នៃគ.ស. បន្ទាត់ទី២៥, ស្រុកទន្ទេន sruk danden K.532B,១១១៨នៃគ.ស.បន្ទាត់ទី២០, ស្រុកទន្លេជ្រៃ sruk danle jrai K.933,១០១២នៃគ.ស. បន្ទាត់ទី៩, ស្រុកទឝគ្រាម sruk daçagrāma K.258B,១១០៧ នៃគ.ស.បន្ទាត់ទី១៣, ស្រុកទាន្យកតិក sruk dānyakatika K.598,១០០៦នៃគ.ស.បន្ទាត់ទី២៨, ស្រុកទុវ្វន sruk durvvana K.966, ១១៦៧នៃគ.ស.បន្ទាត់ទី៣២, ស្រុកទេវីគ្រាម sruk devīgrāma K.158B,១០០៣នៃគ.ស. បន្ទាត់ទី៣២, ស្រុក ទំទៅវ៍ sruk daṃdauv K.292, ១០១១នៃគ.ស.បន្ទាត់ទី៤២, ស្រុកទំទាំ sruk daṃdāṃ K.754, ១៣០៨នៃគ.ស. បន្ទាត់ទី១១, ស្រុកទំនប់ sruk daṃnap K.184,៩២១នៃគ.ស.បន្ទាត់ទី១២, ស្រុកទំនប់បាក់ sruk daṃnap pāk K.467,១០១១នៃគ.ស.បន្ទាត់ទី២៨, ស្រុកទ្យាង sruk dyāṅ K.292,១០១១នៃគ.ស.បន្ទាត់ទី៣៣, ស្រុកទ្រទោច sruk dradoc K.1034,៨៩៥នៃគ.ស.បន្ទាត់ទី១៣, ស្រុកទ្រលេំ sruk dralem̥ K.292,១០១១ នៃគ.ស.បន្ទាត់ទី ២០, ស្រុកទ្រលោង sruk draloṅ K.292E,១០១១នៃគ.ស.បន្ទាត់ទី៤២, ស្រុកទ្វារវតី sruk dvāravatī K.165N, ៩៥៧នៃគ.ស.បន្ទាត់ទី១៣, ស្រុកធនវាហ sruk dhanavāha K.476,១០១១នៃគ.ស.បន្ទាត់ទី១៦, ស្រុកធនិរា ល័យ sruk dhanirālaya K.183,៩២៨ នៃគ.ស.បន្ទាត់ទី១០, ស្រុកធលាកន្សិង sruk dhalā kansiṅ K.292E, ១០១១នៃគ.ស.បន្ទាត់ទី២៨, ស្រុកនាគ បត្តន sruk nāgapattana K.238,៩៤៩នៃគ.ស.បន្ទាត់ទី៨,១០, ស្រុក នាគបុរ sruk nāgapura K.292,១០១១នៃ គ.ស.បន្ទាត់ទី២១, ស្រុកបញ្ចគវ្យ sruk pañcagavya K.100,សតវត្សរ៍ ទី១០បន្ទាត់ទី១, ស្រុកបទមូល sruk padamūla K.569,១៣០៦នៃគ.ស.បន្ទាត់ទី១២, ស្រុកបន្រុក sruk *panruk* K.312a,៨៧៩នៃគ.ស.បន្ទាត់ទី២៣, ស្រុកបរស្ស sruk parass K.956,៩៤៧នៃគ.ស.បន្ទាត់ទី៨, ស្រុកបរាឝរ sruk parāçara K.235D,១០៥២នៃគ.ស.បន្ទាត់ទី៣០, ស្រុកបឱង sruk pa-oṅ K.292E, ១០១១នៃគ.ស. បន្ទាត់ទី៣៧, ស្រុកបាណិ sruk pāṇi K.809,៨៧៨នៃគ.ស.បន្ទាត់ទី៩/ស្រុកបានិ sruk pāni K.809,៨៧៨នៃ គ.ស.បន្ទាត់ទី៨, ស្រុកបាសខ្មៅ sruk pās khmau K.192,៩៥៦នៃគ.ស.បន្ទាត់ទី១៨, ស្រុកបាន្ទុគារ sruk pāndugāra K.233,សតវត្សរ៍ទី១០ បន្ទាត់ទី៩, ស្រុកបុរុេ sruk puruṣa K.105,៩៨៦នៃគ.ស. បន្ទាត់ទី១១, ស្រុកបុរុេបុរ sruk puruṣapura K.105,៩៨៧នៃគ.ស.បន្ទាត់ទី១១,១២, ស្រុកបុលាយ sruk pulāy K.183, ៩២៨ នៃគ.ស.បន្ទាត់ទី១០, ស្រុកបូវ្វាឝ្រម sruk pūrvvāçrama K.207,១០៤២នៃគ.ស.បន្ទាត់ទី៦០, ស្រុក បំរុះ sruk paṃruḥ K.475,១០១១ នៃគ.ស.បន្ទាត់ទី១៨, ស្រុកប្តច sruk ptac K.292, ១០១១នៃគ.ស.បន្ទាត់ទី៣១, ស្រុកប្រជល់ sruk prajal K.319,៨៧៩នៃគ.ស.បន្ទាត់ទី១, ស្រុកប្រទាហ sruk *pradāha* K.292,១០១១នៃគ.ស. បន្ទាត់ទី១២, ស្រុកប្រនោង sruk *pranoṅ* K.292,១០១១នៃគ.ស.បន្ទាត់ទី៣៣, ស្រុកប្រលាយស្លា sruk *pralāy slā* K.207,១០១៤នៃគ.ស.បន្ទាត់ទី២៥, ស្រុកប្ឫ sruk pr̥ K.158B, ១០០៣នៃ គ.ស.បន្ទាត់ទី៣១, ស្រុក

ផលប្រិយ sruk *phalapriya* K.67A,សតវត្សរ៍ទី១១-១២បន្ទាត់ទី៧/ K.67B, សតវត្សរ៍ទី១១-១២បន្ទាត់ទី៣, ស្រុកផ្ចិកិច្វាង sruk *phcik chvāṅ* K.292,១០១១នៃគ.ស.បន្ទាត់ទី១៨, ស្រុកភគវតជ្លំ sruk *bhagavata jlaṃ* K.183,៩២៨នៃគ.ស.បន្ទាត់ទី៣០, ស្រុកភទ sruk *bhada* K.320b, ៨៧៩នៃគ.ស.បន្ទាត់ទី២០, ស្រុកភទ្រគិរិជេងវ្នំ sruk *bhadragiri* jeṅ vnaṃ K.235D,១០៥២នៃ គ.ស.បន្ទាត់ទី១១, ស្រុកជ្មះភទ្រនិកេតនsruk jmaḥ *bhadraniketana* K.235D,១០៥២នៃគ.ស.បន្ទាត់ទី៧៥, ស្រុកជ្មះ ភទ្រយោគិ sruk jmaḥ *bhadrayogi* K.235C,១០៥២នៃគ.ស.បន្ទាត់ទី៦០, ស្រុកភទ្រសិង្ហ sruk *bhadrasiṅha* K.292,១០១១នៃគ.ស.បន្ទាត់ទី២៧, ស្រុកភទ្រាលយ sruk *bhadrālaya* K.262N,៩៨២ នៃ គ.ស.បន្ទាត់ទី៤០, ស្រុកភទ្រាវាស sruk *bhadrāvāsa* K.235D,១០៥២នៃគ.ស.បន្ទាត់ទី១៧,៤៨,ស្រុក ភទ្រេឝ្វរាស្បទ sruk *bhadreçvarāspada* K.475,១១៣៦នៃគ.ស.បន្ទាត់ទី១, ស្រុកភរណី sruk *bharaṇī* K.221,១០១១នៃគ.ស.បន្ទាត់ទី២,១១, ស្រុកភរោវផ្ទិរ៑ sruk *bharov phtir* K.476,១០១១នៃគ.ស.បន្ទាត់ទី ២៤, ស្រុកភវហ្រាម sruk *bhavahrāma* K.383, ១១២១នៃគ.ស.បន្ទាត់ទី៣៩, ស្រុកភវាលយ sruk bhavālaya K.235D,១០៥២នៃគ.ស.បន្ទាត់ទី១១, ស្រុកភិនវគ្រាម sruk *bhinavagrāma* K.248,សតវត្សរ៍ទី១១បន្ទាត់ ទី១៦, ស្រុកភោគបុរ sruk *bhogapura* K.843A, ១០២៥នៃគ.ស.បន្ទាត់ទី៣, ស្រុកភ្ឫត្តិបូរ sruk *bhṛttipūra* K.292,១០១១នៃគ.ស.បន្ទាត់ទី១៣, ស្រុកមង្គលបុរ sruk *maṅgalapura*K.205,១០៣៦នៃគ.ស.បន្ទាត់ ទី១៨/K.206,១០៤២នៃគ.ស.បន្ទាត់ទី៣៧, ស្រុកមធុរបុរ sruk *madhurapura* K.221N,១០១១នៃគ.ស.បន្ទាត់ទី១៨/K.292,១០១១នៃគ.ស.បន្ទាត់ទី៤១, ស្រុកមធុសូទន sruk *madhusūdana* K.263,៩៨៤នៃ គ.ស.បន្ទាត់ទី១៩, ស្រុកមធ្យមទេឝ sruk *madhyama deça* K.194,១១១៩នៃគ.ស.បន្ទាត់ទី៤៣, ស្រុក មនោ sruk *mano* K.235D,១០៥២នៃគ.ស.បន្ទាត់ទី៧០, ស្រុកមហានស sruk *mahānasa* K.183,៩២៨នៃ គ.ស.បន្ទាត់ទី១, ស្រុកមហាលោហ sruk *mahāloha* K.183, ៩២៨នៃគ.ស.បន្ទាត់ទី៣០, ស្រុកមហេឝ្វរា លយ sruk *maheçvarālaya* K.467,១០១១នៃគ.ស. បន្ទាត់ទី២៧, ស្រុកមាង៑គ្យាង sruk māṅ gyāṅ K.292, ១០១១នៃគ.ស.បន្ទាត់ទី២២, ស្រុកមាង៑គ្យាង៑ក្រអាលិsruk *māṅ gyāṅ kraāl*K.292,១០១១នៃគ.ស.បន្ទាត់ទី៣២, ស្រុកមុំវ្រ្យង៑ sruk *muṃ vryaṅ* K.873,៩២១នៃគ.ស.បន្ទាត់ទី៤, ស្រុកមូល sruk *mūla* K.67, សតវត្សរ៍ទី១១-១២បន្ទាត់ទី២, ស្រុកយនប៑ sruk *yanap* K.221S,១០១១នៃគ.ស.បន្ទាត់ទី៨, ស្រុកយោធាបុរ sruk *yodhāpura* K.344,៩៨៥នៃគ.ស.បន្ទាត់ទី១៥, ស្រុករម្មាង៑ថឱក៑ sruk rmmāṅ tha-ok K.185,សតវត្សរ៍ទី ១០ បន្ទាត់ទី៩, ស្រុករាជកុល sruk rājakula K.380D, ១០៣៨នៃគ.ស.បន្ទាត់ទី១៨, ស្រុកជ្មះលក្ស្មីន្ទ្របទ sruk jmaḥ *lakṣmīndrapada* K.702,១០២៥នៃគ.ស.បន្ទាត់ទី៥, ស្រុកលម្ភបុរ៑ sruk *lambhapura* K.292,១០១១ នៃគ.ស.បន្ទាត់ទី២៣, ស្រុកលាង៑ sruk *lāṅ* K.292N,១០១១នៃគ.ស.បន្ទាត់ទី១៦, ស្រុកលុន៑ sruk *lun* K.754, ១៣០៨នៃគ.ស.បន្ទាត់ទី២៨, ស្រុកលេងត្វរ៑ sruk *leṅ tvar* K.235D,១០៥២នៃគ.ស. បន្ទាត់ទី១០១/ស្រុក លេង៑ត្វរ៑ sruk leṅ tvar K.235D,១០៥២នៃគ.ស. បន្ទាត់ទី១០២, ស្រុកលំ sruk *laṃ* K.189,

៩២៨នៃគ.ស. បន្ទាត់ទី៣, ស្រុកលំអ្វ sruk laṃ ava K.189,៩២៨នៃ គ.ស.បន្ទាត់ទី២-៣, ស្រុកវកោង sruk *vakoṅ* K.320A,៨៧៩ នៃគ.ស.បន្ទាត់ទី២២, ស្រុកវង sruk *vaṅ* K.184,៩២១នៃគ.ស.បន្ទាត់ទី១០, ស្រុកវជ្រវម៌្ម sruk *vajravarmma* K.235D,១០៥២នៃគ.ស.បន្ទាត់ទី១១, ស្រុកវទរា sruk *vadarā* K.208,សតវត្សរ៍ទី១១ បន្ទាត់ទី៥២, ស្រុកវនបុរ sruk *vanapura* K.957,៩៤១នៃគ.ស.បន្ទាត់ទី៣/ K.669,៩៧២នៃគ.ស.បន្ទាត់ទី៦,៧, ស្រុកវន្ហាំ sruk *vanhāṃ* K.292,១០១១នៃគ.ស.បន្ទាត់ទី២៣, ស្រុកវរុណ sruk *varuṇa* K.262S,៩៨២នៃគ.ស.បន្ទាត់ទី១៣, ស្រុកវណ្ណ sruk varnṇa K.262S,៩៨២នៃគ.ស.បន្ទាត់ទី៤៨, ស្រុកវសន្តបូរ sruk *vasantapūra* K.221, ១០១១នៃគ.ស.បន្ទាត់ទី៣, ស្រុកវាកលេ sruk *vāk* le K.292,១០១១នៃគ.ស.បន្ទាត់ទី២២, ស្រុកវាគិន្ទ្រ [បត្តន] sruk *vāgindra [pattana]* K.466,១០១៥នៃគ.ស.បន្ទាត់ទី៤, ស្រុកវិក្រមបុរ sruk *vikramapura* K.467, ១០១១នៃគ.ស.បន្ទាត់ទី២៨, ស្រុកវិក្រាន្តបុរ sruk *vikrāntapura* K.697,សតវត្សរ៍ទី១០បន្ទាត់ទី២១, ស្រុកវិជយបុរ sruk *vijayapura* K.227,សតវត្សរ៍ទី១៣ បន្ទាត់ទី២៤, ស្រុកវិណវបុរ sruk viṇavapura K.105,៩៨៧នៃគ.ស.បន្ទាត់ទី១៣, ស្រុកវិទ្យាវាស sruk *vidyāvāsa* K.617,សតវត្សរ៍ទី១០បន្ទាត់ទី១៩, ស្រុកវិនៅ sruk *vinau* K.292E,១០១១នៃគ.ស.បន្ទាត់ទី២៧, ស្រុកវិភេទ sruk *vibheda* K.380,១០៣៨នៃគ.ស.បន្ទាត់ទី២៣, ស្រុកវិស្ណុបទ sruk *viṣṇupada* K.292,១០១១នៃគ.ស.បន្ទាត់ទី១៩, ស្រុកវិស្ណុបុរ sruk*viṣṇu pura* K.315b, ៨៧៩ នៃគ.ស.បន្ទាត់ទី១៥, ស្រុកវិស្ណ្វាលយsruk viṣṇvālaya K.91C, សតវត្សរ៍ទី១២បន្ទាត់ ទី១, ស្រុកវីរេន្ទ្រ sruk *vīrendra* K.183,៩២៨នៃគ.ស.បន្ទាត់ទី១, ស្រុកវីរេន្ទ្របត្តន sruk *vīrendrapattana* K.713,៨៩៣នៃគ.ស.បន្ទាត់ទី២១, ស្រុកវេលាខ្តាំ sruk *velā khtāṃ* K.476,១០១១នៃគ.ស.បន្ទាត់ទី១៨, ស្រុកវោច្រមុល sruk *vo* cramul K.200B,១១៤៥នៃគ.ស.បន្ទាត់ទី៤, ស្រុកវ្ទាង sruk *vdāṅ* K.412,សតវត្សរ៍ ទី១១បន្ទាត់ទី១២, ស្រុកវ្នុរ sruk vnur K.105,៩៨៧នៃគ.ស.បន្ទាត់ទី៧, ស្រុក វ្នុរកំទ្វាត sruk vnur kaṃdvāt K.211,១០៣៧នៃគ.ស.បន្ទាត់ទី១, ស្រុកវ្នុរខ្វេកកន្តាល sruk *vnur khvek kantāl* K.817,១០០២នៃគ.ស.បន្ទាត់ទី១០, ស្រុកវ្នុរ ខ្វេកករោំ sruk*vnur khvek karoṃ* K.817,១០០២នៃគ.ស.បន្ទាត់ទី១១, ស្រុកវ្នុរខ្វេក លេ sruk *vnur khvek le* K.817, ១០០២នៃគ.ស.បន្ទាត់ទី៨, ស្រុកវ្នុរចំបោក sruk *vnur campok* K.184,៩២១នៃគ.ស.បន្ទាត់ទី១៦, ស្រុកវ្នុរតង្កោsruk *vnur taṅko* K.184,៩២១នៃគ.ស. បន្ទាត់ទី៦-៧, ស្រុកវ្នំ ប្រអប sruk *vnaṃ praap* K.219, ១០៥៤ នៃគ.ស.បន្ទាត់ទី២៣, ស្រុកវ្យៅ sruk *vyau* K.183,៩២៨នៃគ.ស.បន្ទាត់ទី១, ស្រុកវ្យៅករោំ sruk *vyau* karoṃ K.183,៩២៨នៃគ.ស.បន្ទាត់ទី១៨-១៩, ស្រុកវ្យៅលេ sruk vyau le K.183,៩២៨នៃគ.ស.បន្ទាត់ទី៤-៥, ស្រុកវ្រច sruk*vrac* K.829,សតវត្សរ៍ទី១១បន្ទាត់ទី១៤, ស្រុកវ្រលេង sruk *vraleṅ* K.326,៨៩៣នៃគ.ស.បន្ទាត់ទី៣, ស្រុកវ្រហ្មបុរ sruk vrahmapura K.235D, ១០៥២នៃគ.ស.បន្ទាត់ទី ៣៨, ស្រុកវ្រាច sruk *vrāc* K.292N, ១០១១នៃគ.ស.បន្ទាត់ទី១២, ស្រុកវ្រៃកក sruk *vrai kak* K.56A,សតវត្សរ៍ ទី១០បន្ទាត់ទី២៧, ស្រុកវ្រៃករង sruk *vrai karaṅ* K.598B, ១០០៦នៃគ.ស.បន្ទាត់ទី៤, ស្រុកវ្រៃចាសតំនាំ sruk *vrai cās taṃnāṃ* K.292, ១០១១នៃគ.ស.បន្ទាត់ទី១៧, ស្រុកវ្រៃតែំថ្និង sruk*vrai teṃ thniṅ* K.105, ៩៨៦នៃគ.ស.បន្ទាត់ទី១៤, ស្រុក វ្រៃត្បេង sruk vrai tpeṅ K.292, ១០១១នៃគ.ស.បន្ទាត់ទី៣៦, ស្រុកវ្រៃ ត្រពេក sruk *vrai trapek* K.720B, ១០០៦នៃគ.ស.បន្ទាត់ទី១៦, ស្រុកវ្រៃទិង sruk *vrai diṅ* K.183,928 ៩២៨នៃគ.ស.បន្ទាត់ទី12, ភូមិស្រុកវ្រៃវង ចន្ទ្រាយ sruk vrai

ramvaṅ candrāy K.235D,១០៥២នៃគ.ស. បន្ទាត់ទី១០៩, ស្រុកវ្រៃអ្គុយ sruk *vrai ᵃguy* K.235D, ១០៥២ នៃគ.ស.បន្ទាត់ទី៩៦, ស្រុកវ្រះគ្អាង sruk *vraḥ gaāṅ* K.292E,១០១១នៃគ.ស.បន្ទាត់ទី២២, ស្រុកវ្រះទំនប sruk *vraḥ daṃnap* K.782,១០៧១នៃ គ.ស.បន្ទាត់ទី១១,១៦, ស្រុកវ្រះបយ្យ៉ង sruk *vraḥ paryyaṅ* K.207, ១០៤២នៃគ.ស.បន្ទាត់ទី៤៧-៤៨, ស្រុក វ្រះផ្ចិក sruk *vraḥ phcik* K.292E,១០១១នៃ គ.ស.បន្ទាត់ទី៣៩, ស្រុកវ្រះវ្រ្យង sruk *vraḥ vryaṅ* K.205, ១០៣៦នៃគ.ស.បន្ទាត់ទី៧, ស្រុក្កវ្រះស្បំ srukk *vraḥ spaṃ* K.570,៩៦៩ នៃគ.ស.បន្ទាត់ទី៤០, ស្រុកវ្រះឥត sruk *vraḥ ĩt* K.754,១៣០៨នៃគ.ស.បន្ទាត់ទី៣០, ស្រុកវ្ឫទ្ធនិវាស sruk *vṛddhanivāsa* K.175N,សតវត្សរ៍ទី១០បន្ទាត់ទី៧, ស្រុកវ្លុក sruk *vluk* K.182,សតវត្សរ៍ ទី១០បន្ទាត់ទី៥, ស្រុកវ្លោក sruk *vlok* K.153,១០០១នៃគ.ស.បន្ទាត់ទី១, ស្រុកវ្លោង sruk *vloṅ* K.292, ១០១១នៃគ.ស.បន្ទាត់ទី៣១, ស្រុកឝង្ករយាគ sruk *çaṅkarayāga* K.188,៩១៩នៃគ.ស.បន្ទាត់ទី១២-១៣, ស្រុកសង្កេ sruk *saṅke* K.669D,៩៧២នៃគ.ស.បន្ទាត់ទី២៦, ស្រុកឝតគ្រាម sruk çatagrāma K.235C, ១០៥២នៃគ.ស.បន្ទាត់ទី៥៩, ស្រុកសន្តោម sruk *santoma* K.989B,១០០៨នៃគ.ស.បន្ទាត់ទី២៦, ស្រុក សប្តាហ sruk *saptāha* K.774,៩៨៩ នៃគ.ស. បន្ទាត់ទី២, ស្រុកសមភូមិ sruk *samabhūmi* K.292,១០១១ នៃគ.ស.បន្ទាត់ទី៣៧, ស្រុកសមវ៌ច sruk *samarvac* K.598B,១០០៦នៃគ.ស.បន្ទាត់ទី២៨, ស្រុកឝម្ភុគ្រាម sruk *çambhugrāma* K.292,១០១១នៃគ.ស.បន្ទាត់ទី ៣៦, ស្រុកសម្ឫទ្ធបុរ sruk *samṛddhapura* K.467, ១០១១នៃគ.ស.បន្ទាត់ទី២៥, ស្រុកសរាំ sruk *sarāṃ* K.292,១០១១នៃគ.ស.បន្ទាត់ទី១៣, ស្រុកសវ៌្វសុខ sruk *sarvvasukha* K.256,៩៨៤នៃគ.ស.បន្ទាត់ទី ១៨, ស្រុកសហការ sruk *sahakāra* K.165,៩៥៧នៃគ.ស.បន្ទាត់ទី៦, ស្រុកសាង្តេ sruk *sāṅte* K.292,១០១១ នៃគ.ស.បន្ទាត់ទី២៧, ស្រុកសិទ្ធិបុរ sruk *siddhipura* K.702, សតវត្សរ៍ទី១១បន្ទាត់ទី៣, ស្រុកសិន្ទូរ sruk *sindūra* K.809,៨៧៨-៨៨៨នៃគ.ស.បន្ទាត់ទី១១, ស្រុកឝិវគភ៌ sruk *çivagarbha* K.809,៨៧៨-៨៨៨នៃគ.ស. បន្ទាត់ទី៣, ស្រុកឝិវគុប្ត sruk *çivagupta* K.212A,១០២៧ នៃគ.ស.បន្ទាត់ទី២៤, ស្រុកឝិវនិវាស sruk *çivanivāsa* K.682,៩២១នៃគ.ស.បន្ទាត់ទី៨, ស្រុកឝិវបត្តន sruk çivapattana K.235,១០៥២នៃគ.ស.បន្ទាត់ទី១១០, ស្រុកសុខាគ្រាម sruk *sukhāgrāma* K.105,៩៨៧នៃ គ.ស.បន្ទាត់ទី១១, ស្រុកសុបុរាយ sruk *supu rāya* K.669, ៩៧២នៃគ.ស.បន្ទាត់ទី៤, ស្រុកសុវណ្ណ៌បុរ sruk *suvarṇṇapura* K.774,៩៨៩នៃគ.ស.បន្ទាត់ទី៧, ស្រុកសូរភិ sruk *sūrabhi* K.420,សតវត្សរ៍ទី១២បន្ទាត់ទី១, ស្រុកសោមាលយ sruk *somālaya* K.91,សតវត្សរ៍ទី១២បន្ទាត់ទី៩, ស្រុក្កសោស៑នោត៑ srukk *sos not* K.376,សតវត្សរ៍ទី១០-១១ បន្ទាត់ទី៥, ស្រុកសំរោង sruk *saṃroṅ* K.713,៨៩៣នៃគ.ស.បន្ទាត់ទី៤,១៥, ស្រុក សំវេគ sruk *saṃvega* K.105,៩៨៧នៃគ.ស.បន្ទាត់ទី១១, ស្រុកសំសំ sruk *saṃsaṃ* K.105,៩៨៧នៃគ.ស. បន្ទាត់ទី១៣, ស្រុកស្វាទ stuk *sṅvād* K.158,១០០៣នៃគ.ស.បន្ទាត់ទី២០, ស្រុកស្ជុង sruk sjuṅ Ka.18A, ១០១៤នៃគ.ស.បន្ទាត់ទី៤៥, ស្រុកស្តុកកន្ទេល៑ sruk stuk kandel K.713,៨៩៣នៃគ.ស.បន្ទាត់ទី២៧, ស្រុកស្តុកកោក sruk stuk kok K.292,១០១១នៃគ.ស.បន្ទាត់ទី១៤, ស្រុកស្តុកផ្លាង sruk stuk phlyāṅ K.183, ៩២៨នៃគ.ស.បន្ទាត់ទី៥, ស្រុកស្តុករន្សិ sruk stuk ransi K.219, ១០៥០ នៃគ.ស.បន្ទាត់ទី៦, ស្រុកស្តុកម្មាំង sruk *stuk rmmāṅ* K.219,១០៥០នៃគ.ស.បន្ទាត់ទី៤/K.235D,១០៥២នៃគ.ស.បន្ទាត់ទី៧២, ស្រុកស្តុកស្រេក sruk stuk srek K.183,៩២៨នៃគ.ស.បន្ទាត់ទី១៤, ស្រុកស្តុក ស្លុត sruk

stuk slut K.206,១០៥២នៃគ.ស. បន្ទាត់ទី៧, ស្រុកស្តុកអន្តោង sruk *stuk anton* K.292,១០១១នៃគ.ស.បន្ទាត់ទី២៨, ស្រុកស្តុកអន្ទ្យារ sruk *stuk andyār* K.420,សតវត្សរ៍ទី១២បន្ទាត់ទី៤២, ស្រុកស្តុកអំវិល sruk stuk aṃvil K.374,១០៤២នៃគ.ស. បន្ទាត់ទី៣, ស្រុកស្ថាល sruk sthāla K.183,៩២៨នៃគ.ស.បន្ទាត់ទី២, ស្រុកស្នាំឆ្លោក sruk snāṃ chlok K.256,៩៨៤នៃគ.ស.បន្ទាត់ទី១២, ស្រុកស្រនាំ sruk *sranāṃ* K.476,១០១១នៃគ.ស. បន្ទាត់ទី២១, ស្រុកគ្រីធរ sruk *çrīdhara* K.832,សតវត្សរ៍ទី១០បន្ទាត់ទី២, ស្រុកគ្រី មធុរេន្ទ្រគ្រាម sruk çrī *madhurendra grāma* K.569,១៣០៦នៃគ.ស.បន្ទាត់ទី៧, ស្រុកគ្រីគ្រីន្ទ្ររាជបុរ sruk çrī *çrīndrarājapura* K.569,១៣០៦នៃគ.ស.បន្ទាត់ទី២, ស្រុកស្វយម្ភុបុរ sruk *svayambhu pūra* K.580, សតវត្សរ៍ទី១០បន្ទាត់ទី៥, ស្រុកស្វាយ sruk svāy K.254,១១២៩នៃគ.ស.បន្ទាត់ទី១៤, ស្រុកស្វាយបញ្ចក sruk *svāy* pañcaka K.254B, ១១២៩នៃគ.ស.បន្ទាត់ទី១៤, ស្រុកហរាគ្រំ sruk *harāçraṃ* K.175,សតវត្សរ៍ទី១០ បន្ទាត់ទី៨, ស្រុកអង្គោល sruk *aṅgol* K.292E,១០១១នៃគ.ស.បន្ទាត់ទី២៩, ស្រុកអធ្វាជិត sruk *adhvājita* K.598B,១០០៦នៃគ.ស. បន្ទាត់ទី២៥, ស្រុកអនង្គបុរ sruk *anaṅgapura* K.292E,១០១១នៃគ.ស.បន្ទាត់ទី ៣០, ស្រុកអន្លាង sruk *anlāṅ* K.235D, ១០៥២នៃគ.ស.បន្ទាត់ទី១១១, ស្រុកអភិវនគ្រាម sruk abhivanagrāma K.713,៨៩៣នៃគ.ស. បន្ទាត់ទី៦, ស្រុកអមរាលយ sruk *amarālaya* K.598B,១០០៦នៃគ.ស.បន្ទាត់ទី២៩-៣០, ស្រុក[អ]រិនិវាស sruk *[a]rinivāsa* K.105,៩៨៧នៃគ.ស.បន្ទាត់ទី១២, ស្រុកអវទ្ធ្យបុរ sruk *avaddhyapura* K.380D,១០៣៨នៃគ.ស.បន្ទាត់ទី៣២/K.380E,១០៣៨នៃគ.ស.បន្ទាត់ទី៣៥, ស្រុកឥន្ទ្រ sruk *indra* K.292, ១០១១នៃគ.ស.បន្ទាត់ទី១៤, ស្រុកឥន្ទ្របរាស្ស sruk indra *parāss* K.292N,១០១១នៃគ.ស.បន្ទាត់ទី១៥, ស្រុកឧទ្យាន sruk *udyāna* K.464,៩៦៨នៃគ.ស.បន្ទាត់ទី៦, ស្រុកអំរេកទិកកេះ sruk *aṃrek* dik keḥ K.265S,៩៥៩នៃគ.ស.បន្ទាត់ទី៦ ជាដើម។

## ២- វាក្យសព្ទសម្គាល់ឋានន្តរនាមតាមរយៈសិលាចារឹកសម័យមុនអង្គរនិងសម័យអង្គរ

វាក្យសព្ទសម្គាល់ឋានន្តរនាមតាមរយៈសិលាចារឹកនេះ ជាមុខវិជ្ជាដ៏សំខាន់មួយដែរនៅក្នុងការសិក្សា ផ្នែកភាសាវិទ្យា ហើយការសិក្សាឋានន្តរនាមអាចឱ្យយើងដឹងអំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងនាសម័យមុនអង្គរ និងសម័យអង្គរផងដែរ។ តាមរយៈសិលាចារឹកសតវត្សរ៍ទី៦-១៤ យើងឃើញថា មានការបែងចែកឋានន្តរនាមយ៉ាងច្បាស់ ហើយឋានន្តរនាមខ្លះកើតឡើងដោយសារការប្រើផ្នត់នីយកម្មនិងសមាសពាក្យ ដើម្បីបង្កើតបច្ចេកសព្ទសម្គាល់គោរមងារថាជាអាទិទេព ព្រះមហាក្សត្រ រាជវង្សានុវង្ស ព្រាហ្មណ៍បុរោហិត រាជកូល មហាមន្ត្រី រាជគ្រូ មន្ត្រីរដ្ឋបាល មន្ត្រីសង្ឃ អ្នកបម្រើប្រុស-ស្រី ជាដើម។ ហេតុដូច្នេះ វាក្យសព្ទសម្គាល់ឋានន្តរនាមនីមួយៗ មកធ្វើការបញ្ជាក់បង្ហាញ ដូចខាងក្រោម៖

### ២.១-គោរមងារសម្គាល់អាទិទេព ព្រះមហាក្សត្រ និងមន្ត្រីថ្នាក់ខ្ពស់

ជាឋានន្តរនាមដែលមានឋានន្តរសក្តិខ្ពង់ខ្ពស់នៅក្នុងសង្គមនាសម័យនោះ“មានជាអាទិ៍ រាជវង្សានុវង្ស ព្រាហ្មណ៍ បុរោហិត រាជកូល មហាមន្ត្រី រាជគ្រូ (ព្រះគុរុ) ឥស្សរជនជាន់ខ្ពស់ មន្ត្រីសង្ឃជាន់ខ្ពស់ ពួកអភិជន (aristocrates)ពួកកុដុម្ពី(ពួកអ្នកមានដីច្រើន) រាជការ(អ្នកបំរើការរបស់រាជ្យព្រះមហាក្សត្រ) សេនាបតី ។ល។

គឺជាឈ្មោះមនុស្សដែលស្ថិតនៅក្នុងស្រទាប់លើនៃសង្គម»[19]។ នៅក្នុងឋានន្តរនាមសម្គាល់ព្រះមហាក្សត្រនេះ វាអាចជួយសម្រួលម្យ៉ាងដែរដល់អ្នកស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រផងដែរ។ ឋានន្តរនាមសម្គាល់ព្រះមហាក្សត្រនិងអាទិទេពទាំងអស់ រមែងមានទម្រង់ ផ្នត់នីយកម្មពីពីរព្យាង្គឡើងទៅ បានសេចក្ដីថា កាលណាទម្រង់ពាក្យកាន់តែវែងកាន់តែស្មុគស្មាញ ហើយ ឋានន្តរនាមនេះមានកម្រិតកាន់តែខ្ពង់ខ្ពស់ឧត្តុង្គឧត្ដមឡើងទៀត។

គេអាចសម្គាល់ឋានន្តរនាមថ្នាក់លើនេះ ដូចខាងក្រោម៖

**២.១.១- គោរមងារសម្គាល់អាទិទេពនិងព្រះមហាក្សត្រ**

វាក្យសព្ទ **វ្រះកំម្រតាង៑អញ៑/វ្រះកម្រតាង៑អញ៑/ វ្រះកំម្រតេង៑អញ៑/វ្រះកម្រតេង៑អញ៑** គឺជាបច្ចេកសព្ទសម្គាល់ឋានន្តរនាមព្រះមហាក្សត្រនិងអាទិទេព នៅក្នុងព្រហ្មញ្ញ សាសនា មានជាអាទិ៍ ព្រះសិវៈ ព្រះវិស្ណុ ព្រះនារាយណ៍ ជាដើម។ ដូចមានឧទាហរណ៍ វ្រះកំម្រតាង៑អញ៑ស្រីត្រិភុវនជយ vraḥ kaṃmratān̊ añ çrī tribhuvanajaya K54,៦២៩នៃគ.ស.បន្ទាត់ទី៩ ដែលមានន័យថា អាទិទេពស្រីត្រិភុវនជយ(ព្រះវិស្ណុ); វ្រះ កំម្រតាង៑អញ៑ស្រីជយទេវីឱយ៑ករោំតម្រតាញ៑សក្រស្វាមិ vraḥ kaṃmratān̊ añ çrī jayadevī oy karoṃ ta mratāñ çakrasvāmi K.904A,៧១៣នៃគ.ស.បន្ទាត់ទី១៥-១៦ ដែលមានន័យថា ព្រះមហាក្សត្រិយានី ស្រីជ័យទេវី ធ្វើអំណោយដីស្រែទំនាបដល់មន្ត្រីសក្រស្វាមិ; វ្រះកម្រតាង៑អញ៑ស្រីភវវម៌្ម vraḥ kamratān̊ añ çrī bhavavarmmaK.149, សតវត្សរ៍ទី៧បន្ទាត់ទី៣ ដែលមានន័យថា ព្រះមហាក្សត្រព្រះបាទភវវម៌្ម(ភវវរ្ម័ន); ធូលីវ្រះបាទកំម្រតេង៑កំត្វនិអញ៑គ្រីសូយ៌្យវម៌្មទេវ dhūlī vraḥ pāda kaṃmraten̊ kaṃtvan añ çri sūryyavarmmadeva K.292,១០១១នៃគ.ស.បន្ទាត់ទី២/ Ka.18A,១០១៤នៃគ.ស.បន្ទាត់ទី១ ដែលមានន័យថា ព្រះមហាក្សត្រព្រះបាទស្រីសូយ៌្យវម៌្មទេវៈ(ព្រះបាទសូរ្យវរ្ម័នទី១)ជាដើម។

**២.១.២- គោរមងារសម្គាល់មន្ត្រីថ្នាក់ខ្ពស់ឬមេទ័ព**

គោរមងារនេះ ជាទូទៅ ប្រើប្រហាក់ប្រហែលនឹងព្រះមហាក្សត្រដែរ ប៉ុន្តែមិនមានប្រើពាក្យ **ទេវៈ** នៅខាងចុងដូចគោរមងារសម្គាល់ព្រះមហាក្សត្រទេ ដូចមានឧទាហរណ៍ វ្រះកំស្តេង៑អញ៑ស្រិលក្ស្មិបតិវម៌្ម នៅក្នុងសិលាចារឹកអូរស្មាច់Ka.18,1014នៃគ.ស.បន្ទាត់ទី៦, អ្នកសញ្ជក៏វីរជយតិហៅវ្រះកម្រតេង៑អញ៑ គ្រីរាជសិង្ហវម៌្ម នៅក្នុងសិលាចារឹកអង្គរវត្ត K.298,សតវត្សរ៍ទី១៣, វ្រះកម្រតេង៑អញ៑គ្រីវីរេន្ទ្រាធិបតិវម៌្ម K.293 សតវត្សរ៍ទី១៣ ជាដើម។

## ២.២- គោរមងារមន្ត្រីថ្នាក់កណ្ដាល

**២.២.១- ព្រះកំស្តេង៑/ព្រះកំស្តេង៑អញ៑**

វាក្យសព្ទ **ព្រះកំស្តេង៑អញ៑** ជាបច្ចេកសព្ទសម្គាល់គោរមងារជាន់ខ្ពស់សម្រាប់ព្រះអង្គម្ចាស់, ម្ចាស់ក្សត្រី មន្ត្រីថ្នាក់កណ្ដាល ព្រះសង្ឃនាយក ជាដើម ដូចមានឧទាហរណ៍ វ្រះកំស្តេង៑គិវបាទសភាបតិនាត្រិណិនុវ្រះ កំស្តេង៑កុតិរុង៑សភាបតិនាចត្វារិ *vraḥ kaṃsten̊* çivapāda sabhāpati nā triṇi nu vraḥ kaṃsten̊ kuti run̊ sabhāpati nā catvāri Ka.18A,១០១៤នៃគ.ស.បន្ទាត់ទី២ ព្រះកំស្តេងសិវបាទជាចៅក្រមថ្នាក់ត្រិណិ ដល់ព្រះ កំស្តេងកុតិរុង ជាចៅក្រមថ្នាក់ចត្វារី ជាដើម។

**២.២.២- កំស្តេង៑/កំស្តេង៑អញ៑**

[19] ឡុង សៀម : វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកកម្ពុជា សម័យបុរេអង្គរ សតវត្សរ៍ទី៦-៨), ឆ្នាំ២០០០, ទំ.១៤។

វាក្យសព្ទ **កំស្តេង/កំស្តេងអញ** ជាបច្ចេកសព្ទសម្គាល់គោរមងារទាបជាងវាក្យសព្ទ **ព្រះកំស្តេង/ព្រះ កំស្តេងអញ** ដូចមានឧទាហរណ៍ កំស្តេងគ្រីជយសិង្ហវម៌្ម *kaṃsteṅ* çrī jayasiṅhavarmma K.61,៩១២នៃ គ.ស.បន្ទាត់ទី៥ ដែលមានន័យថា (មន្ត្រី)កំស្តេងស្រីជយសិង្ហវម៌្មៈ ជាដើម។

### ២.២.៣- ស្តេង/ស្តេញ/ស្តេងអញ/ស្តេញអញ

វាក្យសព្ទ **ស្តេង/ស្តេញ/ស្តេងអញ/ស្តេញអញ** ជាបច្ចេកសព្ទសម្គាល់គោរមងារទាបជាងវាក្យសព្ទ **កំស្តេង/កំស្តេងអញ** ដូចមានឧទាហរណ៍ ស្តេញគិវាចារ្យ*steñ* çivācāryya K.349N,៩៥៨នៃគ.ស.បន្ទាត់ទី៤ ដែលមានន័យថា ស្តេញសិវាចារ្យ ជាដើម។

### ២.២.៥-ម្រតាង/ម្រតាញ/ម្រតាងអញ/ម្រតេងអញ

វាក្យសព្ទ **ម្រតាង/ម្រតាញ/ម្រតាងអញ/ម្រតេងអញ** ជាបច្ចេកសព្ទសម្គាល់គោរមងារទាបជាងវាក្យសព្ទ **វ្រះកំម្រតាងអញ/វ្រះកម្រតាងអញ/ វ្រះកំម្រតេងអញ/វ្រះកម្រតេងអញ** ដូចមានឧទាហរណ៍ ម្រតាញមេធាវិន្ទុ *mratāñ* medhāvindu K.493,៦៥៧នៃគ.ស.បន្ទាត់ទី៣០(ព្រះតេជគុណ)ម្រតាញមេធាវិន្ទុ; ម្រតាងអញ K.788, សតវត្សរ៍ទី៧-៨បន្ទាត់ទី៩ ដែលមានន័យថា ម្រតាញគ្រីវរេន្ទ្រ*mratāñ* çrī varendra K.252,៩៤២នៃគ.ស.បន្ទាត់ទី៣ ដែលមានន័យថា (មន្ត្រី)ម្រតាញស្រីវរេន្ទ្រ ជាដើម។

### ២.២.៦- ក្លោញ/ខ្លោញ

ក្លោញ/ខ្លោញជាបច្ចេកសព្ទសម្គាល់មន្ត្រីទទួលបន្ទុករដ្ឋបាល ដែលមានន័យថា មេ, មេខ្លោង, អធិការ, នាយក, ចៅហ្វាយ, មន្ត្រីទទួលបន្ទុកខាងការត្រួតត្រាពិនិត្យខាងមុខការផ្សេងៗ។ វាក្យសព្ទ **ក្លោញ** មានប្រើក្នុងសម័យមុនអង្គរ និង វាក្យសព្ទ **ខ្លោញ** ប្រើក្នុងសម័យអង្គរ ដូចមានឧទាហរណ៍ ក្លោញស្រុក kloñ sruk K.41, សតវត្សរ៍ទី៧បន្ទាត់ទី៤ ដែលមានន័យថា ចៅហ្វាយឬប្រធានស្រុក; ក្លោញកវបុរ kloñ sruk K.1,សតវត្សរ៍ទី៧-៨បន្ទាត់ទី២ ដែលមានន័យថា ចៅហ្វាយក្រុងកវបុរ; ខ្លោញវ្នំ khloñ vnaṃ K.340,សតវត្សរ៍ទី៩បន្ទាត់ទី៩-១០ ដែលមានន័យថា ចៅអធិការព្រះវិហារ (ប្រាសាទ); ខ្លោញកាយ៌្យ khloñ kāryya K.340,សតវត្សរ៍ទី៩បន្ទាត់ទី១០ ដែលមានន័យថា អធិការត្រួត ការងារ; ខ្លោញវល khloñ vala K.291,910នៃគ.ស.បន្ទាត់ទី៨ ដែលមានន័យថា ប្រធានប្រជាពលរដ្ឋ, មេកងពល ជាដើម។

### ២.២.៧-ឆ្លោញ

វាក្យសព្ទ **ឆ្លោញ** ជាបច្ចេកសព្ទសម្គាល់មន្ត្រីទទួលបន្ទុករដ្ឋបាល ដែលមានន័យថា មេ/ប្រធាន/ប្រមុខ ដូចមានឧទាហរណ៍ ខ្ញុំមណ៌ឆ្លោញប្រាណឱយ៌តវ្រះកម្រតេងអញតវិស្នុ khñuṃ maṇ *chloñ* prāṇa oy ta vraḥ kamrateñ añ ta viṣṇu K.99,៩២២នៃគ.ស.បន្ទាត់ទី១២ ដែលមានន័យថា អ្នកបម្រើដែលឆ្លោញប្រាណបានថ្វាយដល់អាទិទេពគឺព្រះវិស្ណុ ជាដើម។

## ២.៣-គោរមងារមន្ត្រីថ្នាក់ក្រោម

### ២.៣.១- បុ/បា

វាក្យសព្ទ បុ/បា ជាបច្ចេកសព្ទសម្គាល់ សង្ឃនាយក, អភិជន, ព្រះគុណម្ចាស់, ងារចំពោះមនុស្សជាទីគោរពដ៏ពិសិដ្ឋ ដូចមានឧទាហរណ៍ បុអញ *pu* añ K.28,VIIសតវត្សរ៍ទី៧បន្ទាត់ទី១ ដែលមានន័យថា (ព្រះគុណម្ចាស់)បុអញ; អាជ្ញាវ្រះកម្រតាងអញនិគិបុណ្យបុចះអញរត្នភានុគេបុចះអញ ājñā vraḥ kamratāṅ añ ni gui puṇya *pu caḥ añ* ratna- bhānu K.49,៦៦៤នៃគ.ស.បន្ទាត់ទី១១ ដែលមានន័យថា រាជបញ្ជារបស់ព្រះរាជា

ទាក់ទង នឹងការកសាងកុសលរបស់សង្ឃនាយករត្នភានុ; គេចេរ៍អាជ្ញាវ្រះកម្រតាង៑អញ៑ព្រាហ្មណ---ទេឝ និវ៌្វស បន្លោញ៑បោតលិបង៑តិង៑ហេមតុលិ១អនក៑សាមន្យជនគេទណ្ឌ្យ ge cer ājñā vraḥ kamratāṅ añ brāhmaṇa---deça nirvvāsa panloñ *po* tal paṅ tiṅ hema tul 1 anak sāmanyajana ge daṇḍya K.259, ៩៥២នៃគ.ស.បន្ទាត់ទី២៩-៣០ ដែលមានន័យថា អ្នកដែលបំពានព្រះរាជបញ្ជា(បើជា)ព្រាហ្មណ៍---នឹងត្រូវបំបរបង់ចេញពីស្រុក (បើជាមន្ត្រី)បន្លោញបោ នឹងត្រូវបង់ពិន័យជាមាសដល់ចំនួន១តុល (បើជា)មនុស្ស សាមញ្ញគេនឹងត្រូវដាក់ទណ្ឌកម្ម ជាដើម។

### ២.៣.១- បោញ៑

វាក្យសព្ទ **បោញ៑** ជាបច្ចេកសព្ទសម្គាល់ឋានន្តរនាមរបស់មន្ត្រីឬបុព្វជិត ដូចមានឧទាហរណ៍ បោញ៑ឧយ៑ឱយ៑ក្ញុំឰតក្បោញ៑កម្រតាង៑អញ៑ poñ uy oy kñuṃ ai ta kpoñ kamratāṅ añ K.600, ៦១១នៃគ.ស.បន្ទាត់ទី១ ដែលមានន័យថា ព្រះតេជគុណបោញឧយ បានធ្វើអំណោយខ្ញុំបម្រើឱ្យដល់ក្បោញកម្រតាងអញ ជាដើម។

### ២.៣.២- តាញ៑/តាង៑

វាក្យសព្ទ **តាញ៑/តាង៑** ជាបច្ចេកសព្ទសម្គាល់ឋានន្តរនាម និងជាពាក្យផ្សំរបស់ឋានន្តរសក្តិរបស់ឥស្សរជន និងភរិយារបស់មន្ត្រី ដូចមានឧទាហរណ៍ ក្ញុំតាញសុវណ្ណមនបរិគ្រហតកុរាកវ្យាធបុរ kñuṃ *tāñ* suvarṇṇa man parigraha ta kurāk vyādhapura K.109,៦៥៥នៃគ.ស.បន្ទាត់ទី២៤ ដែលមានន័យថា អ្នកបម្រើរបស់(មន្ត្រី)តាញសុវណ្ណ ដែលត្រូវបានបូកសរុបជាមួយនិងអ្នកបម្រើរបស់(មន្ត្រី)កុរាកវ្យាធបុរ; ក្វន៑ វាប៑សទាឝិវ ត ជ្មះតាញ៑វ្រហ្មនុតាញ៑ឧមា kvan vāp sadāçiva ta jmaḥ *tāñ* vrahma nu *tāñ* umā K.720, ១០០៦នៃគ.ស. បន្ទាត់ទី២៣-២៤ ដែលមានន័យថា បុត្រី(វាប)សទាសិវៈ ដែលមានឈ្មោះ(លោកស្រី)តាញ វ្រហ្មនិងតាញឧមា ជាដើម។

### ២.៣.២- វាប៑

វាក្យសព្ទ **វាប៑** ជាបច្ចេកសព្ទសម្គាល់ងារមន្ត្រីថ្នាក់ទាបក្នុងសម័យអង្គរ ដូចមានឧទាហរណ៍ តំរ៑វចវាប៑ជា tamṛvac *vāp* jā K.269,៩២១គ.ស.បន្ទាត់ទី៣ ដែលមានន័យថា តម្រួត(គឺ)វាប៑ជា; វាប៑ម្យង៑ម្មាំ *vāp* myaṅ rmmāṃ K.831,៩៦៨នៃគ.ស.បន្ទាត់ទី២៤ ដែលមានន័យថា (មន្ត្រី)វាបម្យង(ជា)អ្នករបាំ ជាដើម។

## ២.៣- ងារសម្គាល់អ្នកបម្រើ

ងារសម្គាល់អ្នកបម្រើជាងារមនុស្សថ្នាក់ក្រោមនៃស្រទាប់សង្គម សំដៅទៅដល់អ្នកបម្រើនៅតាមវត្តអារាម ប្រាសាទ អ្នកធ្វើស្រែចម្ការ អ្នករបាំ អ្នកថែសួន អ្នកតម្បាញ អ្នកដាំស្ល ជាដើម។ ហើយពាក្យសម្គាល់ ខ្ញុំបម្រើ ជួនកាល លោកសរសេរឈ្មោះជាភាសាខ្មែរ ជួនកាលលោកសរសេរឈ្មោះ ជាភាសាសំស្ក្រឹត ឬក៏ ភាសាទាំងពីររួមបញ្ចូលគ្នាតែម្តង។ នៅត្រង់ចំណុចនេះ តាមរយៈឈ្មោះទាំងអស់នេះ ឈ្មោះខ្លះ យកនាម កិរិយាសព្ទ ឬ គុណនាមទៅប្រើ និង ឈ្មោះខ្លះទៀតកើតឡើងដោយការប្រើផ្នត់នីយកម្ម។ នៅសម័យមុនអង្គរ និង សម័យអង្គរឋានន្តរនាមនេះ គេអាចដឹងភ្លាមដែរថាឈ្មោះនេះជាបុរសឬឈ្មោះនេះជាស្ត្រីបាន ហើយ បច្ចេកសព្ទដែលយើងបានកត់សម្គាល់ឃើញមានប្រើដូចខាងក្រោម៖

### ២.៣.១- ងារសម្គាល់អ្នកបម្រើប្រុស

ចំពោះបច្ចេកសព្ទសម្គាល់អ្នកបម្រើប្រុស នៅសម័យមុនអង្គរ យើងសង្កេតឃើញមានការសរសេរដាក់ពីខាងឆ្វេងឈ្មោះដែលមានដូចក្រោម៖

**ក- វ៉/វា** : វាក្យសព្ទសម្គាល់អ្នកបម្រើបុរស ដូចមានឧទាហរណ៍ វកុញ va kuñ K.24B,សតវត្សរ៍ទី៦-៧បន្ទាត់ទី៩ ដែលមានន័យថា បុរស(អ្នកបម្រើ)នាមកុញ; វាក្ទែរ៍ vā kder K.133,សតវត្សរ៍ទី៨បន្ទាត់ទី៣ ដែលមានន័យថា បុរស(អ្នកបម្រើ)ឈ្មោះ ក្ទេរ ជាដើម។

**ខ-ឃោ** : វាក្យសព្ទសម្គាល់អ្នកបម្រើបុរស ដូចមានឧទាហរណ៍ ឃោក្យក៌អាទិត្យសម្ម៌ gho kyak ādityaçarmma K.137,៧៨១នៃគ.ស.បន្ទាត់ទី២១ ដែលមានន័យថា អ្នកបម្រើប្រុសនាមក្យកអាទិត្យគម្ម៌; បិណ្ឌអំរះ១ឃោ៣គ្វាល៑២តៃ៨លប៑២ piṇḍa amṛaḥ 1 *gho* 3 gvāl 2 tai 8 lap 2 K.270,៩៧១នៃគ.ស.បន្ទាត់ទី៨ ដែលមានន័យថា សរុបអនុរក្សម្នាក់ បុរស(ឃោ)៣នាក់ បុរស(គ្វាល)២នាក់នារី៨នាក់ បុរស(លប)២នាក់ ជាដើម។

**គ- សិ/សី** : វាក្យសព្ទសម្គាល់អ្នកបម្រើបុរស ដូចមានឧទាហរណ៍ ក្ញុំតសិ kñuṃ ta si K.109, ៦៥៥នៃគ.ស.បន្ទាត់ទី១២ ដែលមានន័យថា ខ្ញុំបម្រើបុរស; បៅសី pau sī K.505,៦៣៩នៃគ.ស.បន្ទាត់ទី១៤ ដែលមានន័យថា ក្មេងប្រុសតូចនៅបៅ; សីសង្កាវ៑ sī *saṅkāv* 1 K.330B,៨៩៣នៃគ.ស.បន្ទាត់ទី២៩ បុរស(នាម) *សង្កាវ* ជាដើម។

**ឃ- ទេរ៑សិ/ទេរ៑សី** : វាក្យសព្ទសម្គាល់អ្នកបម្រើប្រុសពេញជំទង់ ដូចមានឧទាហរណ៍ កុត្វៃ១កោន៑ទេរ៑សិ ku tvai 1 kon der si K.155,សតវត្សរ៍ទី៧-៨បន្ទាត់ទី៦ នារីត្វៃ១និងកូនប្រុសជំទង់ ជាដើម។

**ង- លាង៑សិ/លាង៑សី** : វាក្យសព្ទសម្គាល់អ្នកបម្រើប្រុសពេញកម្លោះ ដូចមានឧទាហរណ៍ កុយោង៑កោន៑កុលាង៑ សិ ku yoṅ kon ku lāṅ si K.505,៦៣៩នៃគ.ស.បន្ទាត់ទី៥ ដែលមានន័យថា នារី(អ្នកបម្រើ)នាម យោង និងកូនកម្លោះរបស់គាត់ ជាដើម។

**ច- ទាសះ** : វាក្យសព្ទសម្គាល់អ្នកបម្រើប្រុស ដូចមានឧទាហរណ៍ ទាសទាសីគោមហិស dāsa dāsī go mahiṣa K.44A,៦៧៤នៃគ.ស.បន្ទាត់ទី១០ ដែលមានន័យថា អ្នកបម្រើ ប្រុសស្រី គោ ក្របី; ឱយ៑ទាសទាសីសហស្រ oy *dāsa dāsī* sahasra K.235D,១០៥២នៃគ.ស.បន្ទាត់ទី៦៩ ដែលមានន័យថា ថ្វាយទាសាទាសីចំនួនមួយពាន់នាក់ ជាដើម។

**ឆ- គ្វាល៑** : វាក្យសព្ទសម្គាល់អ្នកបម្រើប្រុសនៅតាមប្រាសាទឬអ្នកគង្វាលសត្វពាហនៈ ដូចមានឧទាហរណ៍ គ្វាល៑វាត្ស៑ត៑ K.155B,សតវត្សរ៍ទី៧-៨បន្ទាត់ទី១១ ដែលមានន័យថា អ្នកគង្វាល គឺបុរស(នាម)ត្សិត; គ្វាល៑កន៑ឥន៑គ្វាល៑ក្រៅ*gvāl* kan-in *gvāl* krau K.713B,៨៩៣នៃគ.ស.បន្ទាត់ទី៥ដែលមានន័យថា បុរស(នាម)កនឥននិងបុរស(នាម)ក្រៅ; គ្វាល៑បន្ទន៑ *gvāl* pandan K.269,៩២១នៃគ.ស.បន្ទាត់ទី៦ ដែលមានន័យថា បុរស(នាម)បន្ទន ជាដើម។

**ឈ- លប៑** : វាក្យសព្ទសម្គាល់អ្នកបម្រើប្រុសនៅតាមប្រាសាទ ដូចមានឧទាហរណ៍ លប៑ទយា *lap* dayā K.312a, ៨៧៩នៃគ.ស.បន្ទាត់ទី៣ ដែលមានន័យថា បុរស(នាម)ទយា; លប៑៦សីរត៑១៥តៃរត៑១១សីបៅ១៩ *lap* 6 sī rat 10-5 tai rat10-1 sī pau 10-9 K.313a,៨៧៩នៃគ.ស.បន្ទាត់ទី៤១ ដែលមានន័យថា បុរស(លប)៥នាក់ ក្មេងប្រុសតូចចេះរត់១៥នាក់ ក្មេងស្រីតូចចេះរត់១១នាក់ ក្មេងប្រុសតូចនៅបៅ១៩នាក់ ជាដើម។

**២.៣.២- ងារសម្គាល់អ្នកបម្រើស្រី**

**ក- កុ** : វាក្យសព្ទសម្គាល់អ្នកបម្រើស្រី ដូចមានក្នុងសិលាចារឹកK.557,៦១១នៃគ.ស.បន្ទាត់ទី៣ ក្ញុំកុតម្មារុល វ៉ា

kñuṃ ku tanmāru va lavo ដែលមានន័យថា នារីអ្នកបម្រើ(ឈ្មោះ)តន្មារុ និង បុរសអ្នកបម្រើ(ឈ្មោះ) លវោ; កុ ក្វី ku kvī K.137, សតវត្សរ៍ទី៧បន្ទាត់ទី២២, នារីអ្នកបម្រើ(ឈ្មោះ) ក្វី។

**ខ- តៃ** : វាក្យសព្ទសម្គាល់អ្នកបម្រើស្រី ដូចមានក្នុងសិលាចារឹក K.134,៧៨១នៃគ.ស.បន្ទាត់ទី២១ បិន្ឌតៃ១១ មេង៩ pinḍa tai 10-1 meṅ 9 ដែលមានន័យថា អ្នកបម្រើនារី១១នាក់ និង ក្មេង៩នាក់; K.320a,៨៧៩នៃគ.ស. បន្ទាត់ទី៧ បិណ្ឌម្មាំតៃ៣ piṇḍa rmmāṃ tai 3 សរុបអ្នករបាំនារី៣នាក់; K.258,1107នៃគ.ស.បន្ទាត់ ទី៣៤-៣៥ ឃោប្រំបិយតៃប្រំបិយផ្សមតបប្រំមួយ gho praṃpiy *tai* praṃpiy phsam tap praṃmvay បុរសប្រាំបីនាក់ នារីប្រាំបីនាក់ សរុបដប់ប្រាំមួយនាក់ ជាដើម។

**គ- ទាសី** : ពាក្យសំស្ក្រឹតសម្រាប់សម្គាល់អ្នកបម្រើស្រី ដូចមានឧទាហរណ៍ ទាសទាសីគោមហិស dāsa dāsī go mahiṣa K.44A,៦៧៤នៃគ.ស.បន្ទាត់ទី១០ ដែលមានន័យថា អ្នកបម្រើ ប្រុសស្រី គោ ក្របី ជាដើម។

**ឃ-ទេរតៃ** : វាក្យសព្ទសម្គាល់ងារអ្នកបម្រើស្រីដែលមានវ័យជំទង់ ដូចមានឧទាហរណ៍ ទេរតៃ der tai 2 K.138, ៦២០នៃគ.ស.បន្ទាត់ទី១០ ដែលមានន័យថា នារីអ្នកបម្រើជំទង់ពីរនាក់ ជាដើម។

**ង-លាងតៃ** : វាក្យសព្ទសម្គាល់នាមអ្នកបម្រើពេញក្រមុំ ដូចមានឧទាហរណ៍ កុសោលកោនលាងតៃ ku sol kon ku lāṅ tai K.505,៦៣៩នៃគ.ស.បន្ទាត់ទី៩ ដែលមានន័យថា នារី(អ្នកបម្រើ)ឈ្មោះ សោលនិងកូនក្រមុំ ជាដើម។

**ច-កន្តៃ/កន្តៃយ** : វាក្យសព្ទសម្គាល់ស្ត្រីឬនារីចំណាស់ ដូចមានឧទាហរណ៍ កន្តៃតបោសឱយ(យ)ជមានក្បោញ ១ kantai ta pos oy (ya) jamāna kpoñ 1K.600,៦១១នៃគ.ស.បន្ទាត់ទី៣ ជូនជីជាអ្នកធ្វើពិធីសក្ការបូជាចំពោះអាទិទេពក្បោញ១; អ្នកកន្តៃម្វាយ ᵃnak *kantai* mvāy K.262S,982នៃគ.ស.បន្ទាត់ទី១៧ ដែលមានន័យថា ស្ត្រីម្នាក់ ជាដើម។

# ៣- ការបែងចែករដ្ឋបាលគ្រប់គ្រង

## ៣.១- ខ្លោញកម្មាន្តរ/កាម្មាន្តរ

នៅក្នុងសម័យអង្គរ យើងឃើញមានប្រើវាក្យសព្ទ **ខ្លោញកម្មាន្តរ** ជាមន្ត្រីទទួលបន្ទុកព្រះបរមរាជវាំងឬជាមន្ត្រីទទួលបន្ទុកពិធីបូជាសព ដូចមានឧទាហរណ៍ ខ្លោញកម្មាន្តរ *khloñ* karmmāntara K.868,៩៧៤នៃគ.ស. បន្ទាត់ទី១៥ ដែលមានន័យថា នាយកមន្ត្រីកម្មាន្តរៈ; កំស្តេងឝ្រីជយេន្ទ្របន្ទិតជារាជបុរោហិតខ្លោញ កាម្មាន្តរឯក kaṃsteṅ çri jayendrapandita jā rājapurohita khloñ kārmmāntaraeka K.235D,១០៥២នៃ គ.ស.បន្ទាត់ទី ៤៥ ដែលមានន័យថា កំស្តែងស្រីជយេន្ទ្របណ្ឌិត ជារាជបុរោហិតជាអធិបតីថ្នាក់ឯកនៃមន្ត្រី កាម្មាន្តរៈ ជាដើម។

## ៣.២-ខ្លោញកល្មន

វាក្យសព្ទ **ខ្លោញកល្មន** គោរមងារមន្ត្រីទទួលបន្ទុកជាផ្នែកក្រមួន ដូចមានឧទាហរណ៍ ខ្លោញកល្មន *khloñ* kalmvan K.913,សតវត្សរ៍ទី១១បន្ទាត់ទី១៣ ដែលមានន័យថា នាយក(ទទួលបន្ទុកខាងការផ្គត់ផ្គង់) ក្រមួន ជាដើម។

## ៣.៣- ខ្លោញកាយ៌្យ khloñ kāryya

វាក្យសព្ទ **ខ្លោញកាយ៌្យ** គោរមងារមន្ត្រីទទួលបន្ទុកជានាយកត្រួតការងារ, នាយកត្រួតកិច្ចការ ដូចមានឧទាហរណ៍ ស្តេញខ្លោញកាយ៌្យ steñ *khloñ kāryya* K. 262S,៩៨២នៃគ.ស.បន្ទាត់ទី៤២ ដែលមានន័យថា (មន្ត្រី) ស្តេញជានាយកត្រួតកិច្ចការ; ផ្សមបាយតទៅតស្មិងនុវៀនុប្រធានខ្លោញកាយ៌្យ phsam pāy ta dau ta smiṅ nu

vñau nu pradhāna *khloñ kāryya* K.989,១០០៨នៃគ.ស.បន្ទាត់ទី២៧ ដែលមានន័យថា សរុបបាយប្រគេនទៅអ្នកបួស(ព្រហ្មញ្ញសាសនា)ភ្ញៀវនិងប្រធានខ្លោញកាយ៌្យ ជាដើម។

### ៣.៤- ខ្លោញ៑គាប៑ khloñ gāp

វាក្យសព្ទ **ខ្លោញ៑គាប៑** គោរមងារមន្ត្រីទទួលបន្ទុកជាមេខ្លោងអ្នកងារ, ប្រធានអ្នកងារ ដូចមានឧទាហរណ៍ វាប៑កេខ្លោញ៑គាប៑ចាប្ប៑ជេង៑កន្ទ្វារ vāp ke *khloñ gāp* cāpp jeṅ kandvāra K.259,៩៥២នៃគ.ស.បន្ទាត់ទី៩ ដែលមានន័យថា (មន្ត្រី)វាបកេប្រធានអ្នកងារ ចាប់ជើងអ្នកយាមទ្វារ; វាប៑ជីវខ្លោញ៑គាប៑វិជយ្យបត្តន vāp jīva khloñ gāp vijayyapattana K.1152A, ៩៦២នៃគ.ស.បន្ទាត់ទី៦(មន្ត្រី)វាបជីវៈជាមេខ្លោងអ្នកងារនៅវិជយ្យ បត្តន; ខ្លោញ៑គាប៑មាលាការ *khloñ gāp* mālākāra K.158D,១០០៣នៃគ.ស.បន្ទាត់ទី២៩ ដែលមានន័យថា ប្រធានអ្នកងារខាងរៀបចំផ្កាភ្ញី ជាដើម។

### ៣.៥-ខ្លោញ៑គុណទោឞ

វាក្យសព្ទ **ខ្លោញ៑គុណទោស** គោរមងារមន្ត្រីទទួលបន្ទុកជានគរបាល ដូចមានឧទាហរណ៍ ម្រតាញ៑ ខ្លោញ៑គុណទោឞ mratāñ *khloñ* guṇadoṣa K.720,១០០៦នៃគ.ស.បន្ទាត់ទី១០ ដែលមានន័យថា (មន្ត្រី) ម្រតាញខ្លោញអធិការគុណទោស(ខាងនគរបាល) ជាដើម។

### ៣.៦- ខ្លោញ៑គ្មាល៑

វាក្យសព្ទ **ខ្លោញ៑គ្មាល៑** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធានឆ្មាំទ្វារ ដូចមានឧទាហរណ៍ វាប៑អម្ឫតខ្លោញ៑គ្មាល៑វាប៑ធម៌្មាចាយ៌្យអមាត្យ vāp amṛta khloñ *gmāl* vāp dharmmācāryya amātya K.262S,៩៨២នៃគ.ស. បន្ទាត់ទី១២ ដែលមានន័យថា (មន្ត្រី)វាបអំម្ឫត ជាប្រធានឆ្មាំទ្វារ (មន្ត្រី)វាបធម្មាចាយ៌្យជាអាមាត្យ(ទីប្រឹក្សា) ជាដើម។

### ៣.៧- ខ្លោញ៑គ្លាង៑

វាក្យសព្ទ **ខ្លោញ៑គ្លាង៑ khloñ glāṅ** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធាន/នាយកឃ្លាំង ដូចមានឧទាហរណ៍ ខ្លោញ៑គ្លាង៑នាឯក khloñ glāṅ nā eka K.99S,៩២២នៃគ.ស.បន្ទាត់ទី៤ ដែលមានន័យថា នាយកឃ្លាំងថ្នាក់ទីមួយ, ខ្លោញ៑គ្លាង៑នាទោ khloñ glāṅ nā do K.262S,៩៨២នៃគ.ស.បន្ទាត់ទី២២ ដែលមានន័យថា នាយកឃ្លាំងថ្នាក់ទីពីរ, ខ្លោញ៑គ្លាង៑នាត្រិណិ khloñ glāṅ nā triṇi K.262S,៩៨២នៃគ.ស. បន្ទាត់ទី២២ ដែលមានន័យថា នាយកឃ្លាំងថ្នាក់ទីបី, ខ្លោញ៑គ្លាង៑នាចត្វារិ khloñ glāṅ nā catvāri K.263D, ៩៨៤នៃគ.ស.បន្ទាត់ទី៦២ ដែលមានន័យថា នាយកឃ្លាំងថ្នាក់ទីបួន ជាដើម។

### ៣.៨-ខ្លោញ៑ចតុទ៌្វារ

វាក្យសព្ទ **ខ្លោញ៑ចតុទ៌្វារ** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធាន/នាយកឆ្មាំព្រះបរមរាជវាំង ដូចមានឧទាហរណ៍ ខ្លោញ៑ចតុទ៌្វារ *khloñ* caturdvāra K.829,សតវត្សរ៍ទី១១បន្ទាត់ទី២០ ដែលមានន័យថា នាយក ឆ្មាំទ្វារ(ឆ្មាំព្រះរាជវាំង) ជាដើម។

### ៣.៩- ខ្លោញ៑ជ្វល

វាក្យសព្ទ **ខ្លោញ៑ជ្វល៑ khloñ jnval** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធាន/នាយកពន្ធដារ ដូចមានឧទាហរណ៍ វាប៑ប្រភាវិឝ្វរខ្លោញ៑ជ្វល៑ vāp prabhāviçvara *khloñ jnval* K.1152A,៩៦២នៃគ.ស.បន្ទាត់ទី៧ ដែលមានន័យថា (មន្ត្រី)វាបប្រភាវិស្វរៈ ជានាយកពន្ធដារ ជាដើម។

### ៣.១០- ខ្លោញ៑ត្ងាត

វាក្យសព្ទ **ខ្លោញភូតាគ khloñ bhūtāça** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធាន/នាយកមន្ត្រីភូតាសៈ ដូចមានឧទាហរណ៍ ខ្លោញភូតាគម្ឫតកធន *khloñ bhūtāça* mṛtaka dhana K.263D,៩៨៨នៃគ.ស.បន្ទាត់ទី ៣៣ ដែលមានន័យថា(មន្ត្រី)ខ្លោញភូតាសៈទទួលបន្ទុកមរតកធន; ខ្លោញភូតាគបយ៌្យង៑ *khloñ bhūtāça* paryyaṅ K.71, សតវត្សរ៍ទី១០បន្ទាត់ទី៥ ដែលមានន័យថា(មន្ត្រី)ខ្លោញភូតាសៈទទួលបន្ទុកប្រេងនិងខ្លាញ់; កំស្តេង៑វោបន្ទុកខ្លោញភូតាគវ្រះជំនួន kaṃsteṅ vo panduk *khloñ bhūtāça* vraḥ jaṃnvan K.207,១០៤២ នៃគ.ស.បន្ទាត់ទី៥២ ដែលមានន័យថា(មន្ត្រី)កំស្តេងវោទទួលបន្ទុក(ទ្រព្យសម្បត្តិ)(មន្ត្រី)ខ្លោញភូតាគៈ (ទទួលបន្ទុក) ព្រះរាជទ្រព្យ ជាដើម។

### ៣.១១- ខ្លោញមុខ

វាក្យសព្ទ **ខ្លោញមុខ khloñ mukha** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធាន/នាយកផ្នែក ដូចមានឧទាហរណ៍ ខ្លោញមុខខ្នេត *khloñ mukha* khnet K.207,១០៤២នៃគ.ស.បន្ទាត់ទី៥២ ដែលមានន័យថា ប្រធាន/នាយកនៃ(អ្នកធ្វើការ)ផ្នែកខាងខ្នើត; ខ្លោញមុខតម្រួចវលឆ្មាំវ្រះបាញ្ជី *khloñ mukha* tamrvac vala chmāṃ vraḥ pāñjī K.391,១០៨២នៃគ.ស.បន្ទាត់ទី២០ ដែលមានន័យថា អគ្គនាយកនៃពួកតម្រួតពល (និង)ឆ្មាំព្រះបញ្ជី ជាដើម។

### ៣.១៣- ខ្លោញរង្វាង

វាក្យសព្ទ **ខ្លោញរង្វាង៑khloñ raṅvāṅ** គោរមងារមន្ត្រីទទួលបន្ទុកជាប្រមុខក្រឡាបញ្ជី ដូចមានឧទាហរណ៍ ខ្លោញរង្វាង៑នាឯក *khloñ raṅvāṅ* nā eka K.653,៩៥៦នៃគ.ស.បន្ទាត់ទី៦ ដែលមានន័យថា ប្រមុខអ្នកបំពេញការងារខាងក្រឡាបញ្ជីឋានន្តរសក្តិថ្នាក់ទី១ ជាដើម។

### ៣.១៤- ខ្លោញវល

វាក្យសព្ទ **ខ្លោញវលkhloñ vala** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធានប្រជាពលរដ្ឋ, ឋានន្តរនាមរបស់មន្ត្រីបម្រើរាជការ, មេបញ្ជាការកងពល ដូចមានឧទាហរណ៍ តិខ្លោញវលទុញតខេន ti *khloñ vala* duñ ta *khen* K.741,៩៩៤នៃគ.ស.បន្ទាត់ទី១៦(ដី)ត្រូវបានទិញដោយមេបញ្ជាការពីទាហានម្នាក់; ខ្លោញវលជេង៑ នុ ខ្លោញវលល្វោ *khloñ vala* jeṅ nu khloñ vala lvo K.817,១០០២នៃគ.ស.បន្ទាត់ទី៧ ដែលមានន័យថា ប្រធានប្រជាពលរដ្ឋ(តំបន់)ជេង និង ប្រធានប្រជាពលរដ្ឋ(តំបន់)ល្វោ ជាដើម។

### ៣.១៥- ខ្លោញវិសយ/ខ្លោញវិសៃយ

វាក្យសព្ទ **ខ្លោញវិសយ/ខ្លោញវិសៃយ** ជាគោរមងារមន្ត្រីទទួលបន្ទុកជាប្រធានផ្នែកខាងប្រេងឬខ្លាញ់ ដូចមានឧទាហរណ៍ ខ្លោញវិសៃយ khloñ *viṣaiya* K.99S,៩៩២នៃគ.ស.បន្ទាត់ទី៧ ដែលមានន័យថា ប្រធានវិស័យ (ប្រេង, ខ្លាញ់, ធនញ្ញជាតិ...) ជាដើម។

### ៣.១៦- ខ្លោញវ្នំ

វាក្យសព្ទ **ខ្លោញវ្នំ, ខ្លោញវ្នំម៑ khloñ vnaṃ , khloñ vnaṃm** គោរមងារមន្ត្រីសង្ឃទទួលបន្ទុក ជាចៅអធិការវត្ត ដូចមានឧទាហរណ៍ ស្តេញអាចាយ៌្យតខ្លោញវ្នំ steñ ācāryya ta *khloñ vnaṃ* K.1087A,៩៣៧ នៃគ.ស.បន្ទាត់ទី៣ ដែលមានន័យថា ព្រះស្តែងអាចារ្យជាចៅអធិការវត្ត; ស្តេញខ្លោញវ្នំមនុបាទមូលកំម្រតេង៑ ជគតគិវបទ steñ khloñ vnaṃm nu *pādamūla* kaṃmrateṅ jagat çivapada K.349S,៩៥៤នៃគ.ស. បន្ទាត់ទី ៩,១៩ ដែលមានន័យថា(ព្រះ)ស្តេញជាចៅអធិការវត្តនិងបព្វជិតជាន់ខ្ពស់នៅប្រាសាទសិវបទ; ខ្លោញ វ្នំវ្រះ

កម្រតេងអញ្ចគិវបាទ *khloñ vnaṃ* vraḥ kamrateṅ añ çivapāda K.354,សតវត្សរ៍ទី១០បន្ទាត់ទី៨ ដែលមានន័យថា ព្រះថៅអធិការប្រាសាទសិវបាទ ជាដើម។

### ៣.១៧- ខ្លោញវ្រិហិ

វាក្យសព្ទ **ខ្លោញវ្រិហិ** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធាន/នាយកធញ្ញជាតិ ដូចមានឧទាហរណ៍ ខ្លោញវ្រិហិ *khloñ* vriha K.349,៩៥៤នៃគ.ស.បន្ទាត់ទី១៦-១៧ ដែលមានន័យថា នាយកទទួលបន្ទុកខាង ធញ្ញជាតិ ជាដើម។

### ៣.១៨- ខ្លោញសិក្សា

វាក្យសព្ទ ខ្លោញសិក្សា គោរមងារមន្ត្រីទទួលបន្ទុកជាប្រធាន/នាយកខាសិក្សាធិការ ដូចមានឧទាហរណ៍ ខ្លោញសិក្សា *khloñ* sikṣā K.258A,១១០៧នៃគ.ស.បន្ទាត់ទី៦ ដែលមានន័យថា នាយកទទួលបន្ទុកខាងសិក្សាធិការ ជាដើម។

### ៣.១៩- ខ្លោញសំតាប

វាក្យសព្ទ **ខ្លោញសំតាបិ khloñ saṃtāp** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធានបរិស័ទអ្នកស្តាប់ធម៌ ដូចមានឧទាហរណ៍ ខ្លោញវលតខ្លោញសំតាបិ khloñ vala ta khloñ saṃtāp K.198A,៩៦៦នៃគ.ស.បន្ទាត់ទី១៥-១៦ ដែលមានន័យថា ប្រធានប្រជាពលរដ្ឋជាប្រធានបរិស័ទអ្នកស្តាប់ធម៌ ជាដើម។

### ៣.២០- ខ្លោញស្នំ

វាក្យសព្ទ **ខ្លោញស្នំ** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធាននៃក្រុមស្រីស្នំ ដូចមានឧទាហរណ៍ ខ្លោញស្នំ *khloñ* snaṃ K.222,សតវត្សរ៍ទី១១បន្ទាត់ទី១៥ ដែលមានន័យថា នាយកពួកស្រីស្នំ ជាដើម។

### ៣.២១- ខ្លោញស្រុ/ស្រូ

វាក្យសព្ទ **ខ្លោញស្រុ/ស្រូ** គោរមងារមន្ត្រីទទួលបន្ទុកជាប្រធាន/នាយកខាងស្រូវ អង្ករ ដូចមានឧទាហរណ៍ ខ្លោញស្រូ *khloñ* srū K.957A,៩៤១នៃគ.ស.បន្ទាត់ទី១៦ ដែលមានន័យថា នាយកទទួលបន្ទុកខាងស្រូវអង្ករ ជាដើម។

## សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាប្រធានបទស្តីពី **ទំនៀមពីបុរាណតាមរយៈសិលាចារឹក**នេះ នៅក្នុងសិលាចារឹកសម័យមុនអង្គរនិងសម័យអង្គរលើបីចំណុចធំនេះ ដែលក្នុងនោះមាន **ស្ថាននាមសម្គាល់ដែនដីរដ្ឋបាល ឋានន្តរនាម/ឋានន្តរសក្តិ និងការបែងចែករដ្ឋបាលគ្រប់គ្រង តាមរយៈសិលាចារឹកសម័យមុនអង្គរនិងសម័យអង្គរ** មិនទាន់លម្អិតគ្រប់ជ្រុងជ្រោយនៅឡើយទេ។ ទោះជាយ៉ាងនេះក្តី ការសិក្សានេះជាស្ពានមួយសម្រាប់ការសិក្សាឱ្យលក្ខណៈស៊ីជម្រៅនាពេលអនាគត។

## គន្ថនិទ្ទេស

- ពុទ្ធសាសនបណ្ឌិត្យ : វចនានុក្រមខ្មែរ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧-១៩៦៨។
- ឡុង សៀម : វាក្យស័ព្ទសំស្ក្រឹតដំបូងក្នុងភាសាខ្មែរបុរាណ និងស្ថាននាម មានប្រភពចេញពីសំស្ក្រឹត, នៅក្នុង : ទស្សនាវដ្តីកម្ពុជសុរិយា លេខ១ ឆ្នាំទី៥០ ១៩៩៦
- ឡុង សៀម : ទំរង់វេយ្យាករណ៍នៃនរនាម(ឯកសារសិលាចារឹកកម្ពុជា) នៅក្នុង : ទស្សនា វដ្តីកម្ពុជសុរិយា លេខ២ ឆ្នាំទី៥០, ១៩៩៧។

- ឡុង សៀម : ស្ថាននាមវិទ្យាខ្មែរ  ភ្នំពេញ ពុទ្ធសាសនបណ្ឌិត្យ  ១៩៩៧ ។
- ឡុង សៀម : បញ្ហាវចនស័ព្ទវិទ្យា  ភ្នំពេញ  ផ្សាយដោយអ្នកនិពន្ធ ១៩៩៩ ។
- ឡុង សៀម : វចនានុក្រមខ្មែរបុរាណ  (តាមរយៈសិលាចារឹកបុរេអង្គរ សតវត្សរ៍ទី៦-៨)   រោងពុម្ពភ្នំពេញ ២០០០ ។
- ឡុង សៀម : " អំពីកិត្យានុភាព និងការអភិវឌ្ឍន៍ភាសាខ្មែរ( ជាពិសេសតាមឯកសារភាសា មន-ខ្មែរ និងសិលាចារឹកកម្ពុជា )"នៅក្នុង : ទស្សនាវដ្ដីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត -សភាកម្ពុជា  លេខ ០២ មិថុនា ២០០១ ។

## ស្នាដៃជាភាសាបរទេស

- Coedès.G, ***Inscriptions du Cambodge,*** Hanoi, BEFEO,VolumeI, 1937.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeII, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeIII, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeIV, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeV, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeVI, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeVII, 1942.
- Coedès.G, ***Inscriptions du Cambodge,*** Paris, BEFEO,VolumeVIII, 1942.
- Jenner Philip N, ***A chrestomathy of Pre-Angorian Khmer I, Dated Inscriptions from the seventh and Eighth Cenyuries( A.D.611-781),*** University of Hawaii, White Lotus, 1980.
- Jenner Philip N, ***A chrestomathy of Pre-Angorian Khmer II, Lexicon of the Dated Inscriptions,***University of Hawaii, Publication by Author, 1981.
- Jenner Philip N, ***A chrestomathy of Pre-Angorian Khmer III, Undated Inscriptions from the Sixth to the Eighth Century,*** University of Hawaii, Publication by Author,1988.
- Jenner Philip N, ***A chrestomathy of Pre-Angorian Khmer IV, Lexicon of the Undated Inscriptions,*** University of Hawaii, Publicaion by Author, 1982 .
- L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome I, 1926.
- L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome II, 1926.
- L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome III, 1927.
- L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome IV, 1928.
- L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome V, 1931.
- L'académie des Inscriptions et Belles-Lettres, ***Inscriptions du Cambodge,*** Paris, Tome VI, 1937.
- Pou Saveros, ***Dictionaire Vieux Khmer- Français-Anglais an Old Khmer-French Dictionary,*** Paris, Cedoreck, 1992.

# សិលាចារឹកវត្តព្រះពុទ្ធឃោសាចារ្យ (វត្តចិនដំដែកខាងត្បូង) K. 1213 និង ព្រឹត្តិការណ៍មួយចំនួននៅប្រទេសកម្ពុជានាដើមសតវត្សរ៍ទី១៩

ដោយ បណ្ឌិត **ជុំ សុ៊នណាង**, លោក **កែវ លីណែត**, លោក **វ៉ាន់ ម៉ូន**, លោកស្រី **អុឹង ម៉ាល័យ**

## ១. រំឭកប្រវត្តិសាស្រ្តនៅពាក់កណ្តាលសតវត្សរ៍ទី១៩ នគរខ្មែរ នគរសៀម នគរលាវ និង នគរយួន

អតីតចៅក្រមព្រៃនគរជនជាតិបារាំងឈ្មោះ **ប៉ូស្តែល** បានលើកក្នុងសៀវភៅរបស់លោកក្នុងឆ្នាំ១៨៨២ ទាក់ទងនឹងព្រឹត្តិការណ៍អតីតកាលនា៤០ឆ្នាំមុន ពោលគឺ សង្គ្រាមខ្មែរ-សៀម-យួននៅភ្នំពេញ។ ក្នុងឆ្នាំ១៨៦៥ ភ្នំពេញមានប្រជាជនប្រហែល៦ពាន់នាក់។ កាលពីឆ្នាំ១៨៣៤ មុនពេលទ័ពសៀមចូលមកដុត ភ្នំពេញមានប្រជាជនប្រមាណ៥ម៉ឺននាក់។[20] លោក **ហ្គានីញេរ** អ្នកដឹកនាំការរុករកទន្លេមេគង្គនៅឥណ្ឌូចិន បានបញ្ជាក់ព្រឹត្តិការណ៍ទ័ពសៀមដុតភ្នំពេញដែរ ប៉ុន្តែ ចំនួនប្រជាជនដែលរស់នៅមានប្រហែល៥ម៉ឺននាក់។[21]

គោលនយោបាយព្រះរាជាវៀតណាម **យ៉ា ឡុង** (១៧៦២-១៨២០) បន្តអនុវត្តការគ្រប់គ្រងបែបមិនផ្ទាល់លើទឹកដីខ្មែរដែលជណ្តើមកាន់កាប់និងធ្លាក់ចូលក្នុងអំណាចរបស់ខ្លួនចាប់ពីសតវត្សទី១៧។ ក្នុងរាជ្យព្រះចៅ **មីញ ម៉ាង** (១៧៩១-១៨៤១) ជាពិសេស នៅអំឡុងឆ្នាំ១៨៣០ ទ្រង់បានបោះបង់នយោបាយមិនផ្ទាល់និងអនុវត្តនយោបាយសមានកម្ម[22]។

ក្នុងការគ្រប់គ្រងរបស់សៀមរវាងឆ្នាំ១៨៣០-១៨៧០ ខេត្តត្រូវបែងចែកក្នុងក្រៅ។ ខេត្តក្នុងជាខេត្តស្ថិតនៅកៀកនឹងនឹងរាជធានី។ ចៅហ្វាយខេត្តខ្មែរចំនួន៥ គឺ *សង្ខះ, សុរិន្ទ, ស៊ីសាកេត, គោកខណ្ឌ* និង *ដេត* ព្រមទាំង នគររាជសីមា ត្រូវបានផ្តល់ឋានៈតាមបែបសៀម។ ថ្វីត្បិតខេត្តទាំងនេះនៅឆ្ងាយពីអំណាចកណ្តាលក្តី ក៏ពួកវាត្រូវបានចាត់ទុកថាជាខេត្តក្នុង។ អំឡុងពេលនោះ នគរសៀមនិងនគរវៀតណាមបានប្រឈមគ្នាក្នុងការបែងចែកអំណាចនៅត្រើយខាងលិចខាងកើតនៃទន្លេមេគង្គភាគកណ្តាល។ នៅដើមរាជ្យ **ព្រះរាមាទី៣** (១៨២៤-១៨៥១) សៀមងាកពីទិសខាងលិចមកខាងកើត។ នគរសៀមចង់ធ្វើឱ្យមានអព្យាក្រឹតភាពផ្នែកខ្លះនៃទន្លេមេគង្គខាងឆ្វេងដើម្បីបង្កើតជាតំបន់ទ្រនាប់ទប់នឹងនគរអណ្ណាម។[23] ដើម្បីការពារដែនដីភាគខាងត្បូង នយោបាយព្រះចៅ **រាមាទី៣** ជំរុញចៅហ្វាយខេត្តឱ្យនាំប្រជារាស្រ្តតាំងលំនៅនៅត្រើយខាងស្តាំទន្លេមេគង្គឡើងវិញ។ នៅឆ្នាំ១៨៤៣ ទន្លេរពៅ (Selamphao) ជាដែនដីរណបចម្ប៉ាសាក់ ហើយ មូលព្រៃ (Manophrai) ជាចំណុះគោកខណ្ឌ។[24]

---

[២០] Roul Postel, *Cochinchine : Annam, Ton-Kin,* (Paris : A. Degorce-Cadot, 1882), p. 172.

[២១] Francis Garnier, *Travels in Cambodia and Parto of Laos: The Mekong Exploration Commission Report (1866-1868) – Volume I,* Trans. and with an Introduction by Walter E. J. Tips. (Bangkok: White Lotus, 1996), p. 48.

[២២] Choi Byung Wook, *Southern Vietnam under the Reign of Minh Mạng (1820-1841): Central Policies and Local Response,* (New York: SEAP, 2004), p. 135.

[២៣] Kennon Breazeale, *The Intergration of the Lao States into the Thai Kingdom,* PhD Diss., University of Oxford, 1975, p. 25.

[២៤] *Ibid,* p.58.

ក្នុងរវាងឆ្នាំ១៨៣០-១៨៤០ ចៅពញា **បឌិនតេជា** មានវត្តមានក្នុងចម្បាំងនៅនគរលាវនិងនគរខ្មែរ។ វត្តមានរបស់លោកស្ថិតមួយភាគធំក្នុងរាជ្យព្រះអង្គ **មុី** ក្សត្រី និង ព្រះអង្គ **ដួង**[25]។

ចៅពញា **បឌិនតេជា** (เจ้าพระยาบดินทรเดชา, ១៧៧៧-១៨៤៩) មានឈ្មោះផ្ទាល់ខ្លួនថា **សិង្ហ សិង្ហសេនី** (สิงห์ สิงหเสนี) ជាមេទ័ពក្នុងរាជ្យព្រះចៅ **រាមាទី៣**។ ក្រៅពីនេះ លោកមានតំណែងជាអគ្គមហាសេនាបតីសមុហនាយក។ លោកត្រូវព្រះ**រាមាទី៣**បញ្ជូនមកវាយនឹងនគរលាវនិងនគរខ្មែរ។ នៅនគរលាវ មានការងើបប្រឆាំងអំណាចសៀម (១៨២៦-១៨២៨)។ ចលនាប្រឆាំងនេះដឹកនាំដោយព្រះចៅ **អនុវង្ស** វៀងចន្ទន៍។ ព្រះចៅ **រាមាទី៣** បានបញ្ជូនព្រះបិតុលា **សម្តេចព្រះបវររាជចៅមហាសក្តិ ពលសេព** (สมเด็จพระบวรราชเจ้ามหาศักดิพลเสพ) អមដំណើរដោយចៅពញា **បឌិនតេជា** ទៅបង្ក្រាប។ ព្រះចៅ **អនុវង្ស** ត្រូវចាប់ដាក់ទ្រុងដែកនាំទៅរាជធានីបាងកកនិងទុក

---

គេគួរបញ្ជាក់បន្តិចពីការវិវត្តប្រវត្តិសាស្ត្រទាក់ទងអតីតដែនដីខ្មែរទាំងពីរខាងលើ។ អ្នកស្រាវជ្រាវរុករកបារាំងនៅចុងសតវត្សរ៍ទី១៩ បានបញ្ជាក់ខេត្តម្លូព្រៃ អស់រយៈពេលជាពីរបីជំនាន់ហើយជាខេត្តមួយរបស់ខ្មែរ។ ឧកញ៉ា តេជោ **មុឹង** ដែលរត់គេចពីកំពង់ស្វាយ បានចូលមកនៅម្លូព្រៃ និង សូមការការពារពីខេត្តគោកខណ្ឌក្រោមការគ្រប់គ្រងរបស់សៀម។ ចៅហ្វាយខេត្តគោកខណ្ឌថ្វាយដំណឹងដល់រាជធានីបាងកក ហើយ ព្រះរាជាសៀមយល់ព្រម។ បន្តិចក្រោយមក ដោយត្រូវចោទថាក្បត់នគរសៀមដោយកូនប្រសារបស់ខ្លួននិងបក្ខពួកកូនប្រសារ ឧកញ៉ាតេជោរូបនេះត្រូវបញ្ជូនទៅរាជធានីបាងកក ហើយ លោកទទួលមរណភាពនៅទីនោះ។ កូនប្រសារបស់ខ្លួននិងបក្ខពួកកូនប្រសាដែលគ្រប់គ្រងម្លូព្រៃស្ថិតក្រោមចំណុះគោកខណ្ឌទោះបីអ្នកទាំងនេះចង់ស្ថិតក្រោមផ្ទាល់បាងកកផ្ទាល់ក្តី។ គេមានលោក Aymonier ម្លូព្រៃមានរាស្ត្រក្នុងបញ្ជីចំនួន៥៥៧នាក់។ លោក Aymonier យល់ថាចំនួនច្រើនជាងនេះ។ ម្លូព្រៃជាខេត្តចំណុះខេត្តគោកខណ្ឌ។ ពេលសួយសារអាករផ្ញើពីម្លូព្រៃមកគោកខណ្ឌ គោកខណ្ឌបន្តបញ្ជូនទៅបាងកក។ សួយពីម្លូព្រៃនេះមានក្រមួន, ភ្លុក, ស្នែងរមាស។ ចៅហ្វាយខេត្តម្លូព្រៃមានងារជា ព្រះមនោចំណាង ភូសម្រេចរាជការ មឿងម្លូព្រៃ។ មន្ត្រីបន្តបន្ទាប់ គឺ ១. ហ្លួងភក្តីភូធរ, សង្គ្រាម, បាឡាត់; ២. ហ្លួងកែវមន្ត្រីយោក្បាត់, ៣. ហ្លួងភក្តីបរិរក្សភូឈួយ, ៤. ហ្លួងភក្តីសង្គ្រាមចតុរង្គ។

ខេត្តទន្លេរពៅ នៅពេលនោះ ខាងកើតជាប់ទន្លេធំ (ទន្លេមេគង្គ) ដែលចេកស្ទឹងត្រែងនិងខុង, ខាងជើង ជាប់បា-សាក់, ខាងលិច ជាប់ជួរភ្នំដងរែកនិងម្លូព្រៃ និង ខាងត្បូង ជាប់ស្រុកខ្មែរ ព្រះរោង។ គេត្រូវធ្វើដំណើរអស់៦ថ្ងៃពីជើងទៅត្បូង និង អស់៤ថ្ងៃពីកើតទៅលិច។ ប្រជារាស្ត្ររស់នៅរាយប៉ាយដែលមានខ្មែរ និង លាវមួយចំនួន រស់នៅតាមមាត់ទឹក និង កួយដែលរស់នៅខាងក្នុងៗ។ ជាច្រើនឆ្នាំ ខេត្តទន្លេរពៅមានត្រឹមបាឡាត់បំពេញមុខងារជាចៅហ្វាយខេត្ត។ ចៅហ្វាយខេត្តចុងក្រោយនេះទើបទទួលមរណភាព។ លោកមានងារជា ហ្លួងអភ័យភូធរសង្គ្រាម បាឡាត់មឿង ទន្លេរពៅ។ នៅខេត្តនេះមានប្រជារាស្ត្រ៤ទៅ៥រយបង់ពន្ធខ្លួនជាក្រមួនឃ្មុំ។ ដើមឡើយ ខេត្តទន្លេរពៅ សួយសារអាករ ក្រៅពីក្រមួន ត្រូវបញ្ជូនប្រាក់១០ណែនទៅរាជធានីបាងកក។ មន្ត្រីនានាត្រូវទៅផឹកទឹកសម្បថនៅបាសាក់។ នៅពេលដែលអ្នកស្រាវជ្រាវបារាំងទៅស្រាវជ្រាវនោះ ខេត្តនេះត្រូវលើកលែងសួយជាប្រាក់។ រូបិយបណ្ណនៅទន្លេរពៅ ក៏ដូចម្លូព្រៃ មានប្រាក់ណែន, បាទសៀម (មិនសូវមាន), ពៃសៀមរាប និង ឆ្ពោរដែក ដែលជំផលិតក្នុងព្រៃកួយ ស្រុកកំពង់ស្វាយ។ ដុល្លារម៉ិចស៊ិក ចាប់ផ្តើមមានចរាចរណ៍ហើយ។ (cf. Étienne Aymonier, "Notes sur le Laos", dans *Excursions et Reconnaissances,* VIII, N$^{0}$ 20 Novembre-Décembre 1884, Saigon : Imprimerie du Gouvernment, 1885. p. 322-327.)

[២៥] អេង សុត, *ឯកសារមហាបុរសខ្មែរ,* ទំ.១០៤៩-១០៩៧។ នៅទំព័រ១០៥៦ ពង្សាវតារខ្មែរបានបញ្ជាក់ថានៅគ.ស.១៨៤២ ព្រះរាជាសៀម **ណាំងក្លាវ** (**រាមាទី៣**) ចាត់ពញា **បឌិនតេជោ** ជាមេទ័ពនាំសេនាសៀមចំនួន១៥ ០០០ហែព្រះអង្គ **ដួង** ចូលនគរខ្មែរវិញ។

ជាការពិត ការយាងចូលនគរវិញរបស់ព្រះអង្គ **ដួង** មិនមែនមានន័យថាបញ្ចប់សង្គ្រាមនោះទេ។ ទ័ពយួននិងទ័ពសៀមបានប្រយុទ្ធគ្នាចន្លោះភ្នំពេញនិងឧដុង្គរហូតដល់មានការព្រមព្រៀងសម្រេចជារួមរវាងមេទ័ពនៃនគរយួននិងនគរសៀមលើកព្រះអង្គ **ដួង** ឡើងគ្រងរាជ្យបន្តពីព្រះអង្គ **មុី** ក្សត្រី។

ក្នុងទ្រុងដែកឱ្យមហាជនមើល និង ធ្វើបាបរហូតដល់សុគត។ តាមរយៈគុណបំណាច់ក្នុងសង្គ្រាម ចៅពញា **បឌិនតេជា** ត្រូវបានដំឡើងពីពញាមកជាចៅពញារាជសុភាវតី។

ចៅពញា **បឌិនតេជា** កើតនៅរាជធានីបាងកកសម័យធនបុរី។ ឪពុករបស់លោកឈ្មោះ អភ័យរាជ **ពិន**, ម្ដាយឈ្មោះ **ហ៊ីក**។ ឪពុកលោកបញ្ជូនលោកឱ្យទៅបម្រើព្រះអង្គម្ចាស់ **ឥស្សរាសន្ទរ** រាជទាយាទ។ ក្រោយមក ព្រះអង្គម្ចាស់ឡើងគ្រងរាជ្យជា **ព្រះពុទ្ធលើតឡានភាល័យ** ឬ **រាមាទី២**។ នៅពេលនោះ ចៅពញា **បឌិនតេជា** បានស្គាល់ព្រះអង្គម្ចាស់ **ជេស្ដាបឌិន** ដែល ក្រោយមក ឡើងសោយរាជ្យជា **រាមាទី៣**។ ក្រោយមកទៀត ចៅបញា **បឌិនតេជា** ឡើងឋានៈជា **បឌិនតេជា**។

ចៅពញា **បឌិនតេជា** ត្រូវបានបញ្ជូនក្នុងយុទ្ធនាការសង្គ្រាមសៀម-អណ្ណាមលើទឹកដីខ្មែររវាងឆ្នាំ១៨៣១-១៨៣៤ និង ១៨៤១-១៨៤៥។ ព្រះចៅ **រាមាទី៣** គាំទ្រដល់ការឡើងគ្រងរាជ្យរបស់ព្រះបាទអង្គ **ដួង**។ ចៅពញា **បឌិនតេជោ** នៅប្រទេសកម្ពុជារហូតដល់ឆ្នាំ១៨៤៨។ មួយឆ្នាំក្រោយមក លោកបានស្លាប់ដោយជំងឺអាសន្នរោគ។[26]

## ២. ខ្លឹមសារសិលាចារឹក

### ២.១- អត្ថន័យសង្ខេប

នៅឆ្នាំ១៨៣៩ ព្រះរាមាទី៣ នៃនគរសៀម បានបញ្ជូនមេទ័ពឈ្មោះ ចៅពញា **បឌិនតេជា** លើកទ័ពចូលកម្ពុជា។ ក្រោយពីតាំងនៅប្រទេសកម្ពុជាមួយរយៈមក មេទ័ពនេះបានភ្នំពេញ ហើយ បានឃើញព្រះវិហារនៅវត្តព្រះឃោសាចារ្យ (វត្តចិនដំដែក) ទ្រុឌទ្រោម លោកក៏ជួសជុលព្រះវិហារនិងសាងចេតិយបញ្ចុះព្រះបរមសារីរិកធាតុ។

### ២.២- ទម្រង់និងខ្លឹមសារ

**លេខសិលាចារឹក** ៖ K. 1213
**ទីតាំង** ៖ ផ្ទាំងសិលាឆ្លាក់ចារឹកជាប់នឹងចេតិយខាងមុខព្រះវិហារបែរមុខទៅកើតនៃវត្តព្រះពុទ្ធឃោសាចារ្យ
**អក្សរថៃ** ៖ ភាសាថៃ, ពាក្យមួយចំនួនមានប្រភពពីភាសាខ្មែរ
**សករាជ** ៖ ២៣៨៥
**ចំនួនបន្ទាត់** ៖ ៣០បន្ទាត់

លើកលែងជាភាសាខ្មែរ សិលាចារឹកវត្តព្រះឃោសាចារ្យនេះមានការសិក្សាខ្លះៗមកហើយ និង មានអំណានអក្សរចេញពីសិលាចារឹកដើមជាភាសាថៃទំនើបដោយលោក **សាន្តិ ភក្តីគាំ** (ศานติ ภักดีคำ)។[27] ដោយចង់រក្សាបូរណភាពនៃខ្លឹមសារនិងពាក្យពេចន៍យើងបានប្រែសម្រួលសេចក្ដីមកជាភាសាឱ្យខ្មែរមិនខ្លាំងពេក។ ធ្វើបែបនេះ យើងសង្ឃឹមថាមានប្រយោជន៍ដល់អ្នកស្រាវជ្រាវឯទៀតដើម្បីជញ្រករសជាតិដើម។ យើងនឹងសិក្សាលើទិដ្ឋភាពភាសាក្នុងសិលាចារឹកនេះនៅពេលក្រោយ។

---

២៦ https://military-history.fandom.com/wiki/Bodindecha ( accessed 16.10.22. )

២៧ Vol. 5 No. 2 ( 2006 ): July – December, https://so01.tci-thaijo.org/index.php/damrong/article/view/20998 ( accessed14.01.25 )

1. ๑ ศุภมัสดุ จุลศักราช 1201 ปี สุกรสังวัชระ เอกะศกบุคมาศ กาลปักษดิฐิจตุรัศมี โสรวารประมี
2. กาลกำหนฎพระบาทสมเด็จบรมนาถบรมบพิตพระพุทธเจ้าอยูหัวกรุงเทพมหานครมีพระราชโอง
3. การมาณพระบันทูลสุรสิงหนาทสำหรัดสังให้เจ้าพญาบดินเดชาทีสมุหนายกอัคมหาเสนาธิบดี
4. ภัยพิริยปรากรมพาหุ ยกพยุหยาตราออกจากกรุงเทพทวาราวดีศีอยุทยามหาดิลกภพนพ
5. รัตนราชธานีบุรีรมอุดมราชมหาสถาน เพือจะให้ปราบเหลาผ่าพาลมฤจฉาทิฐิจิตอันคิดอักตัญ
6. มิได้รู้จักพระเดชพระคุณสมเดจ์พระพุทเจ้าอยูหัวยกตัวเปนอตุกังสนธิ มีมาณะอันกรดางกำเริบ
7. เอิบเอือมลวงเข้ามาตั้งหมั้นอยูในกำภุชประเทศอันเปนเขตขันทสีมาพระราชอาณาปะวัตของสมเดจ์
8. พระพุทธเจ้าอยูหัวผู้ทรงพระคุณเปนมหาบุพการี ครั้นเจ้าพญาบดินเดชากออกมากระทำศึกสํง
9. ครามกอบด้วยมหาพิริยภาพพะยายามอุสาหะมีไชยฉณะคืนเอาเขตแดนกำภุชาได้จึงเหนพระอา
10. รามน้อยใหญ่ในแขวงเมืองพนมเปนปรักหักพังลงหลายตำบล กามาพจรกุศลก็บังเกิดขึ้น
11. ในมโนทวารวิถีจิตรสู้เสียสละทรัพเป็นมูลค่าจ้างให้ไพรพลในกองทัพชวยปติสังขรณซอม
12. แปลงวิหารอุโบสถทังพระพุทธรูปพระสถูปพระเจดียหวังจให้พระพุทธศาสนาจิรฐีติกาลนานปี
13. ตั้งหมั้นรุงเรืองไปเบื้องหน้าแล้วบังเกิดปักขันทิกะศัทาอันสามาถสร้างพระเจดีย์บันจุพระบรม
14. สารีริกธาตุประดิษถานขึ้นใหม่อีกองค์หนึงสูงห้าวาสามศอกคืบ พุทธศักรราชล้วงได้ 2385
15. ปีพยัฆสังวัชรอาสุชมาสกาลปักษาดิภุษฐีอัถะมีคูรรวารบรีเฉท หวังไว้เปนทีสังเกตสถาน
16. บูชาทั่วไปแก่สมณพราหมณาจารมนุษนิกรแลหมู่อมรเทพวิชาธรกินรนาคสุบัณคนธรรพ์
17. ...[แ]ทตยสุรารักษรุกขพิมานมาศหนึงข้าผู้มีจิตประสาทโสมนัสถาปนาการกอปก่อสร้าง
18. ...[พระเจ]ดียถานขึนไว้ครังนี มิได้มีมโนภิรมยยินดีปราถนาสมบัดอินท์พรหมยม...
19. ...แต่ปวรเสวตรฉัตรวิมุตพระพุทธภูมถ่ายเดียว แม้นว่าข้าพเจ้ายังทอง[วัฏ]
20. [สงสาร]สาครตราบใด ฃอให้ขจัดจากพวกพาลอันเปนอกุศลพุทธภูมิปัจโยโหตุ
21. ...[ข้าพ]เจ้าขออัญเชิญภูมเทวดาอารักษเทวดาพฤกษเทวดาแลอาการเทวดาเท่าถึงโส [พส]
22. ... [พ]รหมขอจงมาสโมสรชืนชมชุมนุมกันชวยอภิบาลบำรุงรักษาซึงพระเจดียธาตุนี...
23. ...[พา]สมฤจฉาทิฐิมารันทำยำยีให้เป็นอนตรายได้จงให้ประดิษถานถาวรคำรํงชานานไปถวน
24. ...[ห้าพั]นพระวะษาเรากละปะนาอุทิศสวนกุศลนั้นให้ทุกทัวเทพผู้อภิบาลบริรักษพระบรมธาตุ
25. เจดีย จงเจริญศิริสวัสดิสุนทรในบวรทิพรัตนพิมานเมศ ให้มีมเหษรสักตาเดชยิ่งขึนไป
26. แม้นว่าเทพยุดาพวกใด มิได้มีจิตปรสาทเลือมใสชวยบำรุงรักษาพระเจดียเหตุมีจิตเปนอกุ
27. ศลจุติจากเทวโลกลงไปเสวยทุกขเวทนาอยู่ในมหานะรกชานาน
28. หนึงมนุษแลสมณะพราหมณาจารชีประขาว ผิและแกล้งกระทำให้องค์พระเจดิยนี้ราน
29. ร้าวสสำสลายทำลายลงก็จะมิอาจ์ดำรํงชนมะชีพอยู่นานได้ จะถึงซึงประไลตัวยภยัน
30. ตรายต่างๆ เบื้องวาจุติจากมนุษโลกแล้วก็จลงไปเกิดในมหานรกมกไมอยูสินกาลชานานฯ๛

## ២.៣- សេចក្តីសម្រួលជាភាសាខ្មែរ

១. សុភមស្តុ ចុលសករាជ១២០១ សុក្រស័វច្ឆរៈ ឯកគកបុស្សមាស កាលបក្សក្ស័យតិថីចតុរស្នមី សៅរ៍បូរមី
២. កាលកំណត់ព្រះបាទសម្តេចបរមនាថបរមបពិត្រព្រះពុទ្ធិចៅយួយ្ហ ក្រុងទេពមហានគរមានព្រះរាជឱង-
៣. ការមានព្រះបន្ទូលសុរសិង្ហនាទតម្រាស់ឲ្យចៅពញាបជិនតេជា ទីសមុហនាយក អគ្គមហាសេនាបតី
៤. ភ័យភិរិយព្រះក្រុមពាហុ លើកព្យុហយាត្រាចេញចាកក្រុងទេពទ្វារវតីស្រីអយុធ្យា
៥. រតន៍រាជធានីបុរីរមឧត្តមរាជមហាស្ថាន ដើម្បីឲ្យទៅបង្រ្កាបពួកពាលមិច្ឆាទិដ្ឋិចិត្តអកត្តញ្ញូ
៦. មិនដឹងព្រះតេជព្រះគុណសម្តេចព្រះពុទ្ធិចៅយួហ្ល តាំងខ្លួនជាអគុកំងសន្និមានមានៈតាំងចិត្តកម្រើក
៧. តាំងនៅក្នុងកម្ពុជប្រទេសជាខេត្តខណ្ឌសីមាព្រះរាជាណាចក្ររបស់សម្តេច
៨. ព្រះពុទ្ធិចៅយួហ្លទ្រង់ព្រះគុណជាមហាបុព្វការី។ គ្រានោះ ចៅពញាបតិនតេជាលើកទ័ពចេញធ្វើសឹក
៩. ដោយមហាវីរិយភាពព្យាយាមឧស្សាហ៍មានជ័យជម្នះយកខេត្តដែនកម្ពុជា ហើយ បានឃើញព្រះរាជ
១០. អាណាចក្រតូចធំក្នុងខ្វែងមឿងភ្នំពេញទ្រុឌទ្រោមយ៉ាងជំបន់ ក៏មានកាមាវចរកុសលកើតឡើង
១១. នៃមនោទ្វារវិថីចិត្រលះបង់ទ្រព្យមានតម្លៃឲ្យកងទ័ពជួបបដិសង្ខរណ៍
១២. ជួសជុលវិហារឧបោសថាគារទាំងព្រះពុទ្ធរូប ព្រះសថូប ព្រះចេតីយ៍ សង្ឃឹមថានឹងព្រះពុទ្ធសាសនាតាំងចិរ
កាលយូរអង្វែងឆ្នាំ
១៣. តាំងនៅរុងរឿងដើម្បីសាងព្រះចេតីយ៍បញ្ចុះព្រះបរម
១៤. សារីរិកធាតុប្រតិស្ឋានឡើងថ្មីមួយអង្គកម្ពស់៥វ៉ា៣សកខឹប នាពុទ្ធសករាជ២៣៨៥
១៥. ឆ្នាំព្យគ្ឃសង្វរ អស្សុជមាសកាលបក្ស័យ តិថីអដ្ឋមី មើលបរិច្ឆេទរកទីសង្កេត
១៦. បូជាទូទៅចាស់ សមណព្រាហ្មណាចារ្យ មនុស្សនិករ អមរទេពវិជ្ជាធរ កិន្នរ នាគ សុបណ្ណ គន្ធព
១៧. ទេពសុរារក្ស រុក្ខពិមានមាស មានចិត្រប្រសាទកសាង
១៨. ព្រះចេតីយ៍ឋានឡើងគ្រានេះ ដោយមានមនោភិរម្យចិត្តល្អប្រាថ្នាសម្បត្តិឥន្ទព្រហ្ម
១៩. ស្វេតច្ឆត្រព្រះពុទ្ធភូមិប៉ុណ្ណោះ សូម្បីខ្ញុំព្រះអង្គនៅក្នុងវដ្ត-
២០. សង្សារសាគរតរាបទៅ ក៏សូមវៀរចាកពួកពួលអកុសលពុទ្ធភូមិបច្ចយោហោតុ
២១. សូមអញ្ជើញភូមិទេវតាអារក្សទេវតា ព្រឹក្សទេវតា និង អាកាសទេវតា រហូតសោឡស
២២. ព្រហ្មសូមសមោសរីករាយអភិបាលបម្រុងរក្សាព្រះចេតីយ៍
២៣. ... ពាលមិច្ឆាទិដ្ឋិមកធ្វើយាយីឲ្យអន្តរាយដែលចង់ឲ្យប្រតិស្ឋានឋាវរៈជាយូរអង្វែង
២៤. ... ប្រាំពាន់ព្រះវស្សា យើងឧទ្ទិសសួនកុសលនេះទៅគ្រប់ទេពអ្នកអភិបាលបរិក្សព្រះបរមធាតុ
២៥. ចេតីយ៍ ចម្រើនសិរីសួគ៌សុន្ទរបវរទិព្វរត្នពិមានមេស ឲ្យមានមហេសរសក្តាតេជៈឡើង
២៦. សូម្បីទេពតាពួកណាដែលមានចិត្រប្រសាទទៅជួយបម្រុងរក្សាព្រះចេតីយ៍ហេតុមានចិត្តជា
២៧. អកុល ចូរចុតិចាកទេវលោកទៅស្នោយទុក្ខវេទនានៅមហានរកអស់កាលយូរ
២៨. និងមនុស្ស សមណព្រាហ្មណាចារ្យតាជី
២៩. ទម្លាយព្រះចេតីយ៍ នឹងសឹងប្រល័យដោយភ័យន្ត-
៣០. រាយនានា ពីព្រោះចុតិចាកមនុស្សលោកហើយក៏ធ្លងទៅកើតក្នុងមហានរកអស់កាលយូរអង្វែង។

# គន្ថនិទ្ទេស


អេង សុត, *ឯកសារមហាបុរសខ្មែរ,* ភ្នំពេញ, ១៩៦៩។

Aymonier, Étienne. "Notes sur le Laos", dans *Excursions et Reconnaissances,* VIII, N$^0$ 20 Novembre-Décembre 1884. Saigon : Imprimerie du Gouvernment, 1885.

Choi Byung Wook. *Southern Vietnam under the Reign of Minh Mạng (1820-1841): Central Policies and Local Response*. New York: SEAP, 2004.

Garnier, Francis. *Travels in Cambodia and Parto of Laos: The Mekong Exploration Commission Report (1866-1868)* – Volume I, Trans. and with an Introduction by Walter E. J. Tips. . Bangkok: White Lotus, 1996.

Breazeale, Kennon. *The Intergration of the Lao States into the Thai Kingdom.* PhD Diss., University of Oxford, 1975.

Postel, Roul. *Cochinchine : Annam, Ton-Kin.* Paris : A. Degorce-Cadot, 1882.

https://db.sac.or.th/inscriptions/inscribe/detail/2536

https://military-history.fandom.com/wiki/Bodindecha (22.10.22)

https://en.wikipedia.org/wiki/Chaophraya_Bodindecha (22.10.2024)

https://en.wikipedia.org/wiki/Rama_III (22.10.2024)




ក្រុមការងារចុះពិនិត្យសិលាចារឹកថ្ងៃទី០២ខែមីនាឆ្នាំ២០២៤ វត្តព្រះពុទ្ធឃោសាចារ្យ (វត្តចិនដំដែកខាងត្បូង)

ថតថ្ងៃទី០២ខែមីនាឆ្នាំ២០២៤



ថតថ្ងៃទី០២ខែមីនាឆ្នាំ២០២៤

# ការបង្កើតកម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេស

បណ្ឌិត ជុំ ស៊ុនណាង, បណ្ឌិត ណុន សុខា និងអ្នកឯទៀត
មន្ត្រីវិទ្យាស្ថានភាសាជាតិ រាជបណ្ឌិត្យសភាកម្ពុជា
snang_inl@yahoo.com

## មូលន័យសង្ខេប

ការស្រាវជ្រាវ ស្ដីអំពី "ការបង្កើតកម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេស" នេះ ធ្វើឡើងក្នុងបំណងពង្រឹងគុណភាពបណ្ដុះបណ្ដាលភាសានិងអក្សរសាស្ត្រខ្មែរដល់ជនបរទេសដែលសិក្សាភាសាខ្មែរឱ្យកាន់តែប្រសើរឡើង ក៏ដូចជាការរួមចំណែកលើកតម្កើងតម្លៃភាសានិងអក្សរសាស្ត្រខ្មែរដែលជាផ្នែកមួយនៃវប្បធម៌ជាតិផងដែរ។ ទិន្នន័យសម្រាប់ប្រើប្រាស់ជាបង្អែកក្នុងការសិក្សាវិភាគដើម្បីចងក្រងកម្មវិធីសិក្សានេះ បានប្រមូលមកពីប្រភពនានា ដូចជា គ្រឹះស្ថានសិក្សា បណ្ណាល័យ និងការសម្ភាសអ្នកជំនាញ។ ទិន្នន័យភាគច្រើនទាក់ទងនឹងកម្មវិធីសិក្សា និងឯកសារបង្រៀនភាសាខ្មែរ ទាំងសម្រាប់ជនជាតិខ្មែរនិងសម្រាប់អ្នកសិក្សាបរទេស។ ការអភិវឌ្ឍកម្មវិធីនេះ ផ្អែកលើទ្រឹស្ដីនៃការទទួលបានចំណេះដឹងភាសាទី២(Second Language Acquisition) និងជំហាននៃការទទួលបានចំណេះដឹងរបស់ Bloom's Taxonomy និងឈរលើមូលដ្ឋានក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។ លទ្ធផលនៃការស្រាវជ្រាវនាពេលនេះរកឃើញថា ការបណ្ដុះបណ្ដាលភាសាខ្មែរដល់ជនបរទេសកន្លងមក ច្រើនឈរលើមូលដ្ឋាននៃការកសាងសៀវភៅមេរៀន ឬឯកសារបង្រៀនជាមុន ដោយមិនសូវចាប់អារម្មណ៍ទៅនឹងការរៀបចំកម្មវិធីសិក្សាជាមុនឡើយ។ កម្មវិធីសិក្សាប្រៀបបាននឹងផែនទីដែលជួយនាំផ្លូវអ្នករៀននិងអ្នកបង្រៀនឆ្ពោះទៅគោលដៅនៃការផ្ដល់និងទទួលពុទ្ធិ ស្របតាមជំហាននៃការទទួលបានចំណេះដឹង។ តាមរយៈការប្រមូលផ្ដុំមុខវិជ្ជាដែលមានរួចហើយនៅតាមគ្រឹះស្ថានសិក្សានានា និងមុខវិជ្ជាដែលយើងបានបង្កើតបន្ថែមមួយចំនួនទៀត នឹងធ្វើឱ្យអ្នកសិក្សាកាន់តែទទួលបានចំណេះដឹងទូលាយអំពីភាសានិងអក្សរសាស្ត្រខ្មែរ។ យើងសង្ឃឹមថា ការសិក្សានាពេលនេះនឹងឆ្លើយតបទៅនឹងកង្វះខាតកន្លងមក និងកើតជាប្រយោជន៍តាមបំណងប្រាថ្នារបស់អ្នកសិក្សាតទៅ។

**ពាក្យគន្លឹះ៖** កម្មវិធីសិក្សា ភាសាទី២ ការទទួលបានចំណេះដឹង Bloom's Taxonomy

## The Developing of Khmer Curriculum for Foreigners

Dr. Chom Sonnang, Dr. Non Sokha
Royal Academy of Cambodia
+855 12 625 325
snang_inl@yahoo.com

ABSTRACT

The present research on 'The Developing of Khmer Curriculum for Foreigners' is to develop a curriculum for teaching the Khmer language to foreigners as well as contributing to the appreciation of Khmer language and literature. The data used for analysis were collected from various sources such as academic institutions, libraries, and interviews. Most of the data related to the Khmer curriculum and instruction, both for Khmer students and for foreign ones. The curriculum was developed basing the theory of Second Language Acquisition and Bloom's Taxonomy perspective and the Cambodian Qualification Framework. The results of the present study found that Khmer teaching for foreigners from the previous time was often started by the preparation of textbooks or teaching materials other than developing curriculum at first start. The curriculum is a map that helps guide the learner and the teacher towards the goal of giving knowledge and acquisition. The recent research is the integration work. Previous work on teaching Khmer for foreigners was combined to the recent result which may give broader and clearer knowledge of Khmer language and literature. We hope that the present study could serve as a guideline for lectures and foreign students to reach their goal of education.

**Keywords:** curriculum, second language, language acquisition, Bloom´s Taxonomy

## សេចក្ដីផ្ដើម

ភាសាបានក្លាយជាឧបករណ៍ទំនាក់ទំនងដ៏សំខាន់របស់មនុស្ស និងធ្វើឱ្យមនុស្សមានលក្ខណៈពិសេសដោយឡែកផ្សេងពីសត្វទាំងពួងនៅលើពិភពផែនដីនេះ។ មានភាសាប្រហែល ៧០០០ ភាសានៅលើលោកយើងនេះ(Fromkin. 2011 : 523)។ ភាសាខ្លះមានអ្នកប្រើតិចតួចប៉ុណ្ណោះ ឯភាសាខ្លះទៀតមានអ្នកប្រើច្រើនរាប់ពាន់លាននាក់។ ភាសាទាំងអស់កើតឡើងដោយរចនាសម្ព័ន្ធបួនជាចាំបាច់គឺ សូរ ពាក្យ ឃ្លា ល្បះ និងន័យ។ ទន្ទឹមនឹងរចនាសម្ព័ន្ធទាំងបួនដែលភាសាណាក៏មាន ភាសានីមួយៗមានលក្ខណៈដោយឡែកនៅក្នុងទិដ្ឋភាពលម្អិត។ នៅក្នុងភាសាថៃ ចិន វៀតណាម ជាដើម សុទ្ធសឹងមានសំឡេងសម្រាប់បង្ហាញពីបន្ថែកន័យរបស់ពាក្យ។ សំឡេងមិនមាននៅក្នុងភាសាខ្មែរ ប៉ុន្តែខ្មែរមានវិធីបង្កើតពាក្យតាមរយៈការប្រើមូលបទផ្សំជាមួយពាក្យឫស ដែលមូលបទមិនមានប្រើនៅក្នុងភាសាថៃទេ។ ភាសាអង់គ្លេសមានបច្ច័យបទសម្រាប់បន្ថែមទៅផ្នែកខាងចុងនៃពាក្យឫស ដែលមូលបទប្រភេទនេះមិនទាន់កំណត់ច្បាស់ថា មានឬមិនមាននៅក្នុងភាសាខ្មែរនៅឡើយទេ។

សហគមន៍នៃក្រុមជនជាតិនីមួយៗ សុទ្ធតែមានភាសាសម្រាប់ប្រើប្រាស់ក្នុងទំនាក់ទំនងរបស់ក្រុមខ្លួន។ ភាសាដែលមានអ្នកប្រើច្រើនបានពង្រីកឥទ្ធិពលរបស់ខ្លួន និងត្រូវបានលើកតម្កើងជាភាសាជាតិនៃប្រទេសមួយ។ ដូចយ៉ាង ភាសាខ្មែរដែលស្ថិតនៅក្នុងចំណោមភាសាស្អូច ស្មៀង ព្នង កួយ ជាដើម ត្រូវបានប្រើជាភាសាផ្លូវការនៃប្រទេសកម្ពុជា។ ភាសាវៀតមឿងជាភាសាផ្លូវការនៃប្រទេសវៀតណាម។ ភាសាខ្លះទៀត បានក្លាយជាឧបករណ៍ទំនាក់ទំនងរវាងជាតិសាសន៍មួយជាមួយជាតិសាសន៍មួយទៀត ឬប្រើជាយានទំនាក់ទំនងរវាងប្រទេសនិងប្រទេស ដូចជា ភាសាបារាំង អង់គ្លេស ជាដើម។ បច្ចុប្បន្ន ភាសាអង់គ្លេសត្រូវបានចាត់ទុកជាភាសាអន្តរជាតិ (The British Council. 1978 : 4)។

ក្រៅពីភាសាកំណើតរបស់ខ្លួន មនុស្សម្នាក់អាចប្រើភាសាទី២ឬភាសាបរទេសបានច្រើនភាសាបន្ថែមទៀតអាស្រ័យទៅលើសមត្ថភាពរៀនសូត្ររបស់គេ។ ការសិក្សាភាសាបរទេសមានគោលបំណងច្រើនយ៉ាង ក្នុងនោះគឺការរៀបចំឱ្យអ្នកសិក្សាទទួលបានចំណេះដឹងស៊ីជម្រៅអំពីវប្បធម៌របស់ជាតិមួយដោយផ្អែកលើភាសានិងអក្សរសិល្ប៍តាមរយៈការស្ដែងចេញជាទម្រង់នៃការនិយាយនិងសរសេរ។ ការទទួលបានចំណេះដឹងភាសាទី២បានច្បាស់លាស់នឹងជួយឱ្យអ្នកសិក្សាយល់និងចេះឱ្យតម្លៃភាពចម្រុះនៃវប្បធម៌ ជួយកសាងទំនាក់ទំនងរវាងសង្គមនិងសង្គម និងធ្វើឱ្យពិភពលោកហាក់តូចជាងមុននិងជាកន្លែងពោរពេញទៅដោយសេរីភាពវិសាលភាពធំទូលាយក្នុងការរស់នៅ។

ភាសាខ្មែរស្ថិតនៅក្នុងអម្បូរភាសាខ្មែរ-មន ប្រើជាភាសាផ្លូវការរបស់ប្រទេសកម្ពុជា និងជាភាសាដែលប្រើដោយជាតិពិន្ទុខ្មែរនៅខេត្តមួយចំនួននៅភាគខាងត្បូងនៃប្រទេសវៀតណាម និងប៉ែកឦសាននៃប្រទេសថៃ និងនៅបណ្ដាប្រទេសមួយចំនួនទៀត មានអ្នកនិយាយប្រមាណជិត១៨លាននាក់( Eberhard. 2019 )។

ក្រៅពីខ្មែរដែលជាម្ចាស់ភាសា ក៏នៅមានជនជាតិបរទេសជាច្រើននាក់ បានចាប់អារម្មណ៍សិក្សារៀនសូត្រនិងស្រាវជ្រាវអំពីភាសាខ្មែរ។ ការរីកចម្រើនខាងផ្នែកវិទ្យាសាស្រ្តបច្ចេកទេស និងទំនាក់ទំនងសេដ្ឋកិច្ច បានធ្វើឱ្យភាសាខ្មែរក្លាយជាគោលដៅសំខាន់មួយដែលធ្វើឱ្យជនបរទេសកាន់តែចាប់អារម្មណ៍នឹងភាសានេះ។ ការចេះភាសាខ្មែរអាចជាស្ពានក្នុងការឈានទៅសិក្សាស្វែងយល់អំពីមរតកវប្បធម៌ខ្មែរក៏ដូចជាការប្រើប្រាស់ក្នុងទំនាក់ទំនងប្រចាំថ្ងៃ កិច្ចការជំនួញ ការទូត និងការងារគ្រប់គ្រងរវាងជនបរទេសទាំងនោះជាមួយនឹងខ្មែរ។

ជាការពិត ការរៀននិងការបង្រៀនភាសាខ្មែរដល់ជនបរទេសមិនមែនទើបតែមាននាពេលបច្ចុប្បន្ននេះទេ គឺបានធ្វើឡើងច្រើនទសវត្សរ៍មកហើយ។ ក្នុងពេលកន្លងមក ទាំងអ្នករៀន ទាំងអ្នកបង្រៀនបានខិតខំស្វះស្វែងរកគ្រប់វិធី ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការរៀននិងបង្រៀន។ មានក្បួនតម្រាសិក្សាភាសាខ្មែរជាច្រើនបានត្រូវបង្កើតឡើងជាលក្ខណៈបុគ្គល ជាស្ថាប័នសិក្សា ដោយយោងទៅតាមបទពិសោធន៍ និងវិធីសាស្រ្តរបស់គេរៀងៗខ្លួន។

## ចំណោទបញ្ហានៃការស្រាវជ្រាវ

ទន្ទឹមនឹងប្រយោជន៍នៃក្បួនតម្រាទាក់ទងនឹងការរៀននិងបង្រៀនភាសាខ្មែរដែលបានចងក្រងឡើងនាពេលកន្លងមក នៅមានបញ្ហាមួយចំនួនដែលកំពុងកើតមានឡើង។ ការផ្តល់ពុទ្ធិខាងភាសាខ្មែរនៅមានកម្រិត និងនៅមិនទាន់មានលក្ខណៈឯកភាពគ្នា ស្របទៅតាមនិយាមគរុកោសល្យក្នុងការបង្រៀនភាសាខ្មែរបែបភាសាទី២ (Teaching Khmer as Second Language)។ រាល់ស្នាដៃដែលបានរៀបចំឡើងច្រើនស្ថិតនៅក្នុងបរិបទនៃភាពចាំបាច់មួយ ពោលគឺ ធ្វើឡើងដើម្បីដោះស្រាយបញ្ហាចំពោះមុខ ដោយមិនបានកសាងកម្មវិធីសិក្សាមួយសម្រាប់ជាទម្រមូលដ្ឋាន មុននឹងបង្កើតឯកសារបង្រៀនឬសៀវភៅគោលឡើយ។

ការសិក្សាស្រាវជ្រាវនេះ នឹងពិចារណាទៅលើចំណុចខាងលើដើម្បីបំពេញបន្ថែមចំណុចខ្វះខាត រកឯកភាពគ្នាទៅលើកម្មវិធីសិក្សា និងអាចជាទុនក្នុងការពង្រឹងគុណភាពការរៀននិងការបង្រៀនភាសាខ្មែរដល់ជនបរទេសប្រកបដោយប្រសិទ្ធភាពខ្ពស់ និងដើម្បីលើកគុណតម្លៃភាសានិងវប្បធម៌ខ្មែរលើឆាកអន្តរជាតិ។

## គោលបំណងនៃការស្រាវជ្រាវ

ការបង្កើតកម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេសនេះ ធ្វើឡើងដើម្បី៖

- ធ្វើឱ្យកម្មវិធីបង្រៀនភាសាខ្មែរមានវឌ្ឍនកម្ម ស្របទៅនឹងគោលការណ៍នៃការទទួលបានចំណេះដឹងភាសាដែលបានកំណត់ក្នុងក្របខណ្ឌកម្មវិធីសិក្សា។
- បង្កើតគំរូព័ត៌មានទូទៅនៃមុខវិជ្ជាដែលបម្រើដល់ការបណ្តុះបណ្តាលភាសា។

- ជាមូលដ្ឋានសម្រាប់យកទៅចងក្រងជាតម្រាឬឯកសារបង្រៀនទៅតាមមុខវិជ្ជានីមួយៗនាពេលអនាគត។

## ដែនកំណត់និងវិសាលភាពនៃការសិក្សាស្រាវ

គម្រោងស្រាវជ្រាវ នេះមានដែនកំណត់និងវិសាលភាព ដូចតទៅៈ

- បង្កើតកម្មវិធីបង្រៀនភាសាខ្មែរដល់ជនបរទេសដោយប្រើប្រាស់ភាសាខ្មែរបច្ចុប្បន្ន
- បង្កើតមុខវិជ្ជាថ្មី ដើម្បីបំពេញបន្ថែមលើមុខវិជ្ជាដែលមិនទាន់មានកន្លងមក
- ចងក្រងកម្មវិធីសិក្សាបីថ្នាក់ គឺ ថ្នាក់មូលដ្ឋាន ថ្នាក់ជំនាញ និងថ្នាក់បរិញ្ញាបត្រ

## វិធីសាស្ត្រនៃការស្រាវជ្រាវ

ទិន្នន័យទុតិយភូមិបានមកពីការប្រមូលឯកសារដែលពាក់ព័ន្ធនឹងទ្រឹស្តីនៃការរៀននិងបង្រៀនភាសា និងស្នាដៃទាក់ទងនឹងកម្មវិធីសិក្សាខ្មែរសម្រាប់ជនបរទេស ដែលបានរៀបចំចងក្រងដោយខ្មែរឬបរទេស។ ទិន្នន័យបឋមភូមិបានមកពីការចុះប្រមូលពីគ្រឹះស្ថានសិក្សា មជ្ឈមណ្ឌលនានាដែលបាននិងកំពុងបើកឱ្យមានដំណើរបង្រៀនភាសាខ្មែរសម្រាប់ជនបរទេស។

ទិន្នន័យដែលទាក់ទងនឹងទ្រឹស្តីនាំមកពិចារណាដើម្បីឈានទៅកំណត់គោលការណ៍ថ្មី ក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ ទិន្នន័យដែលប្រមូលបាននឹងនាំយកមករៀបចំ និងសិក្សាវិភាគមុខវិជ្ជាដែលមានកន្លងមក និងដើម្បីបង្កើតមុខវិជ្ជាថ្មីបន្ថែមដោយផ្អែកលើទ្រឹស្តីការទទួលចំណេះដឹងទី២ និងគោលការណ៍នានាដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡានៃប្រទេសកម្ពុជា។ ពិចារណានិងបែងចែកមុខវិជ្ជាទៅតាមកម្រិតសិក្សា។

## សម្មតិកម្មនិងលទ្ធផលរំពឹងទុក

លទ្ធផលនៃគម្រោងក្រោយបានបញ្ចប់ដោយជោគជ័យ កម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេសនេះ នឹងៈ

- អាចជាជំនួយក្នុងរៀបចំផែនការរៀននិងបង្រៀនភាសាខ្មែរដល់ជនបរទេសឱ្យកាន់តែមានប្រសិទ្ធិភាពប្រសើរឡើង ឆ្លើយតបនឹងតម្រូវការបណ្តុះបណ្តាលភាសាខ្មែរនាពេលបច្ចុប្បន្ន។
- ជួយគ្រឹះស្ថានសិក្សានានាដែលមានការរៀននិងបង្រៀនភាសាខ្មែរសម្រាប់ជនបរទេស ដើម្បីអាចនាំយកទៅអនុវត្តជាលំនាំគំរូបាន។
- ធ្វើឱ្យភាសាខ្មែរមានមាត្រដ្ឋានរួមមួយក្នុងការរៀននិងបង្រៀនដល់ជនបរទេស។

## ប្រវត្តិនៃការសិក្សាភាសាខ្មែរ

ការសិក្សាអំពីភាសាខ្មែរទទួលបានការចាប់អារម្មណ៍ពីសំណាក់ជនបរទេសជាយូរមកហើយ ពិសេសអ្នកសិក្សាស្រាវជ្រាវអំពីខ្មែរ។ ការរៀនភាសាខ្មែរទំនងជាចាប់ផ្តើមតាំងពីពេលដែលខ្មែរមានទំនាក់ទំនងជាមួយនឹងជនជាតិក្រៅស្រុក។ ទំនាក់ទំនងទាំងនោះបានធ្វើឡើងក្នុងគោលដៅផ្សេងៗគ្នា ដូចជា ជំនួញ ការផ្សព្វផ្សាយសាសនា ការទូត សិក្សាស្រាវជ្រាវ ជាដើម។ ដើម្បីប្រាស្រ័យទាក់ទងគ្នាបាន គេត្រូវចេះភាសាម្ចាស់ស្រុក ឬម្ចាស់ស្រុកត្រូវចេះភាសាអ្នកដែលចូលមក។

ឯកសារចិនដែលគេស្គាល់ច្រើនជាងគេ ហើយដែលមានសារៈសំខាន់យ៉ាងពិតប្រាកដ គឺស្នាដៃរបស់ជូតាក្វាន់(Zhou Daguan) ដែលបានមកកាន់ក្រុងអង្គរជាមួយអង្គទូតចិននៅចុងសតវត្សរ៍ទី១៣(នៅឆ្នាំ១២៩៦ - ១២៩៧) គឺក្នុងឱកាសដែលប្រទេសកម្ពុជានៅកំពុងពេញរុងរឿងនៅឡើយ។ ជនជាតិបស្ចិមប្រទេសបានមកដល់ប្រទេសកម្ពុជានៅសតវត្សរ៍ទី១៦។ ដំបូងគឺជនជាតិព័រទុយហ្គាល់ បន្ទាប់មកគឺជនជាតិអេស្ប៉ាញ ហើយក្រោយមកទៀត នៅសតវត្សរ៍ទី១៧ គឺជនជាតិហូឡង់ អង់គ្លេស ដាណឺម៉ាក និងបារាំង។[28] អ្នកដំណើរទាំងនោះដែលមកដល់ប្រទេសកម្ពុជា ភាគច្រើនជាបព្វជិតអ្នកផ្សព្វផ្សាយសាសនានកាតូលិក អ្នកជំនួញ ឬអ្នកចម្បាំង (ម៉ក់ ភឺន.១៩៩៦:៥៩, ៦០)។

ការទទួលបានចំណេះដឹងភាសាទី២[29](Second Language) អាចធ្វើឡើងតាមរយៈវិធីច្រើនយ៉ាង ដែលក្នុងនោះការរៀននិងការបង្រៀនជាវិធីដ៏មានប្រសិទ្ធភាពមួយ។ ចលនានៃការបង្រៀនភាសាខ្មែរសម័យបច្ចុប្បន្នដល់ជនបរទេស បានចាប់ផ្តើមឡើងជាច្រើនទសវត្សរ៍មកហើយ។ ការសិក្សាច្រើនធ្វើឡើងក្នុងលក្ខណៈជាការផ្តល់ចំណេះដឹងសម្រាប់ប្រើប្រាស់ក្នុងគ្រាបណ្តោះអាសន្ន ចំពោះជនជាតិបរទេសដែលមានបំណងមកប្រទេសកម្ពុជាក្នុងកិច្ចការជំនួញ ការទូត ឬមានបំណងសិក្សាស្រាវជ្រាវនៅប្រទេសកម្ពុជា។ ការរៀនផ្តោតទៅលើការពង្រីកបំណិនទំនាក់ទំនងក្នុងកិច្ចការប្រចាំថ្ងៃ។ ការបង្រៀនភាសាខ្មែរដល់ជនបរទេសក៏បានធ្វើឡើងនៅក្នុងប្រទេសនិងក្រៅប្រទេស។

ស្នាដៃជាច្រើនទាក់ទងនឹងភាសាខ្មែរបានចងក្រង និងបោះពុម្ពផ្សាយដោយអ្នកសិក្សាស្រាវជ្រាវបរទេស។[30] ស្នាដៃទាំងនោះមានលក្ខណៈជាការសិក្សាវិភាគនិងជាឯកសារសម្រាប់បង្រៀន។ លោកហ្សក ម៉ាស្ពេរ៉ូ (George Maspéro) បានសរសេរសៀវភៅវេយ្យាករណ៍ខ្មែរ (Grammair de la lanque khmère) និងបានបោះពុម្ពផ្សាយនៅឆ្នាំ១៩២១។ លោកបានអធិប្បាយលម្អិតអំពីលក្ខណៈ

---

[28] ឈ្មោះជនជាតិមួយចំនួននៅក្នុងឯកសារច្បាប់ដើម សរសេរជា ព័រទុយគេស, អេស្ប៉ាញ៉ុល, ហុល្លង់។ នៅទីនេះ យើងសូមអនុវត្តរូបសំណេរឈ្មោះជនជាតិទាំងនោះតាមគោលការណ៍កំណត់របស់ក្រុមប្រឹក្សាភាសាជាតិ(២០១៣)ទៅចុះ។ បើតាមវចនានុក្រមរបស់ពុទ្ធសាសនបណ្ឌិត្យ ពាក្យ អង់គ្លេស សរសេរជា អង្គ្លេស។

[29] ភាសាទី២(Second language, L2)

[30] យើងបានប្រមូលស្នាដៃមួយចំនួននោះដាក់ទៅក្នុងបញ្ជីឯកសារយោងនៃកម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេសនេះ ដើម្បីងាយស្រួលដល់អ្នកសិក្សាស្វែងរកឯកសារទាំងនោះ។

នានានៃភាសាខ្មែរ ដូចជា ប្រវត្តិភាសា សូរ ពាក្យ ការបង្កើតពាក្យ និងការប្រើប្រាស់ពាក្យ ជាដើម។ លោកហ្វ្រង់ស្វ័រ ម៉ាទីនី(François Martini) បានសិក្សាវិភាគអំពីភាសាខ្មែរដោយផ្អែកលើគោលទ្រឹស្តីភាសាវិទ្យា(យោងពី Jacob. 1993)។ លោកហ្គ័រហ្គោញីវ(Gorgoniyev. 1961) បាននិពន្ធសៀវភៅ The Khmer Language ដែលបានពិពណ៌នាអំពីមូលដ្ឋានភាសាខ្មែរ និងបំណែងចែកផ្នែកផ្សេងៗនៃភាសានេះតាមមូលដ្ឋានភាសាវិទ្យា។ លោកហាប់មែន (Huffman. 1967) បានសរសេរនិក្ខេបបទថ្នាក់បណ្ឌិតរបស់លោកស្តីអំពី វេយ្យាករណ៍ខ្មែរ "An Outline of Cambodian Grammar" និងក្រោយមកទៀតលោកបានសរសេរសៀវភៅមេរៀនភាសាខ្មែរ វចនានុក្រមខ្មែរ-អង់គ្លេស និងសៀវភៅជាច្រើនទៀតអំពីភាសានិងអក្សរសាស្ត្រខ្មែរ។ នៅឆ្នាំ១៩៦៨ អ្នកស្រីយ៉ាកូប (Jacob) បានបោះពុម្ពសៀវភៅ Introduction to Cambodian ដែលរៀបចំឡើងសម្រាប់ការរៀនភាសាខ្មែរ និងនៅឆ្នាំ១៩៩៣ លោកស្រីបានអធិប្បាយអំពីភាសានិងអក្សរសិល្ប៍ខ្មែរតាមរយៈសៀវភៅ Cambodian Linguistics, Literature and History។ នៅឆ្នាំ១៩៧២ លោក Kheang និង លោក Purtle បានសហការគ្នាចងក្រងឯកសារបង្រៀនជាច្រើនក្បាល ដែលជាគម្រោងផលិតឯកសារបង្រៀននៅសាកលវិទ្យាល័យអាម៉េរិក "American University"។

ក្រៅពីស្នាដៃដែលបានលើកឡើងខាងលើ នៅមានស្នាដៃសិក្សាស្រាវជ្រាវអំពីភាសានិងអក្សរសាស្ត្រខ្មែរជាច្រើនទៀតដែលបានធ្វើឡើងដោយអ្នកស្រាវជ្រាវបរទេស។ ទាំងអស់នេះចាត់ទុកជាតឹកតាងដែលអាចបញ្ជាក់ថា មានអ្នកសិក្សាបរទេសជាច្រើនបានចាប់អារម្មណ៍នឹងភាសាខ្មែរ ហើយព្យាយាមសិក្សាស្រាវជ្រាវរហូតទទួលបានចំណេះវិជ្ជាជ្រៅជ្រះនិងចងក្រងជាស្នាដៃទាំងនេះឡើង។

## ការរៀននិងបង្រៀនភាសាខ្មែរ

ដោយសារតម្រូវការចាំបាច់ ក្នុងទំនាក់ទំនងទៅលើវិស័យផ្សេងៗ ជាមួយប្រទេសកម្ពុជា ប្រទេសមួយចំនួនបានបញ្ចូលកម្មវិធីសិក្សាភាសាខ្មែរទៅក្នុងកម្មវិធីសិក្សាភាសាបរទេសរបស់គេ។ អ្នករៀបចំកម្មវិធីច្រើនជាអ្នកជំនាញភាសា ដែលយល់ដឹងអំពីខ្មែរ ដែលជួនកាលគេក៏បានសហការជាមួយខ្មែរដែលអ្នកម្ចាស់ភាសាផងដែរ។

ក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំថៃ មានបញ្ចូលមុខវិជ្ជាភាសាខ្មែរទៅក្នុងកម្មវិធីសិក្សាតាំងពីសាលារៀនចំណេះទូទៅរហូតថ្នាក់ឧត្តមសិក្សា(The Ministry of Education Thailand. 2008 : 252)។ នៅព្រះរាជាណាចក្រថៃ មានសាកលវិទ្យាល័យមួយចំនួនបានបើកឱ្យដំណើរការបង្រៀនភាសាខ្មែរនេះដែរ ប៉ុន្តែមានគ្រឹះស្ថានសិក្សាតិចតួចទេដែលបណ្តុះបណ្តាលក្នុងកម្រិតឯកទេសអក្សរសាស្ត្រខ្មែរ ដូចជាសាកលវិទ្យាល័យមហាសារខាម សាកលវិទ្យាល័យសិល្បាករ សាកលវិទ្យាល័យស្រីនគរិន្ទ្រ។ ក្រៅពីនោះ មុខវិជ្ជាភាសាខ្មែរស្ថិតក្នុងក្រុមមុខវិជ្ជាជ្រើសរើស ឬនិស្សិតចុះឈ្មោះចូលរៀនដើម្បីបំពេញក្រេឌីតនៃកម្មវិធីសិក្សាណាមួយតែប៉ុណ្ណោះ។ នៅសហរដ្ឋអាម៉េរិក ក៏មានបើកបង្រៀនភាសាខ្មែរយ៉ាងផុសផុលដែរ ពិសេសនៅរដ្ឋហាវ៉ៃ។

នៅក្នុងប្រទេស ការបង្រៀនភាសាខ្មែរដល់ជនបរទេសក៏មានសន្ទុះគួរឱ្យកត់សម្គាល់ដែរ។ វិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានរៀបចំកម្មវិធីបង្រៀនភាសាខ្មែរសម្រាប់ជនបរទេស តាមមតិណែនាំរបស់រដ្ឋមន្ត្រីក្រសួងអប់រំ តាំងពីឆ្នាំ១៩៨៣មកម្ល៉េះ(គេហទំព័រ RUPP. 2017)។ គោលដៅដំបូងនៃកម្មវិធីរៀបចំឡើង ដើម្បីបណ្តុះបណ្តាលនិស្សិតបរទេសដែលបានសិក្សានៅប្រទេសកម្ពុជាតាមរយៈកិច្ចព្រមព្រៀងផ្លាស់ប្តូរទៅវិញទៅមក។ ចាប់តាំងពីពេលនោះមក វគ្គសិក្សានេះបានផ្លាស់ប្តូរដោយការផ្តោតអារម្មណ៍របស់ខ្លួនឆ្ពោះទៅរកការបណ្តុះបណ្តាលជនបរទេសដែលមកធ្វើការនៅប្រទេសកម្ពុជា ជាពិសេសសម្រាប់អង្គការមិនមែនរដ្ឋាភិបាលនិងអ្នកដែលមានបំណងចង់រៀនភាសាខ្មែរ។ ការសិក្សានេះមានលក្ខណៈជាការសិក្សាមិនគិតក្រេឌីត (Non-credit) និងបានកំណត់កម្រិតនៃការសិក្សាជាបួនកម្រិត។

មហាវិទ្យាល័យសិល្បសាស្ត្រនិងមនុស្សសាស្ត្រ(Collect of Arts and Humanities) នៃសាកលវិទ្យាល័យកម្ពុជាមានកម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេស(Khmer for Non-Cambodians)។ កម្មវិធីនេះផ្តល់ឱកាសដល់និស្សិត កម្មករ អ្នកស្រាវជ្រាវបរទេសប៉ុណ្ណោះ។ មានមុខវិជ្ជាចំនួន២០ដាក់ឱ្យនិស្សិតចុះឈ្មោះចូលរៀន ដែលមុខវិជ្ជានីមួយៗមាន៣ក្រេឌីត។ មុខវិជ្ជាទាំងនោះទាក់ទងនឹងភាសា វប្បធម៌ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអក្សរសិល្ប៍ខ្មែរ។ ការបណ្តុះបណ្តាលមានពីរកម្រិតបរិញ្ញាបត្ររងនិងកម្រិតបរិញ្ញាបត្រ (University of Cambodia. 2007)។

កម្មវិធីភាសាខ្មែរដែលរៀបចំដោយសាកលវិទ្យាល័យកម្ពុជាខាងលើ អាចចាត់ទុកថាជាជំហានថ្មីមួយក្នុងការបណ្តុះបណ្តាលភាសាខ្មែរដល់ជនបរទេស ព្រោះកម្មវិធីបានរៀបចំឱ្យមានមុខវិជ្ជាច្រើនមុខ ក្នុងការផ្តល់ពុទ្ធិដល់អ្នកសិក្សាសមស្របទៅនឹងរបត់នៃការរៀននិងការបង្រៀនក្នុងយុគសម័យថ្មី។ ទោះយ៉ាងណាក្តី មុខវិជ្ជាមួយចំនួនទៀតគួរត្រូវបន្ថែម ដើម្បីបំពេញទៅនឹងគោលការណ៍នៃក្របខណ្ឌកម្មវិធីសិក្សាថ្មី។

## មូលដ្ឋានទ្រឹស្តីក្នុងការបង្កើតកម្មវិធីសិក្សា

កម្មវិធីសិក្សាភាសាដែលល្អអាចនាំយកទៅអនុវត្តជាក់ស្តែងក្នុងការរៀននិងបង្រៀនឱ្យកើតប្រយោជន៍ ផ្តល់ពុទ្ធិ និងសមត្ថភាពខាងផ្នែកភាសាដល់អ្នកសិក្សាបានប្រសើរ។ កម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេសនាពេលនេះបានបង្កើតឡើងដោយឈរលើមូលដ្ឋានទ្រឹស្តី និងផ្អែកលើគោលការណ៍នៃក្របខណ្ឌកម្មវិធីសិក្សារបស់ក្រសួងអប់រំ។

ការទទួលបានចំណេះដឹងភាសាទី២(L2) មិនដូចគ្នាទៅនឹងការទទួលបានចំណេះវិជ្ជានៃភាសាកំណើត(L1)ទេ។ ម្ចាស់ភាសាទទួលចំណេះភាសារបស់ខ្លួនឡើង ដោយមិនដឹងខ្លួន តាមរយៈការប្រើប្រាស់ភាសាពីអ្នកដែលនៅជុំវិញខ្លួនតាំងពីនៅភាពជាទារកហូតពេញវ័យ។ ទិន្នន័យភាសា មានទាំងសូរ សំនៀង ការប្រើប្រាស់ពាក្យ ល្បះជាដើម បានប្រមូលរក្សាទុកក្នុងខួរក្បាលរបស់ម្ចាស់ភាសាជា

ស្វ័យប្រវត្តិ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវបានរកឃើញថា មិនមានម្ចាស់ភាសាណាដែលរៀន(មូលដ្ឋាន)វេយ្យាករណ៍របស់ភាសាកំណើតខ្លួនដើម្បីនាំយកទៅប្រើប្រាស់ក្នុងទំនាក់ទំនងប្រចាំថ្ងៃទេ។ ផ្ទុយទៅវិញ ការទទួលបានចំណេះដឹងភាសាទី២កើតឡើងដោយការតាំងចិត្ត តាមរយៈការរៀន។ អ្នកសិក្សាត្រូវមានសេចក្ដីព្យាយាម រៀនតាំងពីវេយ្យាករណ៍ ការបន្លឺសូរ ការប្រើពាក្យនៅក្នុងសម្ពន្ធ ការបង្កើតឃ្លាល្បះ និងខិតខំហ្វឹកហាត់ឱ្យបានខ្ជាប់ខ្ជួន(Saville-Troike. 2006)។ ការរស់នៅឡូកឡំក្នុងសង្គមដែលប្រើភាសាទី២ អាចជួយឱ្យអ្នកសិក្សាបានទទួលចំណេះដឹងភាសាទី២កាន់តែលឿន។

លោកប្លូម(Bloom) ផ្អែកលើទស្សនៈដែលថា អ្នកសិក្សាត្រូវតែចាប់ផ្ដើមដោយការដឹងអំពីចំណេះដឹងជាមូលដ្ឋាន ដែលបានផ្ដល់មុនពេលពួកគេឈានទៅដល់ការគិតស៊ីជម្រៅ ដែលប្រកបដោយភាពស្មុគស្មាញសាំញ៉ាំ ដូចជាការវិភាគ និងការវាយតម្លៃជាដើម។ ក្របខណ្ឌរបស់ Bloom មានទម្រង់ជាសាជីជ្រុងដូចដំណាក់កាលទទួលចំណេះដឹងរបស់ Maslow ដែរ។ ក្របខណ្ឌនេះចេញដំណើរពីកម្រិតទាប ងាយ ទៅកម្រិតខ្ពស់សាំញ៉ាំ ដែលកម្រិតនីមួយៗជាដំណាក់កាលដូចការឡើងកាំជណ្ដើរ។ មុននឹងឈានពីកម្រិតមួយទៅកម្រិតបន្ទាប់ ចំណេះដឹងត្រូវបានទទួលការហ្វឹកហាត់សារចុះសារឡើងរហូតក្លាយជាទម្លាប់ និងស្ទាត់ជំនាញ។




តារាងវិភាគកម្រិតយល់ដឹងតាមលោកប្លូម
(បណ្ដាញសាកលវិទ្យាល័យអាស៊ាន. ២០១៦ : ១៨)

កម្រិតទី១ ការចងចាំ៖ អ្នកសិក្សានឹងចេះធ្វើការរៀបចំ ស្គាល់ និងទន្ទេញចងចាំមេរៀនបានយ៉ាងស្ទាត់។ ឧទាហរណ៍៖ ក្រោយចប់មេរៀននេះ សិស្សនឹងអាចសូត្រស្ទាត់នូវច្បាប់ចលនាទាំង៣របស់ញូតុន។

កម្រិតទី២ ការយល់៖ អ្នកសិក្សានឹងចេះពន្យល់ ពិពណ៌នា និយាយឡើងវិញ សង្ខេប ប្រៀបធៀបមេរៀន។ ឧទាហរណ៍៖ ក្រោយចប់មេរៀននេះ សិស្សនឹងអាចពិពណ៌នានូវច្បាប់ចលនាទាំង៣របស់ញូតុនដោយប្រើប្រាស់ពាក្យពេចន៍របស់ខ្លួន។

កម្រិតទី៣ អនុវត្តន៍៖ អ្នកសិក្សានឹងចេះគណនា ព្យាករណ៍ ដោះស្រាយ ប្រើប្រាស់ និងអនុវត្តទ្រឹស្តីនៃមេរៀន។ ឧទាហរណ៍៖ ក្រោយចប់មេរៀននេះ សិស្សនឹងចេះគណនាថាមពលស៊ីនេទិចនៃចលនាគ្រាប់បាញ់។

កម្រិតទី៤ វិភាគ៖ អ្នកសិក្សានឹងអាចចេះចាត់ថ្នាក់ បែងចែកជាផ្នែកៗ ឬជាប្រភេទៗ វិភាគ គូសដ្យាក្រាម ផ្តល់មតិផ្សេងៗលើមេរៀន។ ឧទាហរណ៍៖ ក្រោយចប់មេរៀននេះ សិស្សនឹងចេះបែងចែកពីភាពខុសគ្នារវាងថាមពលប៉ូតុងស្យែល និងថាមពលស៊ីនេទិច។

កម្រិតទី៥ វាយតម្លៃ៖ អ្នកសិក្សានឹងចេះជ្រើសរើសជម្រើសត្រឹមត្រូវ គាំទ្រ កំណត់ភាពត្រឹមត្រូវ ប្រៀបធៀប លើកមតិប្រឆាំង បញ្ចុះបញ្ចូល ផ្តល់ហេតុផលទៅលើអ្វីដែលខ្លួនបានគិតក្នុងលំហាត់ ឬមេរៀន។
ឧទាហរណ៍៖ ក្រោយចប់មេរៀននេះ សិស្សនឹងចេះកំណត់ថា តើគួរប្រើប្រាស់រូបមន្តណាមួយ ដើម្បីដោះស្រាយលំហាត់មេរៀនរលកស៊ីនុយសូអ៊ីត។

កម្រិតទី៦ បង្កើត៖ អ្នកសិក្សានឹងចេះ កែច្នៃ បង្កើត បង្កើតថ្មី អភិវឌ្ឍន៍ឱ្យកាន់តែខ្លាំងនូវមេរៀនទ្រឹស្តីដែលខ្លួនបានរៀន។ ឧទាហរណ៍៖ ក្រោយចប់មេរៀននេះ សិស្សនឹងចេះបង្កើតលំហាត់មេកានិកដោយខ្លួនឯង។ ( Bloom's Taxonomy )

## គោលការណ៍មូលដ្ឋាន

ជាតុគោលរបស់គុណវុឌ្ឍិ ដែលកំណត់នៅក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា[31]( ក.គ.ជ.ក ) របស់រាជរដ្ឋាភិបាលកម្ពុជា( ២០១៤ ) មាន៤គឺ៖ កម្រិត ក្រេឌីត លទ្ធផលសិក្សា និងច្រកសិក្សា។

ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាបានកំណត់ថា កម្រិត ជាលេខលំដាប់ដែលភ្ជាប់ទៅនឹងឈ្មោះគុណវុឌ្ឍិ ដើម្បីរៀបរាប់ពីតម្រូវការនៃបញ្ញាដែលកើនឡើងនិងភាពស្មុគស្មាញនៃលទ្ធផលសិក្សានៅក្នុងគុណវុឌ្ឍិនីមួយៗ។

គ្រប់ការសិក្សាទាំងអស់ចាំបាច់មានរយៈពេលកំណត់ ដែលអាចជាខ្នាតរង្វាស់កម្រិតពុទ្ធិដែលទទួលបាន។ គេចែកកម្មវិធីសិក្សាជាពីរប្រព័ន្ធធំៗ គឺ ប្រព័ន្ធម៉ោង និង ប្រព័ន្ធក្រេឌីត។ នៅក្នុងកម្មវិធីតាម

[31] ដើម្បីរក្សារូបសំណេរតាមវចនានុក្រមពុទ្ធសាសបណ្ឌិត្យ យើងកំណត់សរសេរពាក្យ ខណ្ឌ ខុសពីក្នុងច្បាប់ដើមដែលសរសេរជា ខ័ណ្ឌ។

ប្រព័ន្ធក្រេឌីត មុខវិជ្ជាណាដែលសិក្សាក្នុងថ្នាក់មួយម៉ោងក្នុងមួយសប្ដាហ៍រយៈពេល១៤ទៅ១៥សប្ដាហ៍ ពេលប្រឡងជាប់ គេនិយាយថា និស្សិតទទួលបានមួយក្រេឌីត។

**ក្រេឌីត** ជាឯកតាឬតម្លៃដែលយកជាខ្នាតសម្រាប់វាស់វែងនិងពិពណ៌នាពីទំហំការងារឬបរិមាណនៃការសិក្សាដែលរំពឹងទុកសម្រាប់កម្រិតនីមួយៗឬសម្រាប់មុខវិជ្ជាសិក្សា ឯកតាសិក្សា ឬសមាសភាគដទៃទៀតនៃកម្មវិធីអប់រំនិងបណ្ដុះបណ្ដាល(រាជរដ្ឋាភិបាលកម្ពុជា. ២០១៤)។

រូបមន្តក្រេឌីត អាស្រ័យទៅតាមប្រព័ន្ធចំនួន នៅក្នុងការសិក្សាពេញម៉ោងរបស់និស្សិត គឺ ពី១២ទៅ២១ក្រេឌីតក្នុងមួយឆមាសនិងចំនួនក្រេឌីតអប្បបរមា១២០ក្រេឌីតក្នុងកម្រិតគុណវុឌ្ឍិសិក្សារយៈពេល៤ឆ្នាំ។ រូបមន្តក្រេឌីតត្រូវបានប្រើជាមុខងារសម្រាប់វាយតម្លៃចំនួននៃការសិក្សាដែលសម្រេចបាន។ ប្រសិនបើកម្មវិធីអប់រំមានចំនួនម៉ោងសិក្សាច្រើនអាចធ្វើឱ្យចំនួនក្រេឌីតខ្ពស់ តែមិនប្រាកដជាភស្តុតាងបង្ហាញថា លទ្ធផលការសិក្សាដែលបានរំពឹងទុកអាចទទួលបានទាំងស្រុងនោះទេ(រាជរដ្ឋាភិបាលកម្ពុជា. ២០១៤ : ៥៧)។

ជាគោលការណ៍ ការកំណត់ចំនួនក្រេឌីតក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា គឺ ១៥ម៉ោងស្មើនឹង១ក្រេឌីតសម្រាប់ការបង្រៀនក្នុងកម្រិតធម្មតា ៣០ម៉ោងស្មើនឹង១ក្រេឌីតសម្រាប់ការសិក្សាប្រតិបត្តិ និងចំនួន៤៥ម៉ោងស្មើនឹង១ក្រេឌីតសម្រាប់ការអនុវត្តជាក់ស្ដែង។ ចំពោះនិស្សិតសិក្សាពេញម៉ោងនៅកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រក្នុងរយៈពេល១ឆមាស ត្រូវសិក្សាយ៉ាងតិចចំនួន១៥ក្រេឌីតនិងយ៉ាងតិចចំនួន៣០ក្រេឌីតក្នុងរយៈពេលមួយឆ្នាំសិក្សា (រាជរដ្ឋាភិបាលកម្ពុជា. ២០១៤)។

ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា(រាជរដ្ឋាភិបាលកម្ពុជា. ២០១៤)បានកំណត់ថា **លទ្ធផលសិក្សា** ជាសេចក្ដីថ្លែងនូវអ្វីដែលអ្នកសិក្សាចេះ យល់ និងអាចធ្វើបាន ក្រោយបញ្ចប់ការសិក្សា តាមរយៈលក្ខណវិនិច្ឆ័យស្នាដៃការងារផ្អែកលើចំណេះដឹង ជំនាញ អាកប្បកិរិយា និងសមត្ថភាព។

**ច្រកសិក្សា** គឺច្រកអាចបត់បែនបានដែលបង្កភាពងាយស្រួលដល់អ្នកសិក្សាក្នុងការផ្លាស់ប្ដូររវាងវិស័យអប់រំឧត្តមសិក្សា និងវិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការបន្តការសិក្សាកម្រិតគុណវុឌ្ឍិខ្ពស់បន្ថែមទៀត តាមរយៈការទទួលស្គាល់ការសិក្សាដែលមានពីមុន រួមមានការផ្ទេរក្រេឌីតនិងការទទួលស្គាល់លើបទពិសោធន៍និងសមត្ថភាពបច្ចុប្បន្ន (រាជរដ្ឋាភិបាលកម្ពុជា. ២០១៤ : ២)។

## គោលការណ៍រួមនៃកម្មវិធីសិក្សា

មុខវិជ្ជាសម្រាប់បម្រើឱ្យការបណ្ដុះបណ្ដាលភាសាខ្មែរមិនបានកំណត់តែមុខវិជ្ជាដែលមានតែភាសាមួយមុខប៉ុណ្ណោះទេ។ ការសិក្សាចាំបាច់ត្រូវមានមុខវិជ្ជាពាក់ព័ន្ធឯទៀតដែលនឹងធ្វើឱ្យលទ្ធផលនៃចំណេះដែលទទួលបានមានប្រសិទ្ធភាពខ្ពស់ក្នុងទំនាក់ទំនង។

ក្របខណ្ឌកម្មវិធីសិក្សាចំណេះដឹងទូទៅ និងអប់រំបច្ចេកទេស(ក្រសួងអប់រំ. ២០១៥ខ : ៦)បានកំណត់គោលបំណងនៃការសិក្សាមុខវិជ្ជាភាសាខ្មែរ ដូចតទៅ៖

- ទទួលបានចំណេះដឹងបំណិនភាសានិងអក្សរសាស្ត្រខ្មែររឹងមាំ

- មានសមត្ថភាពពិណ៌នា វិភាគ វិនិច្ឆ័យ ពន្យល់ បកស្រាយបានត្រឹមត្រូវ និងសមហេតុផល
- អនុវត្តចំណេះដឹង បំណិនភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរក្នុងការសិក្សាមុខវិជ្ជាដទៃទៀតនិងការរស់នៅប្រចាំថ្ងៃ
- ស្គាល់និងលើកកម្ពស់តម្លៃមុខវិជ្ជាភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ និងមោទនភាពក្នុងការប្រើប្រាស់ភាសាខ្មែរនិងអក្សរសាស្ត្រខ្មែរ។

ស្របតាមកម្រិតសិក្សានីមួយៗ តាមរយៈការកំណត់ក្រេឌីតដែលបានលើកមកបង្ហាញខាងលើ កម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេសនេះ កំណត់ក្រេឌីតដូចខាងក្រោម៖

- កម្រិតមូលដ្ឋានតម្រូវឱ្យអ្នកសិក្សារៀនយ៉ាងតិច ៣០ ក្រេឌីត
- កម្រិតជំនាញតម្រូវឱ្យរៀនយ៉ាងតិច៨ក្រេឌីតក្នុងមួយជំនាញ និង
- កម្រិតបរិញ្ញាបត្រត្រូវរៀនយ៉ាងតិច១៣០ក្រេឌីត។

**លទ្ធផលនៃការស្រាវជ្រាវ**

ក្រោយពីបានពិចារណាទៅលើទិន្នន័យទាក់ទងនឹងការរៀននិងបង្រៀនភាសាខ្មែរសម្រាប់ជនបរទេសកន្លងមក និងក្រោយពីបានសិក្សាអំពីទ្រឹស្តីនិងគោលការណ៍កម្មវិធីសិក្សា ខាងក្រោមនេះជាលទ្ធផលនៃកម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេស។

ដើម្បីឆ្លើយតបនឹងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេសកំណត់ប្រភេទជាពីរ គឺ មុខវិជ្ជាឯកទេស និងមុខវិជ្ជាចំណេះទូទៅ ហើយប្រភេទមុខវិជ្ជានីមួយៗចែកចេញជា មុខវិជ្ជាចាំបាច់ និងមុខវិជ្ជាជ្រើសរើស។ នៅក្នុងមុខវិជ្ជាឯកទេសមាន មុខវិជ្ជាភាសា និងមុខវិជ្ជាអក្សរសិល្ប៍ ចំណែកនៅក្នុងមុខវិជ្ជាចំណេះទូទៅមាន មុខវិជ្ជាចម្រុះដែលពាក់ព័ន្ធ។

មុខវិជ្ជាដែលក្រុមការងារស្រាវជ្រាវយើងបានពិចារណាឃើញថានឹងបម្រើដល់ការសិក្សាភាសាខ្មែរសម្រាប់ជនបរទេសនៅក្នុងកម្មវិធីនេះរួមមានមុខវិជ្ជាសរុបចំនួន១០២មុខវិជ្ជា។ ក្នុងនោះ មានមុខវិជ្ជាទាក់ទងនឹងភាសាចំនួន៦០ មុខវិជ្ជាទាក់ទងនឹងអក្សរសិល្ប៍២០ ទាក់ទងនឹងចំណេះទូទៅ២០ និងមុខវិជ្ជាសហកិច្ចសិក្សាមានចំនួន២។

## ១- ការកំណត់កូដមុខវិជ្ជា

នៅក្នុងមុខវិជ្ជានីមួយៗមាន កូដមុខវិជ្ជា ឈ្មោះមុខវិជ្ជា ចំនួនក្រេឌីត និងការពិពណ៌នាមុខវិជ្ជា។

ឧទាហរណ៍៖

| កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| KH 114 | ភាសាខ្មែរក្នុងជីវភាពប្រចាំថ្ងៃ<br>Khmer in Everyday Life | 3(3-0-6) |

មុខវិជ្ជានេះត្រូវបានរៀបចំឡើង ដើម្បីជួយអ្នកសិក្សាយល់និងអនុវត្តជំនាញភាសាខ្មែររបស់ខ្លួន កសាងបំណិននៃការស្តាប់ ការនិយាយ ការអាន និងការសរសេរ។ មានការផ្លាស់ប្តូរសកម្មភាពគ្នារវាងអ្នកសិក្សាដែលនឹងជួយពួកគេពង្រីកចំណេះដឹងខាងប្រាស្រ័យទាក់ទង ប្រកបដោយប្រសិទ្ធភាពនិងអាចវាស់ស្ទង់ការយល់ដឹងរបស់ពួកគេ តាមរយៈការអនុវត្តជាក់ស្តែងលើការស្តាប់និងចេះដោះស្រាយជាមួយបញ្ហាក្នុងស្ថានភាពផ្សេងៗនៅក្នុងការទំនាក់ទំនងជីវិតប្រចាំថ្ងៃ។
រយៈពេល៖ (រៀនក្នុងថ្នាក់ ៣ ម៉ោង, អនុវត្ត ០ ម៉ោង, រៀនខ្លួនឯង ៦ ម៉ោង)

មុខវិជ្ជារៀនមុន៖

មុខវិជ្ជារៀនដំណាលគ្នា៖ គ្មាន

This course is designed to help the students understand and practice his/her Khmer skills. The course aims to enable students to develop essential listening, speaking and writing. In addition, interchange activities will help students communicate effectively and test their understanding through extra listening practice and deal with various situations in daily life communication. (Lecture 3 hours, Practice 0 hours, Self-study 6 hours)

Prerequisite:

Co-requisite: NA

## ១.១- កូដមុខវិជ្ជា

កូដមុខវិជ្ជានីមួយៗ ផ្តើមឡើងដោយអក្សរកាត់ និងមានលេខបីខ្ទង់នៅបន្ទាប់ ដែលមានទម្រង់ជា KH xxx មានន័យថា៖

- KH Khmer
- xxx លេខបីខ្ទង់ សរសេរជាលេខអារ៉ាប់

លេខខ្ទង់ទី១(ខ្ទង់រយ) ជាលេខសម្គាល់ក្រុមមុខវិជ្ជា ដូចជា៖

1 ជាលេខសម្គាល់មុខវិជ្ជាភាសា

2 ជាលេខសម្គាល់មុខវិជ្ជាអក្សរសិល្ប៍

3 ជាលេខសម្គាល់មុខវិជ្ជាវប្បធម៌/ចំណេះដឹងទូទៅ

លេខខ្ទង់ទី២(ខ្ទង់ដប់) និងទី៣(ខ្ទង់រាយ) ជាលេខលំដាប់មុខវិជ្ជានៃក្រុមមុខវិជ្ជានីមួយៗ។

ឧទាហរណ៍៖

| លេខកូដ | ឈ្មោះមុខវិជ្ជា | លំដាប់មុខវិជ្ជាក្នុងក្រុម |
|---|---|---|
| KH 118 | ក្រុមមុខវិជ្ជាភាសា | លំដាប់ទី 18 |
| KH 213 | ក្រុមមុខវិជ្ជាអក្សរសិល្ប៍ | លំដាប់ទី 13 |
| KH 318 | ក្រុមមុខវិជ្ជាចំណេះទូទៅ | លំដាប់ទី 18 |

## ១.២- ឈ្មោះមុខវិជ្ជា

ឈ្មោះមុខវិជ្ជានីមួយៗសរសេរជាភាសាខ្មែរនៅបន្ទាត់ខាងលើ និងសរសេរជាភាសាអង់គ្លេសបន្ទាត់ខាងក្រោម នៅជួរឈរកណ្ដាលនៃតារាងមុខវិជ្ជា។

ឧទាហរណ៍៖

| កូដមុខវិជ្ជា | ឈ្មោះមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| KH 118 | ភាសាខ្មែរសម្រាប់ទំនាក់ទំនង<br>Khmer for Communication | 3(3-0-6) |

## ១.៣- ក្រេឌីត

ចំនួនក្រេឌីតនៃមុខវិជ្ជានីមួយៗសរសេរជាលេខអារ៉ាប់ មានលំនាំ 3(3-0-6) និងមានន័យដូចតទៅ៖

| | |
|---|---|
| 3 លេខនៅក្រៅវង់ក្រចកសម្គាល់ | ចំនួនក្រេឌីត |
| 3 លេខនៅក្នុងវង់ក្រចកសម្គាល់ | ម៉ោងទ្រឹស្ដី(ម៉ោងក្នុងថ្នាក់) |
| 0 លេខនៅក្នុងវង់ក្រចកសម្គាល់ | ម៉ោងអនុវត្ត (ពិសោធ) |
| 6 លេខនៅក្នុងក្រចកសម្គាល់ | ម៉ោងប្រតិបត្តិ (សិក្សាខ្លួនឯង) |

## ១.៤- ការពណ៌នាមុខវិជ្ជា

ផ្នែកនេះនឹងជួយដល់គ្រូឧទ្ទេសនិងអ្នកសិក្សាឱ្យបានដឹងដោយសង្ខេបអំពីចំណេះដឹងដែលត្រូវផ្ដល់និងទទួលក្រោយបញ្ចប់ការសិក្សាក្នុងមុខវិជ្ជានីមួយៗ។ ការអធិប្បាយនេះប្រៀបបាននឹងផែនទីសម្រាប់គ្រូឧទ្ទេសនាំទៅរៀបចំមេរៀនឱ្យបានចំវត្ថុបំណងដែលរៀបចំទុក។

## ២- ចំណែងចែកវគ្គសិក្សា

មុខវិជ្ជាដែលបានរៀបចំឡើងខាងលើ ត្រូវបានដាក់ទៅតាមប្រភេទផ្សេងៗនៃឯកទេសភាសា។

យើងមិនបានរៀបចំទៅតាមលំដាប់លំដោយនៃកម្រិតសិក្សាទេ។ អ្នករៀបចំកម្មវិធីអាចជ្រើសរើសមុខវិជ្ជាណាមួយដែលសមស្របដើម្បីបញ្ចូលទៅក្នុងដំណើរការបណ្ដុះបណ្ដាលភាសាខ្មែរទៅតាមតម្រូវការជាក់ស្ដែង។ ទោះជាយ៉ាងណាក្ដី ដើម្បីជាលំនាំនៃការរៀបចំកម្មវិធីសិក្សា នៅក្នុងកម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេសរបស់គម្រោងស្រាវជ្រាវនេះបានបែងកម្រិតឬថ្នាក់សិក្សាជាបី គឺ ភាសាខ្មែរថ្នាក់មូលដ្ឋាន ភាសាខ្មែរថ្នាក់ជំនាញ និងភាសាខ្មែរថ្នាក់បរិញ្ញាបត្រ។

ភាសាខ្មែរថ្នាក់មូលដ្ឋាន ការសិក្សាបែងចែកជាបួនកម្រិត គឺៈ

១- ភាសាខ្មែរកម្រិតដំបូង

២- ភាសាខ្មែរកម្រិតទាប

៣- ភាសាខ្មែរកម្រិតមធ្យម និង

៤- ភាសាខ្មែរកម្រិតខ្ពស់

ក្នុងកម្រិតនីមួយៗ អ្នកសិក្សាតម្រូវឱ្យចុះឈ្មោះរៀនយ៉ាងតិច៨ក្រេឌីត។ ក្នុងនោះ មុខវិជ្ជាឯកទេសយ៉ាងតិច៦ក្រេឌីត និង/ឬមុខវិជ្ជាចំណេះទូទៅយ៉ាងតិច២ក្រេឌីត។

ភាសាខ្មែរថ្នាក់ជំនាញផ្ដោតទៅលើជំនាញចំនួន៤ គឺៈ

១- ភាសាខ្មែរសម្រាប់ទេសចរណ៍

២- ភាសាខ្មែរសម្រាប់កិច្ចការរដ្ឋបាល

៣- ភាសាខ្មែរសម្រាប់ជំនួញ/អាជីវកម្ម និង

៤- ភាសាខ្មែរសម្រាប់ការសិក្សាអប់រំ។

ក្នុងមួយជំនាញ អ្នកសិក្សាត្រូវរៀនយ៉ាងតិច៨ក្រេឌីត។

ចំណែកភាសាខ្មែរថ្នាក់បរិញ្ញាបត្រ អ្នកសិក្សាត្រូវប្រើពេលសិក្សាមិនទាបជាង០៤ឆ្នាំ ស្មើនឹង ១២០ ឬ ១៦៥ ក្រេឌីត។

## សេចក្ដីសន្និដ្ឋាន

តាមរយៈការលើកឡើងគ្រួសៗ អំពីប្រវត្តិនៃដំណើរការបង្រៀនភាសាខ្មែរដល់ជនបរទេសខាងលើ បង្ហាញឱ្យឃើញថា ការរៀននិងការបង្រៀនច្រើនធ្វើឡើងដោយចេញដំណើរពីការរៀនរយៈពេលខ្លីដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ភាសាក្នុងទំនាក់ទំនង ក្នុងជីវភាពប្រចាំថ្ងៃនិងក្នុងទំនាក់ទំនងចំពោះមុខនានា និងក្រោយមកទៀត ការបង្រៀនបានពង្រីកខ្លួនរហូតដល់កម្រិតឧត្ដមសិក្សា។ ដំណើរការរៀននិងបង្រៀនភាសាខ្មែរនៅជំហានដំបូងច្រើនធ្វើឡើងដោយមិនមានការរៀបចំកម្មវិធីសិក្សាសម្រាប់ ជាផែនការសិក្សាអប់រំជាមុនទេ និងផលិតសៀវភៅសិក្សាគោល( textbook )ជាមុន។

ក្រោយការពិចារណាទាំងទៅលើទ្រឹស្ដីក្ដី ទាំងគោលការណ៍គុណវុឌ្ឍិដែលបានរៀបចំឡើងដោយក្រសួងអប់រំនៃព្រះរាជាណាចក្រកម្ពុជា ទម្រង់នៃកម្មវិធីភាសាខ្មែរសម្រាប់ជនបរទេសបានរៀបចំ

ឡើងដោយការប្រាប់បញ្ចូលគ្នារវាងកិច្ចការដែលបានធ្វើកន្លងមករបស់គ្រឹះស្ថានសិក្សាឬមជ្ឈមណ្ឌលបណ្ដុះបណ្ដាលភាសាខ្មែរ។

យើងបានសម្រួលផ្នែកមួយចំនួននៃកម្មវិធី ដូចជាមុខវិជ្ជាដែលនាំមកដាក់ឱ្យមានដំណើរការកម្មវិធីសិក្សា និងចំនួនក្រេឌីត ជាដើម។

មុខវិជ្ជាដែលបែងចែកជាបីប្រភេទ គឺ មុខវិជ្ជាឯកទេស មុខវិជ្ជាចំណេះទូទៅ និងមុខវិជ្ជាសហកិច្ចសិក្សា។ ក្នុងនោះ មុខវិជ្ជាឯកទេសនីមួយៗ មាន៣ក្រេឌីត មុខវិជ្ជាចំណេះទូទៅនីមួយៗមាន២ក្រេឌីត និងមុខវិជ្ជាសហកិច្ចសិក្សានីមួយៗ មាន៩ក្រេឌីត។

មុខវិជ្ជានីមួយៗដែលកំពុងដាក់ឱ្យសិក្សានាពេលបច្ចុប្បន្ននៅគ្រឹះស្ថានសិក្សានានានៅប្រទេសកម្ពុជា ច្រើនមានតម្លៃ៣ក្រេឌីតដូចៗគ្នា។

ចំណុចដែលគួរឱ្យចាប់អារម្មណ៍មួយទៀត គឺមុខវិជ្ជាសហកិច្ចសិក្សាសម្រាប់អ្នកសិក្សាថ្នាក់បរិញ្ញាបត្រ។ មុខវិជ្ជានេះប្រៀបបាននឹងជំហានសាកល្បងចំណេះដឹងដែលអ្នកសិក្សាទទួលបានក្រោយពីបានក្រេបយកវិជ្ជាក្នុងរយៈពេលសមស្របមួយនៅគ្រឹះស្ថានសិក្សា។ អ្នកសិក្សាត្រូវនាំយកចំណេះដឹងនៅក្នុងជំនាញទៅអនុវត្តជាក់ស្ដែងនៅក្រៅទីតាំងសិក្សា។ គ្រឹះស្ថានសិក្សាមួយចំនួននៅប្រទេសកម្ពុជាមួយចំនួនបានកំណត់ចំនួនក្រេឌីតលើមុខវិជ្ជានេះពី១ទៅ៣ក្រេឌីតប៉ុណ្ណោះ។

ដោយយល់ឃើញថា ការចុះអនុវត្តជាក់ស្ដែងមានសារៈប្រយោជន៍និងទាមទារពេលវេលាវែងមួយ នៅក្នុងកម្មវិធីសិក្សានេះ យើងកំណត់ឱ្យនិស្សិតប្រើពេលពេញមួយឆមាសណាមួយនៃឆ្នាំទី៤សម្រាប់តែមុខវិជ្ជាមួយនេះ។

## ឯកសារយោង


កង ឱម. (២០០២) ការអភិវឌ្ឍកម្មវិធីសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នាពេលបច្ចុប្បន្ន(សារណាបរិញ្ញាបត្រជាន់ខ្ពស់). ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា

កង ឱម. (២០១៦)"កម្មវិធីសិក្សា និងគុណភាពអប់រំ". នៅក្នុង វេទិការស្រាវជ្រាវវិទ្យាសាស្ត្រលើកទី២. ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា (ទំព័រ. ២៦៥-២៧២)

ក្រសួងអប់រំ យុវជន និងកីឡា (២០០៦). ភាសាខ្មែរឬសំរាប់អប់រំមូលដ្ឋានចំណេះដឹងទូទៅ. ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៤ក). ស្តង់ដាអំណាន៖ សៀវភៅណែនាំគ្រូបង្រៀនដើម្បីពង្រឹងសមត្ថភាពអំណានដល់សិស្ស ថ្នាក់ទី១. ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៥ក). សៀវភៅមគ្គុទេសក៍ សម្រាប់ការជ្រើសរើសគ្រឹះស្ថានសិក្សានិងមុខជំនាញបន្តការសិក្សានៅកម្រិតឧត្តមសិក្សា. ភ្នំពេញ៖ នាយកដ្ឋានឧត្តមសិក្សា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៥ខ). ក្របខណ្ឌកម្មវិធីសិក្សាចំណេះដឹងទូទៅនិងអប់រំបច្ចេកទេស. ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨ក). កម្មវិធីសិក្សាលម្អិតមុខវិជ្ជាអក្សរសាស្ត្រខ្មែរសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ. ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨ខ). កម្មវិធីសិក្សាលម្អិតមុខវិជ្ជាអក្សរសាស្ត្រខ្មែរសម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ. ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨គ). កម្មវិធីសិក្សាលម្អិតភាសាខ្មែរកម្រិតបឋមសិក្សា. ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា

ក្រុមប្រឹក្សាជាតិភាសាខ្មែរ. (២០១៣). សទ្ទានុក្រម ឈ្មោះប្រទេស, រាជធានី / រដ្ឋធានី និងបច្ចេកសព្ទភូមិវិទ្យាមួយចំនួន. ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា

ជុំ ស៊ុនណាង (២០១២). ភាសាខ្មែរសម្រាប់ទំនាក់ទំនង. មហាសារខាម៖ រោងពុម្ពអភិធាត

ជុំ ស៊ុនណាង (២០១៤). ភាសាខ្មែរក្នុងជីវភាពប្រចាំថ្ងៃ. មហាសារខាម៖ រោងពុម្ពឥន្ទនិល

បណ្ដាញសាកលវិទ្យាល័យអាស៊ាន. (២០១៦). ការគ្រប់គ្រងគុណភាពនៃកម្មវិធីអប់រំនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ព្រះរាជក្រឹត្យស្ដីពី ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ២០០៣

ម៉ក់ ភឺន. (១៩៩៦). "ខេមរវិទ្យា : តុល្យការនិងលទ្ធភាពខ្លះទៅអនាគត" នៅក្នុង សន្និសីទអន្តរជាតិស្ដីអំពី ខេមរវិទ្យា ចំណេះដឹងអំពីអតីតកាល និង ការរួមវិភាគទានក្នុងការស្ដារ និង ស្ថាបនាប្រទេសកម្ពុជាឡើងវិញ. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២, (ទំព័រ ៥៩-៧២)

រាជរដ្ឋាភិបាលកម្ពុជា (២០១៤). ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា. ភ្នំពេញ៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

វង់ សុធា (២០១៤). សន្ទនាភាសាខ្មែរ. មហាសារខាម៖ រោងពុម្ពឥន្ទនិល

Council of Europe. Common European Framework of Reference for Languages. Cambridge University Press.

Eberhard, David M., Gary F. Simons, and Charles D. Fennig (eds.). (2019). Ethnologue: Languages of the World. 22nd edition. Dallas, Texas: SIL International.

Fromkin, Victoria and et al (2011). An Introduction to Language. Boston: Wadsworth.

Gorgoniyev, Y. A. (1966). The Khmer Language. Moscow: Nauka Publishing House.

Headley, Robert Kirk. Cambodian-English Dictionary (Vol. 1, 2). Washington : The Catholic University of America Press, 1977.

Huffman, E. Franklin (1970). *វិដ្ឋាខេមរភាសា Modern Spoken Cambodian*. New York: Cornell University;

Huffman, Franklin E. (1967). *An Outline of Cambodian Grammar*. Doctor's Thesis. Cornell University;

Huffman, Franklin E. (1970). Cambodian System of Writing and Beginning Reader. London : Yale University Press.

Huffman, Franklin E. (1978). *English-Khmer Dictionary* (with phonetic symbol). Yale University Press;

Huffman, Franklin E., (1987) Modern Spoken Cambodian. New York: Cornell University;

Jacob, Judith M. (1968). Introduction to Cambodian. London: Oxford University Press.

Jacob, Judith M. (1993). Cambodian Linguistics, Literature and History. London: School of Oriental and African Studies;

Jenner, Philip Norman. (1969). Affixation in Modern Khmer. Michigan: University Microfilms.

Marzano, Robert J. and Kendall John S. The New taxonomy of Educational Objectives, 2nd edit. Thousand Oaks: Corwin Press, 2007;

Maspero, Georges. (1915). Grammair de la langue khmère. Paris: Imprimerie nationale.

Null, Westely. (2011). Curriculum from Theory to Practice. New York: Rowman & Littlefield Publishers, Inc;

RUPP (2007). http://www.rupp.edu.kh/center/kf/?page=background, Retrieved: 23 Aug 2017.

Saville-Troike, Muriel. (2006). Introducing Second Language Acquisition. Cambridge: Cambridge University Press.

The British Council (1978) London: Printing and Publishing Department.

The Ministry of Education Thailand. (2008). The Basic Education Core Curriculum. Bangkok: The Ministry of Education.

# អក្សរសិល្ប៍ប្រជាប្រិយជនជាតិព័រ
# នៅខេត្តពោធិ៍សាត់

ស្រាវជ្រាវដោយ លោក **ណុន សុខា**
លោកស្រី **ភាជ ណាង**
លោក **វ៉ាត សូផាន**
នាយកដ្ឋានអក្សរសាស្ត្រនិងអក្សរសិល្ប៍

បងប្អូនជនជាតិព័រ ជាជាតិសាសន៍មួយមានប្រពៃណី ទំនៀមទម្លាប់ របៀបរស់នៅរបស់គេតាំងពីយូរណាស់មកហើយ។ ដោយសារវប្បធម៌ទាំងនោះ ធ្វើឱ្យបងប្អូនជនជាតិដើមភាគតិចព័រមានអត្តសញ្ញាណរបស់ខ្លួនខ្ជាប់ខ្ជួន ដែលអត្តសញ្ញាណទាំងនោះមានដូចជា ភាសា រឿងព្រេងប្រជាប្រិយ ជំនឿ ម្ហូបអាហារ គ្រឿងលម្អ ផ្សេងៗក្នុងជីវភាពប្រចាំថ្ងៃ ជាដើម។ ហេតុមកដល់សព្វថ្ងៃនេះ ទំនៀមទម្លាប់មួយចំនួនត្រូវបាត់បន្តិចម្តងៗ មានតែមនុស្សវ័យចាស់ៗមួយចំនួនប៉ុណ្ណោះដែលនៅចេះចាំខ្លះ។

ក្នុងចំណោមមរតកនៃវប្បធម៌ទាំងនោះ រឿងព្រេងប្រជាប្រិយ ជាគ្រឿងសម្គាល់អត្តសញ្ញាណបងប្អូនជនជាតិព័រមួយដែរ។ គ្រប់បញ្ហាជីវភាពនៃការរស់នៅរបស់ពួកគាត់សុទ្ធតែមានជាប់ទាក់ទងនឹងការពន្យល់របស់បងប្អូនជនជាតិព័រនៅក្នុងរឿងព្រេងនេះទាំងអស់។ ប៉ុន្តែ គួរឱ្យសោកស្តាយចាស់ៗដែលចេះចាំរឿងរបៀបនេះនៅមានចំនួនតិចតួច ម្យ៉ាងទៀត ក្រុមអ្នកស្រាវជ្រាវយើងអាចធ្វើបានត្រឹមកម្រិតមួយប៉ុណ្ណោះ។

## រឿងនាងទុនសុត្រា

(និទានដោយលោកអ៊ំ **ង៉ែត ចាត** អាយុ៧៧ឆ្នាំ និង អ៊ំស្រី **យុត សាម៉ុន** អាយុ៦៣ឆ្នាំ ជនជាតិព័រ)

**នាងទុនសុត្រា កូនអើយទម្លាក់ស៊ក់[32]ឱ្យ៉ា ឱ្យក្រងផ្កាឱ្យ !**

កាលដើមឡើយមានស្រីៗក្នុងភូមិជាច្រើនតែងនាំគ្នាចូលព្រៃដើម្បីច្រូតស្បូវនិងជីកដំឡូង។ ថ្ងៃមួយពេលទទួលទានអាហារថ្ងៃត្រង់រួច មាននាងម្នាក់ពុំបានយកទឹកមកផឹកនឹងគេ ហើយគ្មាននរណាចែករំលែកទឹកឱ្យផង នាងនោះក៏បានចេញដើរទៅរកទឹកផឹកតែម្នាក់ឯង នាងក៏ប្រទះឃើញទឹកក្នុងដានជើងដំរីមួយថ្លុក ក៏ក្បង់ទឹកនោះផឹក រួចក៏ត្រឡប់មកវិញ។

មកដល់ផ្ទះអស់កាលជាច្រើនខែ នាងដែលផឹកទឹកក្នុងដានដំរីនោះក៏មានផ្ទៃពោះ។ លុះគ្រប់ខែនាងក៏ប្រសូត្របានកូនស្រីមួយដាក់ឈ្មោះថា **នាងទុនសុត្រា**។

អស់កាលច្រើនឆ្នាំកន្លងទៅ **នាងទុនសុត្រា**ចម្រើនវ័យកាន់តែធំ នាងតែងដើរលេងជាមួយក្មេងៗនៅក្នុងភូមិជាអ្នកជិតខាងជារឿយៗ។ ថ្ងៃមួយ **នាងទុនសុត្រា**បានទៅលេងអង្គញ់ជាមួយក្មេងៗនៅក្បែរផ្ទះនាង នាងតែងលេងឈ្នះគេគ្រប់ពេលទាំងអស់ មិនដែលចាញ់ម្តងណាឡើយ នាងលេងល្បែងអ្វីក៏តែងតែឈ្នះដែរ។ ភាពពូកែរបស់**នាងទុនសុត្រា** បានធ្វើឱ្យពួកក្មេងៗដែលលេងជាមួយនាងខឹងយ៉ាងខ្លាំង ហើយជេរតិះដៀលនាងថា «***មីកូនអត់ឪ***»។ កាលបើបានឮពាក្យគេជេរបែបនេះ នាងខឹងខ្លាំងណាស់ ពេលត្រឡប់មកដល់ផ្ទះវិញ នាងបានសួរទៅម្តាយដើម្បីរកឪពុក។ នាងជាម្តាយបានឆ្លើយប្រាប់ទៅកូនថា បើកូនចង់ទៅរកឪពុករបស់កូន ចូរកូនទៅសួរដំរី ចាប់ពីដំរីមានភ្លុក១ រហូតដល់ដំរីមានភ្លុក១២ នោះនឹងដឹងពីឪពុករបស់កូនហើយ។ ក្រោយពីស្តាប់

---

[32] « *ស៊ក់* » ជាភាសាព័រ មានន័យថា *សក់* ។

សម្តីម្តាយរួច **នាងទុនសុត្រា**ក៏ធ្វើដំណើរស្វែងរកឪពុកតាមការប្រាប់របស់ម្តាយ នាងក៏បានជួបដំរីជាច្រើន ហើយសួរទៅដំរីទាំងអស់ ចាប់ពីដំរីមានភ្លុក១ រហូតដំរីមានភ្លុក១២។ កាលបើឃើញក្មេងស្រីសួររកឪពុកដូច្នេះ ដំរីភ្លុក១២ក៏បួងសួងថា «*ប្រសិនបើក្មេងស្រីនេះជាកូនរបស់ខ្ញុំ សូមឱ្យខ្ញុំគ្រវែងដៃឆ្វេងលើកដៃស្តាំបានដល់ខ្នង*»។ ក្រោយពីបានសាកល្បងធ្វើហើយ ដំរីភ្លុក១២ក៏បានសម្រេចដូចក្តីប្រាថ្នាមែន ពេលនោះដំរីនោះក៏ទទួលនាងជាកូនស្រីរបស់ខ្លួន។

អ្នកទាំងពីរសប្បាយចិត្តយ៉ាងខ្លាំង ពេលស្គាល់ថាជាឪពុកកូន។ ដោយខ្លាចសត្រូវមកធ្វើបាបកូន ដំរីជាឪពុកបានធ្វើរានមួយយ៉ាងខ្ពស់នៅក្នុងព្រៃ ទុកសម្រាប់ឱ្យកូនស្នាក់នៅលើនោះ ហើយដំរីនោះតែងចេញទៅរកចំណីបាត់ៗរៀងរាល់ថ្ងៃ។ ពេលត្រឡប់មកវិញ ដំរីជាឪពុកតែងស្រែកហៅកូនថា ***អឺ! នាងទុនសុត្រា ទម្លាក់ស៊ាក់ឱវ៉ា ឪក្រងផ្កាឱ្យ។*** ដំរីជាឪពុកតែងក្រងសក់ឱ្យកូនរៀងរាល់ពេលដែលត្រឡប់មកពីរកចំណីវិញ។

គ្រប់ពេលចេញទៅរកចំណី ដំរីជាឪពុកតែងផ្តាំកូនឱ្យពន្លត់ភ្លើងចន្លុះនៅពេលយប់។ វេលាយប់មួយនាងភ្លេចពន្លត់ភ្លើង ធ្វើឱ្យព្រានព្រៃឃើញភ្លើងនោះ ហើយក៏ផ្សងថា ***បើភ្លើងនេះជាភ្លើងព្រាយ សូមឱ្យរលត់ តែបើភ្លើងនេះជាភ្លើងរបស់មនុស្សសូមកុំឱ្យរលត់។*** ក្រោយពេលផ្សងរួច ភ្លើងនៅតែឆេះដដែល ព្រានព្រៃក៏ដាក់ជណ្តើរឡើងលើរានចាប់**នាងទុនសុត្រា**។ **នាងទុនសុត្រា**ភ័យខ្លាំងណាស់ ស្រែកឱ្យគេឯងជួយ តែមិនមានមនុស្សណាម្នាក់មកជួយនាងឡើយ។ ព្រានព្រៃក៏ចាប់លីនាងយកទៅ ក្នុងពេលជាមួយគ្នានេះដែរ **នាងទុនសុត្រា**បានយកគ្រាប់ល្ងដាក់តាមខ្លួន ហើយបាចតាមផ្លូវខាងឆ្វេងផង ខាងស្តាំផងរហូតដល់កន្លែងព្រានព្រៃរស់នៅ ដើម្បីឱ្យចំណាំផ្លូវនិងទុកជាសញ្ញាឱ្យឪពុកបានដឹង។

ចំណែកដំរីជាឪពុកពេលត្រឡប់មកពីរកចំណីវិញ បានស្រែកហៅកូនយ៉ាងពីរោះថា ***អឺ! នាងទុនសុត្រា ទម្លាក់ស៊ាក់ឱវ៉ា ឪក្រងផ្កាឱ្យ។*** ដំរីជាឪពុកហៅនាងបីបួនដង នៅតែមិនឮសំឡេងឆ្លើយ ក៏ដើរជុំវិញរាន ហើយក៏ប្រទះឃើញដានជើងមនុស្សចម្លែកនិងគ្រាប់ល្ងជ្រុះពេញដី ដំរីជាឪពុកគិតថា កូនស្រីរបស់ខ្លួន ពិតជាមានចោរចាប់យកទៅបាត់ហើយ។ ដំរីជាឪពុកក៏ដើរតាមគ្រាប់ល្ងនោះ រហូតដល់កន្លែងព្រានព្រៃទុកកូនស្រី ដែលកន្លែងនោះហ៊ុមព័ទ្ធដោយរបងពីរបីជាន់ ដំរីក៏ចាប់ទាញរបងនោះនិងជាន់កម្ទេចឱ្យខ្ទេចខ្ទីទាំងអស់។ ព្រានព្រៃឃើញសភាពដូចនេះ ក៏រកមធ្យោបាយសម្លាប់ដំរី ដោយយកជ័រទឹកទៅស្លឱ្យរលាយដូចជាទឹក ដើម្បីទុកឱ្យដំរីផឹក។

